# អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា (ខេប)


*“ការអភិវឌ្ឍមនុស្សប្រកបដោយសេចក្ដីថ្លៃថ្នូរ”*



# របាយការណ៍ប្រចាំឆ្នាំ ២០១៦

**៣១ មករា ២០១៧**

(អង្គការ ខេប បានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ ១៩៩៩ )


ការិយាល័យ: សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ប្រអប់សំបុត្រ: P.O Box ១៦២១ ភ្នំពេញ កម្ពុជា

០៤២-០៩៤១-៤៨១ / ០៤២-៩៤១-៩១៨
kape@kapekh.org
www.kapekh.org
www.facebook.com/kapeaction
www.facebook.com/kapeaction
www.plus.google.com/+KAPECambodia
www.youtube.com/TheKapeCambodia
www.linkedin.com/company/kampuche an-action-for-primary-education


*សម្គាល់: សូមមើលអំពីផលជះរបស់គម្រោងនីមួយៗនៅលើគេហទំព័រអង្គការ ខេប។ លោកអ្នកអាចអានករណីសិក្សាបន្ថែមតាមរយៈតំណភ្ជាប់:*
*kapekh.org/en/what-we-do/4/?pro_id=20*



# សារប្រធានក្រុមប្រឹក្សាភិបាល

*ក្នុងនាមក្រុមប្រឹក្សាភិបាលអង្គការ ខេប ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងឯកភាពទៅលើរបាយការណ៏ប្រចាំឆ្នាំ២០១៦ របស់អង្គការ។ របាយការណ៏នេះបានបង្ហាញទាំងដំណើរការកម្មវិធីជោគជ័យនៅក្នុងបរិយាកាសប្រតិបត្តិការដ៏លំបាកដូចនឹងចក្ខុវិស័យច្បាស់លាស់មួយសម្រាប់អនាគត។ ក្រុមប្រឹក្សាភិបាលសូមចូលរួមអបអរសាទរដល់បុគ្គលិកអង្គការ ខេប ទាំងអស់ដែលបានខិតខំពុះពារជួយកុមារកម្ពុជាដែលមានវិបត្តិឱ្យទទួលបានសេវាអប់រំមានគុណភាពខ្ពស់ រក្សាបាននូវស្តង់ដាអភិបាលកិច្ចល្អ មានតម្លាភាព និងមានប្រសិទ្ធភាពក្នុងការប្រើប្រាស់មូលនិធិ។ ក្រុមប្រឹក្សាភិបាលសូមធ្វើការឆ្លុះបញ្ចាំងចំពោះជោគជ័យនេះទៅឆ្នាំបន្តបន្ទាប់ទៀត ដូចយើងបានដឹងហើយថាអង្គការ ខេប បានឈានមកដល់ខួបឆ្នាំទី២០របស់ខ្លួន៕*

**ប្រធានក្រុមប្រឹក្សាភិបាល**

**ហ៊ាន ភុយ**

ខេបគឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ និងកម្មវិធីអាហារូបករណ៏សម្រាប់សិស្សនៅសាកលវិទ្យាល័យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ៧១.០០០នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ ដែលបង្រៀននៅជាង ១៦៥សាលាក្នុង ១៩ខេត្ត-រាជធានី។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជន នូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៏ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី/ច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

## មាតិកា


សារប្រធានក្រុមប្រឹក្សាភិបាល.......... 3
សារនាយកប្រតិបត្តិ.......... 3
សេចក្តីសង្ខេប .......... 4
ការឆ្លុះបញ្ចាំងទៅថ្ងៃអនាគត .......... 5
ព្រឹត្តិការណ៏សំខាន់ៗក្នុងឆ្នាំនេះ.......... 6
ព័ត៏មានសំខាន់ៗ និងព្រឹត្តិការណ៏អន្តរជាតិ.......... 8
បច្ចុប្បន្នភាព ធនធានសិក្សា (ធធស) .......... 10


## កម្មវិធី


គម្រោង សាលារៀនដៃគូ (BSI) .......... 11
គម្រោង សាលារៀនជំនាន់ថ្មី (NGS).......... 12
គម្រោង លើកកម្ពស់សេវាកម្មសុខភាពសាលារៀន (ISHS) .......... 14
គម្រោង សៀវភៅសម្រាប់កម្ពុជា (BfC) .......... 15
គម្រោង អប់រំកុមារ (EAC) .......... 16
កម្មវិធី អប់រំបញ្ចូលគ្នា (IEP).......... 17
គម្រោង ខ្ញុំកំពុងរៀន (IML)!.......... 20
គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៏ (REACH) ..... 21
គម្រោង ងាយស្រួលរៀន (E2L) .......... 22
គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ (E4K) .......... 23
គម្រោង វិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC II).......... 24
គម្រោង គ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ (SML).......... 25
គម្រោង បណ្ណាល័យអេឡិចត្រូនិចសម្រាប់កុមារ (CDL) .......... 26
គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព (QLE Expansion).......... 27

ការបង្ហាញហិរញ្ញវត្ថុក្នុងឆ្នាំ២០១៦ .......... 28
ក្រុមអ្នកគ្រប់គ្រងនៅក្នុងឆ្នាំ២០១៦ .......... 29
រចនាសម្ព័ន្ធអង្គការ ខេប នៅក្នុងឆ្នាំ២០១៦ .......... 30

# សារនាយកប្រតិបត្តិ



ខ្ញុំមានសេចក្តីរីករាយ សូមបង្ហាញជូននូវរបាយការណ៍ប្រតិបត្តិការប្រចាំឆ្នាំ និងសារស្វាគមន៍ ប្រសិទ្ធពរជ័យគ្រប់ប្រការដល់អ្នកពាក់ព័ន្ធ អ្នកឧបត្ថម្ភគាំទ្រ ព្រមទាំងម្ចាស់ជំនួយទាំងអស់ដែលបានធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការ ខេប ក្នុងរយៈពេលពេញមួយឆ្នាំ២០១៦កន្លងមកនេះ។ នៅក្នុងរបាយការណ៍ការបូកសរុបលទ្ធផលនេះដែរ អង្គការ ខេប ស្ទើរតែមិនជឿខ្លួនឯងថា មកដល់បច្ចុប្បន្ននេះ អង្គការបានដំណើរការមានរយៈពេលជាង១៧ឆ្នាំហើយ គិតចាប់តាំងពីឆ្នាំបានដំណើរការដំបូង និងចុះបញ្ជីផ្លូវការនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ១៩៩៩។

អង្គការ ខេប មានសេចក្តីសោមនស្សនិងធ្វើការឆ្លុះបញ្ចាំងរយៈពេលច្រើនឆ្នាំកន្លងមកនេះ ដោយបានចាប់ដៃគូសហការជាមួយរាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធ ដើម្បីប្រាកដថា៖ តើ»**ខេប**» បានដើរមកដល់ចំណុចត្រឹមណាហើយក្នុងអំឡុងពេលជិតពីរទសវត្សរ៍មកនេះ។ មុនការឈានចូលទសវត្សរ៍ទីបីនាពេលប៉ុន្មានឆ្នាំខាងមុខទៀតនេះ »**ខេប**» បានរៀបចំខ្លួនធ្វើការបូកសរុបលទ្ធផលដែលជាការលើកទឹកចិត្តមួយធ្វើឱ្យអង្គការអាចឈរជើងបានយូរអង្វែងនៅក្នុងវិស័យអប់រំ។

រយៈពេលពេញមួយឆ្នាំមកនេះ អង្គការ ខេប បានបន្តឧបត្ថម្ភគាំទ្រ និងអនុវត្តគម្រោងទាំងទំហំតូចនិងទំហំធំសរុបចំនួន១៥គម្រោង។ គម្រោងការទាំងនេះបានផ្តល់អន្តរាគមន៍ឧបត្ថម្ភគាំទ្រដល់កុមារ និងយុវជនកម្ពុជាចំនួនប្រមាណជា ៧១.០០០នាក់ នៅតាមសាលាបឋមសិក្សាចំនួន ១៤៦ សាលាមធ្យមសិក្សាបឋម និងទុតិយភូមិចំនួន ១៩ រួមទាំងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមួយចំនួនទៀត។ គម្រោងការទាំងអស់នេះផ្តោតសំខាន់ទៅលើការអភិវឌ្ឍសំខាន់ៗរួមមាន៖ សកម្មភាពប្រមូលកុមារចូលរៀន ការនាំយកនូវស្តង់ដាអប់រំប្រកបដោយគុណភាពនៅក្នុងសតវត្សរ៍ទី២១ និងការលើកកម្ពស់អភិបាលកិច្ចសាលារៀនល្អ។

ព្រឹត្តិការណ៍ធំសំខាន់ៗមួយចំនួននៅក្នុងឆ្នាំនេះ ដែលអង្គការ ខេប សម្រេចបានជោគជ័យ រួមមាន៖ ការអញ្ជើញមកធ្វើទស្សនកិច្ចសិក្សាពីសមាជិករដ្ឋសភាជាតិនៅសាលារៀនជំនាន់ថ្មីនៃវិទ្យាល័យ ហ៊ុន សែន ខេត្តកំពង់ចាម ការបញ្ចប់ឯកសារគោលនយោបាយបង្កើតសាលារៀនជំនាន់ថ្មីនិងត្រូវបានចុះហត្ថលេខាអនុម័តដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងអំឡុងកាលពីខែកញ្ញា ឆ្នាំ២០១៦។ នេះគឺជាសមិទ្ធផលដ៏ធំធេងដែលខេបសម្រេចបានមកពីការអនុវត្តសាកល្បងលំនាំកម្មវិធីសាលារៀនធម្មនុញ្ញ ហើយប្តូរមកហៅថា «សាលារៀនជំនាន់ថ្មី« ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដោយបានធ្វើឱ្យមានការផ្លាស់ប្តូរដ៏ធំមួយមិនធ្លាប់មានពីមុនមកអំពីវិធីដែលរាជរដ្ឋាភិបាលធ្វើការវិនិយោគក្នុងប្រព័ន្ធអប់រំសាធារណៈរបស់រដ្ឋ។ ទោះបីជាស្ថិតនៅក្នុងកម្រិតតូចយ៉ាងណាក៏ដោយ ក៏កម្មវិធីសាលារៀនជំនាន់ថ្មីនេះទទួលបាននូវសមិទ្ធផលធំៗមួយចំនួន រួមមាន៖ ការលុបបំបាត់ថ្នាក់បង្រៀនឯកជន ការស៊ីសំណូក ការបង្រៀនគួរនៅក្នុងថ្នាក់ និងសាលារៀន ជាពិសេសការបង្កើតស្តង់ដាបង្រៀនកម្រិតខ្ពស់នូវមុខវិជ្ជាវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។ កម្មវិធីនេះកំពុងទទួលបានការគាំទ្រយ៉ាងខ្លាំងពីគ្រប់មជ្ឈដ្ឋាន និងក្រុមគ្រួសារវណ្ណៈកណ្តាល ពួកគាត់ដកកូនចេញពីវិស័យឯកជននាំកូនមកសិក្សានៅក្នុងវិស័យអប់រំសាធារណៈវិញ ដែលនេះគឺជាគោលបំណងដ៏ចម្បងមួយរបស់រាជរដ្ឋាភិបាល។ ក្រសួងអប់រំ យុវជន និងកីឡា បានប្តេជ្ញាចិត្តថានៅក្នុងឆ្នាំខាងមុខបន្តបន្ទាប់ទៀតនឹងពង្រីកមូលនិធិសម្រាប់កម្មវិធីនេះដែលវាជាក្តីរំពឹងដ៏រំភើបមួយរបស់ »**ខេប**» និងដៃគូអភិវឌ្ឍនានាជាច្រើនឯទៀត។

ខេបបានបន្តបោះជំហានខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់សុសវែរថ្មី ដើម្បីជួយអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាហើយការរៀបចំអភិវឌ្ឍន៍នូវសុសវែររបស់ខ្លួននេះគឺផ្តើមនៅក្នុងកម្រិតសាលាបឋមសិក្សា ដោយប្រើប្រាស់ថវិកាទាំងស្រុងផ្តល់មកពីអង្គការ **All Children Reading** និងបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនបង្កើតសុសវែរអន្តរជាតិដើម្បីនាំយកនូវសុសវែរថ្នាក់ពិភពលោកមកប្រើប្រាស់នៅកម្រិតមធ្យមសិក្សាទៀត។ សុសវែរនេះគឺដើរស្របទៅតាមបរិបទនឹងបរិយាកាសសាលារៀន និងកម្មវិធីសិក្សានៅប្រទេសកម្ពុជា ហើយវាអាចជួយផ្លាស់ប្តូរវិធីសាស្ត្រគ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីបាន។

ជាថ្មីម្តងទៀតជំនួសមុខឱ្យសហគមន៍ខេប ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាល អង្គការដៃគូ និងម្ចាស់ជំនួយនានា ចំពោះកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ហើយយើងរំពឹងថា នៅក្នុងរយៈពេលនាឆ្នាំខាងមុខនឹងមានការច្នៃប្រឌិតថ្មីបន្ថែមទៀតក្នុងប្រព័ន្ធអប់រំនៃប្រទេសកម្ពុជា៕

កំពង់ចាម ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៧

**នាយកប្រតិបត្តិ**

**សៅ វណ្ណា**

# សេចក្តីសង្ខេប

នៅក្នុងឆ្នាំ២០១៥ អង្គការ ខេប បានធ្វើរបាយការណ៍បង្ហាញថា អង្គការបានឆ្លងកាត់ដំណាក់កាលអន្តរកាលក្នុងការស្វែងរកមូលនិធិពេញលេញដោយមិនពឹងផ្អែកម្ចាស់ជំនួយបែបទ្វេភាគីឡើយ។ ក្នុងគ្រានេះ ខេបរក្សាបាននូវគម្រោងធំសំខាន់ៗចំនួន ១៥គម្រោង ចាប់ពីកម្មវិធីប្រមូលកុមារចូលរៀនដល់កម្មវិធីលើកកម្ពស់គុណភាពអប់រំ។ ការប្តូរទៅជាការផ្តល់ហិរញ្ញប្បទានឯកជន គឺជាប្រភពមូលនិធិដ៏សំខាន់ផ្តល់ឱកាសបន្ថែមទៀតពីគម្រោងខ្នាតមធ្យមទៅជាគម្រោងខ្នាតតូច ដែលការវាស់ស្ទង់ត្រួតពិនិត្យគុណភាពកាន់តែមានភាពងាយស្រួលជាងមុន ដូច្នេះហើយដែលធានាពីសុពលភាពល្អនៃសមិទ្ធផល និងអត្តសញ្ញាណរបស់ខេប។ នៅក្នុងឆ្នាំនេះ ការខិតខំប្រឹងប្រែងរួមធ្វើឱ្យមានស្ថេរភាពតាមរយៈកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡាដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងសាលារៀនជំនាន់ថ្មីរបស់ខេប។




សមិទ្ធផលកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការផ្តល់ហិរញ្ញប្បទានដល់កម្មវិធីខេប គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដែលមិនធ្លាប់មាននៅក្នុងវិស័យអប់រំ និងក៏ជាប្រផ្នូលល្អសម្រាប់សម្ព័ន្ធភាពថ្មីរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល។ ការផ្តល់ហិរញ្ញប្បទានរបស់ក្រសួងបានធ្វើឱ្យកម្មវិធីខេបកាន់តែរឹងមាំច្បាស់លាស់ ហើយបានជួយខេបជំរុញការឧបត្ថម្ភគាំទ្រដំណើរការសាលារៀនធម្មនុញ្ញទៅមុខនៅក្នុងប្រព័ន្ធអប់រំសាធារណៈនៅកម្ពុជា ដែលអាចផ្លាស់ប្តូរនូវវិធីសាស្ត្រដែលរដ្ឋាភិបាល និងម្ចាស់ជំនួយធ្វើការអភិវឌ្ឍ។ គម្រោងសាលារៀនជំនាន់ថ្មីបានក្លាយទៅជាកម្មវិធីសំខាន់បំផុត មានសក្តានុពលធ្វើឱ្យមានការផ្លាស់ប្តូររបៀបគិតរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយអំពីអភិបាលកិច្ចសាលារៀនក្នុងវិស័យសាធារណៈ។

## គម្រោងចំនួន ១៥ ក្នុងឆ្នាំ២០១៦

| | |
|---|---|
| BfC | គម្រោង សៀវភៅសម្រាប់កម្ពុជា |
| BSI | គម្រោង សាលារៀនដៃគូ |
| E2L | គម្រោង ងាយស្រួលរៀន |
| E4K | គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ |
| EAC | គម្រោង អប់រំកុមារ |
| GEI | គម្រោង អប់រំកុមារី |
| IML | គម្រោង ខ្ញុំកំពុងរៀន |
| ISHS | គម្រោង លើកកម្ពស់សេវាកម្មសុខភាពសាលារៀន |
| NGS | គម្រោង សាលារៀនជំនាន់ថ្មី/ខេត្តស្វាយរៀង |
| NGSI | គម្រោង សាលារៀនជំនាន់ថ្មី |
| QLE | គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព |
| REACH | គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ |
| SML | គម្រោង គ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ |
| STEM4Women | គម្រោង ស្ទែមសម្រាប់ស្ត្រី |
| TRAC II | គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ II |

ខេបក៏បានទទួលជោគជ័យខ្លាំងផងដែរក្នុងការតស៊ូមតិលើកម្មវិធីច្នៃប្រឌិតថ្មី រួមមានការប្រជុំទៀងទាត់ជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៦នេះ ជាពិសេស ដំណើរទស្សនកិច្ចរបស់សមាជិកសភាជាតិដឹកនាំដោយឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ និងការធ្វើបទបង្ហាញជាច្រើនទៀតនៅក្នុងមហាសន្និបាតថ្នាក់ជាតិ និងអន្តរជាតិក្នុងប្រទេសកម្ពុជា ប្រទេសវៀតណាម ប្រទេសសិង្ហបុរី និងទីក្រុងប៉ារីសនៃប្រទេសបារាំង។

ខេបក៏បានធ្វើការអភិវឌ្ឍសំខាន់ៗក្នុងឆ្នាំ២០១៦នេះផងដែរដើម្បីសម្រេចឱ្យបាននូវគោលបំណងកម្មវិធីជាយុទ្ធសាស្ត្រមួយចំនួន។ គោលបំណងទាំងអស់នេះផ្តោតទៅលើសកម្មភាពសំខាន់ៗ រួមមាន៖ ការពង្រឹងអំណានថ្នាក់ដំបូង កម្មវិធីអប់រំយុវជន និងការប្រឹក្សាអាជីព ការតស៊ូមតិសម្រាប់អនុវត្តកម្មវិធីស្ទែម (STEM) ក៏ដូចជាការច្នៃប្រឌិតថ្មីៗដែលលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ។ ក្នុងកាលៈទេសៈនេះ ខេបបានឈានមុខគេដ៏ធំក្នុងការបង្កើតបន្ទប់វិទ្យាសាស្ត្រ បណ្ណាល័យសតវត្សរ៍ទី២១ និងកម្មវិធីស្លាបព្រាកម្មថ្មីនៅសាលារៀនដោយចាប់ផ្តើមធ្វើពីសាលារៀនចាស់ៗដែលបានឆ្លើយតបតម្រូវការសតវត្សរ៍ថ្មី។ ការខិតខំប្រឹងប្រែងទាំងអស់នេះបានក្លាយជាទម្រង់វិនិយោគបន្តក្នុងការអភិវឌ្ឍកម្មវិធី ដែលនាំទៅរកការរៀបចំកម្មវិធីធំថ្មីៗជាច្រើន ក៏ដូចជាការពង្រីកគម្រោងបន្តពីឆ្នាំ២០១៥ (សូមមើលតារាងខាងក្រោមទំព័រខាងស្តាំ)។



ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពមូលនិធិនៅតែជាបញ្ហាប្រឈមសម្រាប់ខេប ដោយសារការបែងចែកមូលនិធិមានកម្រិតរឹតត្បិត និងមានភាពលំបាកជាច្រើនទៀតក្នុងប្រតិបត្តិការចំណាយហិរញ្ញវត្ថុនៅការិយាល័យកណ្តាលរបស់ខេប។ ដូច្នេះ គម្រោងថវិកាប្រចាំឆ្នាំរបស់ខេបរក្សាបាននូវកម្រិតមួយខ្ពស់ជាង ២លានដុល្លាអាមេរិក ប៉ុន្តែវាក៏ជាការកាត់បន្ថយការចំណាយនៅកម្រិតការិយាល័យផងដែរ ដែលនេះធ្វើឱ្យខេបពិបាករក្សាបាននូវស្តង់ដាខ្ពស់នៃគណនេយ្យ និងការធ្វើរបាយការណ៍។ បញ្ហានេះកាន់តែប្រឈមឡើងដោយសារមានម្ចាស់ជំនួយជាច្រើនក៏បានបង្កើនតម្រូវការរដ្ឋបាលរបស់ពួកគេមកឱ្យអង្គការ ប៉ុន្តែពួកគេបានកាត់ចោលការឧបត្ថម្ភគាំទ្រប្រតិបត្តិការនៅកម្រិតការិយាល័យកណ្តាលដែលត្រូវឆ្លើយតបតម្រូវការទាំងនេះ៕

# ការផ្លាស់ប្តូរ ដើម្បីទៅមុខ!

នៅពេលវដ្តកម្មវិធីជាច្រើននឹងត្រូវបិទបញ្ចប់នៅចុងឆ្នាំ ២០១៨ ខាងមុខនេះ អង្គការ ខេប បានប្តូរការវិនិយោគដ៏លំបាកដើម្បីបង្កើតកម្មវិធីអភិវឌ្ឍដែលឆ្លើយតបនឹងផែនការយុទ្ធសាស្រ្តរយៈពេល ៥ឆ្នាំរបស់ខ្លួន។ ដូចបានលើកឡើងខាងដើម ការអភិវឌ្ឍនេះធ្វើឱ្យខេបខិតខំពុះពារយកចិត្តទុកដាក់ខ្លាំងលើការបង្កើតគម្រោងពាក់ព័ន្ធបញ្ហាយុវជន អំណានថ្នាក់ដំបូង បច្ចេកវិទ្យាសម្រាប់ការអប់រំ ហើយសំខាន់បំផុតនោះគឺការអភិវឌ្ឍសាលារៀនធម្មនុញ្ញ។ ជាសរុបរួម ខេបបានរៀបចំសំណើសុំចំនួន១៤ដាក់ស្នើទៅម្ចាស់ជំនួយដើម្បីពិនិត្យ និងអនុម័ត គម្រោងចំនួន ១០ស្មើ៧១% ទទួលបានការអនុម័ត គម្រោង ចំនួន០១ស្មើនឹង៧% ស្ថិតក្នុងបញ្ជីរង់ចាំការអនុម័ត និងមានបីសំណើសុំស្មើនឹង២១% បានបរាជ័យ។ ខេបក៏បានដឹកនាំ ឬចូលរួមក្នុងការសិក្សាស្រាវជ្រាវជាច្រើនផងដែរក្នុងឆ្នាំ២០១៦នេះ រួមមាន៖ ការសិក្សាអំពីសារៈសំខាន់ក្នុងការអប់រំគ្រូដោយមានការឧបត្ថម្ភគាំទ្រពីអង្គការឆាលហ្វានកម្ពុជា និងការសិក្សាស្តីពីលក្ខខណ្ឌសិក្សាអប់រំនៅក្នុងខេត្តមណ្ឌលគិរី ដែលឧបត្ថម្ភគាំទ្រដោយអង្គការ WeWorld។ ការសិក្សាទាំងនេះ ជាក់ស្តែងបានធ្វើឱ្យខេបរីកចម្រើនការស្រាវជ្រាវច្រើនឆ្នាំកន្លងទៅដែលជួយធ្វើឱ្យការរៀបចំគម្រោងនៅថ្ងៃអនាគតកាន់តែប្រសើរឡើង៕



*ស្ពានត្បូងកម្មសាលារៀនជំនាន់ថ្មី: សួនច្បារនៅជាប់ទ្វារសាលារៀនជំនាន់ថ្មី ខេត្តកំពង់ចាម បង្កើតបរិយាកាសរីករាយសម្រាប់សិស្សសិក្សា និងចែករំលែកនៅក្នុងប្រព័ន្ធសាលារដ្ឋ។*

## សេចក្តីសង្ខេបការអភិវឌ្ឍកម្មវិធីថ្មីៗក្នុងឆ្នាំ ២០១៦

| គម្រោង | ដៃគូ | ម្ចាស់ជំនួយ | លក្ខខណ្ឌ | រយៈពេល |
|---|---|---|---|---|
| ១. គម្រោង អាហារសម្រាប់ការអប់រំ (អំណានថ្នាក់ដំបូង) | កម្មវិធីស្បៀងអាហារពិភពលោក<br>អង្គការអប់រំពិភពលោក | ក្រសួងកសិកម្មសហរដ្ឋអាមេរិក | ជោគជ័យ | ៣ឆ្នាំ |
| ២. គម្រោង STEM4Women | Classroom of Hope | អង្គការស្ត្រី១០០ | ជោគជ័យ | ២ឆ្នាំ |
| ៣. គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ (ពង្រីកបន្ត) | ធនធានសិក្សា-ខេប | All Children Reading | ជោគជ័យ | ៧ខែ |
| ៤. គម្រោង សាលារៀនជំនាន់ថ្មី (ពង្រីកបន្ត) | អង្គការអប់រំពិភពលោក | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១៥ខែ |
| ៥. គម្រោង សាលារៀនជំនាន់ថ្មី | ក្រសួងអប់រំ យុវជន និងកីឡា | មូលនិធិ Franks Family | ជោគជ័យ | ៣ឆ្នាំ |
| ៦. គម្រោង សាលារៀនជំនាន់ថ្មី/ខេត្តស្វាយរៀង | -- | អង្គការឆាលហ្វាន | ជោគជ័យ | ៣ឆ្នាំ |
| ៧. គម្រោង ងាយស្រួលរៀន (ពង្រីកបន្ត) | -- | អង្គការឆាលហ្វាន | ជោគជ័យ | ៣ឆ្នាំ |
| ៨. គម្រោង អាហារូបករណ៍សិស្សស្រីនៅសាកលវិទ្យាល័យ | អង្គការមូលនិធិអាស៊ី | អង្គការមូលនិធិ Merali | ជោគជ័យ | ៤ឆ្នាំ |
| ៩. គម្រោង សៀវភៅសម្រាប់កម្ពុជា (ពង្រីកបន្ត) | -- | អង្គការមូលនិធិអាស៊ី | ជោគជ័យ | ១ឆ្នាំ |
| ១០. គម្រោង ជំនួយការរៀនវិទ្យាសាស្រ្ត (SAS) | -- | USAID<br>Development Alternatives, Inc | ជោគជ័យ | ៩ខែ |
| ១១. គម្រោង អំណានថ្នាក់ដំបូងនៅកម្ពុជា | Chemonics<br>Room to Read<br>អង្គការអប់រំពិភពលោក | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ | លុបចោល | ៥ឆ្នាំ |
| ១២. គម្រោង ត្រីវិស័យ | អង្គការមូលនិធិអ្នកទ្រី | ក្រុមហ៊ុន Google | នៅរង់ចាំ | ៣ឆ្នាំ |
| ១៣. គម្រោង អនាគតជើងឯក | អង្គការអប់រំពិភពលោក | អង្គការមូលនិធិ Qatar | នៅរង់ចាំ | ៣ឆ្នាំ |
| ១៤. គម្រោង វិធីសាស្រ្តសរុបដើម្បីពង្រីកអំណានសម្រាប់កុមារ (ពង្រីកបន្ត) | -- | អង្គការមូលនិធិ Atlassian | មិនជោគជ័យ | ៤ឆ្នាំ |

## ទស្សនកិច្ចសិក្សានៃគណៈកម្មការទី៧រដ្ឋសភាជាតិនៅសាលារៀនជំនាន់ថ្មី ក្រុងកំពង់ចាម


លោក សឿង វ៉ាន់ ជានាយកសាលារៀនជំនាន់ថ្មីបានដឹកនាំអ្នកប្រតិបត្តិអង្គការពន្យល់អំពីការសិក្សាក្នុងថ្នាក់រៀន

នៅខែមករា ឆ្នាំ២០១៦ ខេបមានមហាកិត្តិយសបានទទួលស្វាគមន៍ដំណើរទស្សនកិច្ចសិក្សាពីសមាជិកករដ្ឋសភាចជាតិចំនួន៧រូបមកពីគណៈកម្មការទី៧ទទួលបន្ទុកសម្រាប់ការអប់រំ ទេសចរណ៍ វប្បធម៌ និងបណ្តុះបណ្តាល។ គោលបំណងទស្សនកិច្ចសិក្សានេះធ្វើឡើងដើម្បីស្វែងយល់អំពីកំណែទម្រង់អប់រំបច្ចុប្បន្នរបស់ក្រសួងអប់រំ យុវជន និងកីឡា ពាក់ព័ន្ធនឹងសាលារៀនជំនាន់ថ្មី។ ទស្សនកិច្ចនេះបានធ្វើឡើងនៅសាលាគំរូ ដែលជាសាលារៀនធម្មនុញ្ញទី១នៅកម្ពុជា។ គណៈប្រតិភូទស្សនកិច្ចសិក្សានេះដឹកនាំដោយ**ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ** ប្រធានគណៈកម្មការទី៧នៃរដ្ឋសភា។ នាយកសាលាអនុវត្ត **លោក សឿង វ៉ាន់** បានធ្វើបទបង្ហាញ ជូន គណៈប្រតិភូអំពីចក្ខុវិស័យរបស់ខេបក្នុងការបង្កើតសាលារៀនរដ្ឋស្វ័យតដែលយើងហៅថា សាលារៀនជំនាន់ថ្មី។ បទបង្ហាញនេះទទួលបានការយល់ដឹងជ្រួតជ្រាប និងគាំទ្រពីសមាជិកគណៈកម្មការមកពីគណបក្សនយោបាយទាំងពីរ។ ការលើកកម្ពស់ការយល់ដឹងអំពីសាលារៀនជំនាន់ថ្មីដោយក្រុមអ្នកបង្កើតគោលនយោបាយគឺមានសារៈសំខាន់ និងជាជោគជ័យរបស់ខេប និងជាសញ្ញាល្អឆ្លើយតបបានជោគជ័យក្នុងគម្រោងសាលារៀនជំនាន់ថ្មី។ ទស្សនកិច្ចសិក្សារបស់សមាជិកសភានេះត្រូវបានកត់ត្រាផ្សព្វផ្សាយនៅលើគេហទំព័រខេប: http://kapekh.org/?p=newsdetail&id=81&l=English#.VtlrG7QTHzL។

## ពិធីសម្ពោធគម្រោងសាលារៀនជំនាន់ថ្មីផ្លូវការគាំទ្រមូលនិធិដំបូងពីរាជរដ្ឋាភិបាល


ពិធីកាត់ខ្សែបូផ្លូវការៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងហិរញ្ញវត្ថុ ព្រមទាំងប្រធានសមាគមសាលាព្រះស៊ីសុវត្ថិ បានចូលរួមបើកសម្ពោធន៍គម្រោង សាលារៀនជំនាន់ថ្មីផ្លូវការនៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ។

ខេបបានរៀបចំសព្វគ្រប់ដើម្បីបើកសម្ពោធគម្រោងសាលារៀនជំនាន់ថ្មី ដែលគាំទ្រមូលនិធិដោយរដ្ឋាភិបាលទៅតាមកាលបរិច្ឆេទបើកសម្ពោធលើកទី២ក្នុងខែមេសា ឆ្នាំ២០១៦។ ពិធីសម្ពោធគម្រោងសាលារៀនជំនាន់ថ្មី ជាផ្លូវការនៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ នាថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១៦ ត្រូវបានអញ្ជើញចូលរួមពីភ្ញៀវកិត្តិយសំខាន់ៗជាច្រើនរួមមានៈ **ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) **ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន** (រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា) និង**ឯកឧត្តម ហ៊ុន ម៉ាណែត** (ប្រធានសមាគមអតីតសិស្សវិទ្យាល័យ ព្រះស៊ីសុវត្ថិ)។ ពិធីនេះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការផ្តល់ឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវប្រត្យក្សភាពរឹងមាំ ដែលការធ្វើវិនិយោគប្រាក់ពន្ធទៅក្នុងកំណែទម្រង់នៅកម្ពុជាតាមរយៈគម្រោងសាលារៀនជំនាន់ថ្មីគឺនាំឱ្យមានការផ្លាស់ប្តូរ មិនគ្រាន់តែក្នុងទម្រង់អប់រំប៉ុណ្ណោះទេ ប៉ុន្តែពោរពេញដោយខ្លឹមសារផងដែរ។ ពិធីនេះបង្ហាញពីភាពជោគជ័យដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាពគាំទ្រយ៉ាងខ្លាំងនូវសមិទ្ធផលដែលបានអនុវត្តក្នុងពេលដ៏ខ្លីកន្លងមក៕

## អង្គការ ខេប បានចុះកិច្ចព្រមព្រៀងថ្មីជាមួយវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនៅប្រទេសថៃ

លោក **សៅ វណ្ណា** ជានាយកប្រតិបត្តិអង្គការ ខេប និងកញ្ញា **ហ៊ឹម ម៉ារី** ជាប្រធានសម្របសម្រួលកម្មវិធីអប់រំបញ្ចូលគ្នា បានចុះកិច្ចព្រមព្រៀងទៅវិញទៅមកជាមួយសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ Sateuk ក្នុងប្រទេសថៃ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមួយចំនួនទៀត ដើម្បីឧបត្ថម្ភគាំទ្រអាហារូបករណ៍ដល់សិស្សកម្ពុជាដែលកំណត់ដោយអង្គការ ខេប ដើម្បីទៅសិក្សានៅសាលារៀនមួយចំនួននៅប្រទេសថៃ។ រាជរដ្ឋាភិបាលថៃឧបត្ថម្ភតម្លៃសិក្សា និងការស្នាក់នៅ ចំណែកអង្គការ ខេប ឧបត្ថម្ភលើតម្លៃអាហារ ការធ្វើដំណើរ ឯកសណ្ឋាន និងតម្លៃសិក្សាផ្សេងៗទៀត។ មានការរៀបចំពិធីតាំងបង្ហាញពហុបច្ចេកវិជ្ជាចម្រុះនៅទីក្រុងបាងកក ក៏ដូចជានៅតាមការចូលរួមពីវិទ្យាស្ថាននានានៃបណ្តាខេត្តដទៃៗទៀតដែរ។ ការចរចារធ្វើកិច្ចព្រមព្រៀងជាមួយសាលាអន្តរជាតិក្រៅពីប្រទេសកម្ពុជាគឺជាផលសម្រេចដ៏ធំរបស់អង្គការ ខេប ហើយនឹងលើកកម្ពស់ការខិតខំប្រឹងប្រែងរបស់អង្គការក្នុងការតស៊ូមតិរកឱកាសទទួលការអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់យុវជនកម្ពុជាដែលគ្មានលទ្ធភាពបន្តការសិក្សា៕


លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការ ខេប ធ្វើបទបង្ហាញនៅវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ Sateuk ក្នុងប្រទេសថៃ។

## សមិទ្ធផល និងការឯកភាពលើក្របខណ្ឌគោលនយោបាយសាលារៀនជំនាន់ថ្មី

ការធ្វើជាដៃគូថ្មីមួយជាមួយក្រសួងអប់រំ យុវជន និងកីឡា អង្គការ ខេប បានដឹកនាំធ្វើការអភិវឌ្ឍក្របខណ្ឌច្បាប់កំណត់អំពីសាលារៀនជំនាន់ថ្មី និងច្បាប់អភិបាលកិច្ចសាលារៀន និងវិធីប្រតិបត្តិក្របខណ្ឌច្បាប់អភិបាលកិច្ច។ ការឯកភាពលើកក្របខណ្ឌគោលនយោបាយនេះបានផ្តល់នូវមូលដ្ឋានច្បាប់សម្រាប់ឆ្លើយតបនឹងសាលារៀនជំនាន់ថ្មី ដែលជាវិធីមួយនឹងរក្សាបានអត្ថន័យឈ្មោះគម្រោងសាលារៀនជំនាន់ថ្មី។ នេះគឺជាលើកដំបូងដែលខេបតែងតែបានដឹកនាំអភិវឌ្ឍក្របខណ្ឌគោលនយោបាយជាមួយក្រសួងអប់រំ យុវជន និងកីឡា ហើយវាក៏ជាព្រឹត្តិការណ៍ដ៏សំខាន់នៃគម្រោងសាលារៀនជំនាន់ថ្មីរបស់ខេបផងដែរ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

គោលនយោបាយ
ស្តីពី
សាលារៀនជំនាន់ថ្មី

ខែកញ្ញា ឆ្នាំ២០១៦

## អង្គការ ខេប បើកដំណើរការសុសវែរសម្រាប់អំណានថ្នាក់ដំបូង ហៅថា សៀវភៅឆ្លាត

អំឡុងឆ្នាំនេះ ខេបសម្រេចបានការអភិវឌ្ឍសុសវែរថ្មី ដែលបង្កើតឡើងសម្រាប់បង្រៀនភាសាខ្មែរដល់កុមារតូចៗ។ សុសវែរនេះមានឈ្មោះថា ***សៀវភៅឆ្លាត*** ហើយគាំទ្រថវិកាពីអង្គការ **All Children Reading** ស្ថិតនៅក្នុងរដ្ឋធានីវ៉ាស៊ីងតោន។ សៀវភៅឆ្លាតគឺជាកម្មវិធី App ទូរសព្ទដៃជួយលើកកម្ពស់ប្រសិទ្ធភាពអំណានកុមារកម្ពុជា។ នេះគឺជាសៀវភៅអានបែបអេឡិចត្រូនិចដែលមូលដ្ឋានគ្រឹះផ្អែកលើសៀវភៅកម្មវិធីសិក្សារបស់ក្រសួង។ សុសវែរនេះមានប្រសិទ្ធភាពណាស់ព្រោះវាជាវិធីមួយដែលគេប្រើប្រាស់បានគ្រប់កាលៈទេសៈដើម្បីពង្រឹងកអំណានស្ទាត់ពួកគេ។ សៀវភៅឆ្លាតអេឡិចត្រូនិចធ្វើឱ្យសិស្សទទួលភាពជឿជាក់លើខ្លួនឯងតាមកម្រិតអំណានរបស់ពួកគេ។ ការប្រើប្រាស់រូបមន្តអំណានដោយផ្អែកលើបទពិសោធន៍ អង្គការ ខេប និងក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលអត្ថបទរឿងនិទានពីសៀវភៅសិក្សាថ្នាក់ជាតិមកជាសៀវភៅសិក្សាដោយបែងចែកកម្រិតពិបាកៗឱ្យមកជាអត្ថបទងាយស្រួលយល់។ នេះគឺជាព្រឹត្តិការណ៍អប់រំដ៏សំខាន់មួយនៅក្នុងប្រព័ន្ធអប់រំកម្ពុជា ដែលជាជំហានដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការប្តូរសៀវភៅសិក្សាមកជាទម្រង់អេឡិចត្រូនិច។ជាសំខាន់វាបង្កើតឱ្យមានសេចក្តីសម្រេចដូចគ្នាចំពោះភាគីដទៃទៀតធ្វើការជាមួយក្រសួងក្នុងការប្តូរសៀវភៅស្រដៀងគ្នានេះដែរ។ សៀវភៅឆ្លាតត្រូវបានអភិវឌ្ឍដោយក្រុមបច្ចេកទេសខេប និងអ្នកជំនាញផ្នែកភាសាខ្មែរមកពីក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ថ្នាក់ទី២ និងទី៣។ ពេលបន្ទាប់ ខ្លឹមសារត្រូវផ្តល់ឱ្យអ្នកបង្កើតសុសវែរឯករាជ្យដែលបានបញ្ចូលទៅជាសៀវភៅអេឡិចត្រូនិចតាមកិច្ចព្រមព្រៀង។


*សិស្សអាហារូបករណ៍អង្គការ ខេប សិក្សានៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈកសិកម្ម និងបច្ចេកវិទ្យា បូរីរ៉ាំ ប្រទេសថៃ ទទួលបានសញ្ញាបត្រ*

## សិស្សអាហារូបករណ៍ជំនាន់ទី១របស់ ខេប រៀននៅប្រទេសថៃទទួលបានសញ្ញាបត្រ

ក្នុងរយៈពេលពីរឆ្នាំកន្លងទៅ អង្គការ ខេប បានចុះកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំថៃដើម្បីជួយឧបត្ថម្ភគាំទ្រយុវជនកម្ពុជាតាមរយៈអង្គការ ខេប បានចុះឈ្មោះចូលសិក្សាតាមកម្មវិធីរយៈពេលពីរឆ្នាំនៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈកសិកម្ម និងបច្ចេកវិទ្យា បូរីរ៉ាម នៅភាគនិរតីប្រទេសថៃ។ ជាសរុប សិស្សចំនួន១១នាក់បានប្រឡងជាប់ ដែលគ្រប់គ្រងដោយរដ្ឋាភិបាលថៃ ហើយទទួលបានវគ្គបណ្តុះបណ្តាលលើកទឹកចិត្តរៀនភាសាថៃបន្ថែមមុនពេលពួកគេចូលសិក្សានៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈកសិកម្ម និងបច្ចេកវិទ្យា បូរីរ៉ាម។ រដ្ឋាភិបាលថៃជួយចេញតម្លៃសិក្សា និងការស្នាក់នៅ ចំណែកខេបចេញថ្លៃអាហារ ឯកសណ្ឋាន ទិដ្ឋាការ និងការធ្វើដំណើរ។ នៅក្នុងឆ្នាំ២០១៦ មានការរៀបចំកម្មវិធីសំខាន់មួយសម្រាប់ប្រគល់សញ្ញាបត្រ និងផ្តល់រង្វាន់ដល់សិស្សអាហារូបករណ៍ចំនួន១១នាក់ ដែលបានបញ្ចប់ការសិក្សាបញ្ញាបត្ររងផ្នែកសិល្បៈរយៈពេល២ឆ្នាំតាមមុខវិជ្ជាពួកគេ រួមមាន៖ វិស្វកម្មអេឡិចត្រូនិច ស្ថាបត្យកម្ម កសិកម្ម និងសណ្ឋាគារ។ បច្ចុប្បន្ន សិស្សអាហារូបករណ៍ក្នុងជំហានទី២ក៏បានទៅរៀននៅប្រទេសថៃក្នុងឆ្នាំ២០១៦ ដូចគ្នានឹងការរៀបចំក្នុងជំហានទី១ផងដែរ។

# ព័ត៌មាន និងព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ

*“ការអភិវឌ្ឍតាមរយៈបណ្ដាញ និងនៅថ្នាក់មូលដ្ឋាន ”*



*លោក សាយម៉ុន ប្រេង្ស៍ ជានាយកមូលនិធិ ប្រេង្ស៍ ហ្វេមីលី ពិភាក្សាអំពីការឆ្លើយតបកម្មវិធីសាលារៀនជំនាន់ថ្មីជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ។ មូលនិធិលោកនឹងផ្ដល់មូលនិធិ ៣០មុឺនដុល្លា ដើម្បីឧបត្ថម្ភគាំទ្រដល់អង្គការ ខេប និងក្រសួងអប់រំ យុវជន និងកីឡា សម្រាប់គម្រោងនេះ។*

## ខេបបានរៀបចំការប្រជុំរវាងមូលនិធិ Franks Family Foundation ជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីសាលារៀនជំនាន់ថ្មី

នៅខែឧសភា ឆ្នាំ២០១៦ ខេបបានរៀបចំការប្រជុំរវាងមូលនិធិ គ្រួសារហ្វ្រង់ ដែលជាម្ចាស់អំណោយថ្មីរបស់ខេបជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិភាក្សាអំពីសាលារៀនជំនាន់ថ្មី។ លោក សាយម៉ុន ហ្វ្រង់ ជានាយកមូលនិធិ គ្រួសារហ្វ្រង់ បានជួបជាមួយឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា (កម្ពុជា) ដើម្បីពិភាក្សាអំពីចក្ខុវិស័យសាលារៀនជំនាន់ថ្មី ដែលជាគម្រោងកំណែទម្រង់ថ្មីរបស់ក្រសួង។ គម្រោង សាលារៀនជំនាន់ថ្មីត្រូវបានចាប់ផ្ដើមសាកល្បងដោយអង្គការ ខេប ហើយបានទទួលស្គាល់ដោយក្រសួងសម្រាប់អនុវត្តឱ្យបានទូលំទូលាយនៅតាមសាលាដែលមានធនធានមនុស្សជាមូលដ្ឋានគ្រឹះ និងមានឆន្ទៈនយោបាយគាំទ្រគម្រោងនេះ។ លោក ហ្វ្រង់ និងរដ្ឋមន្ត្រីបានបង្ហាញនូវទស្សនៈរួមគ្នាលើវិធីផ្ដល់បរិស្ថានសិក្សាប្រកបដោយគុណភាពខ្ពស់ ផ្សារភ្ជាប់នឹងអភិបាលកិច្ចសាលារៀនរឹងមាំល្អ ដែលជាគោលការណ៍ស្នូលក្រោមការអភិវឌ្ឍសាលារៀនជំនាន់ថ្មី។ មូលនិធិ គ្រួសារហ្វ្រង់បានបន្តជួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ ខេប ក្នុងទឹកប្រាក់ ៣០មុឺនដុល្លា ដែលនឹងជួយបន្ថែមលើមូលនិធិបច្ចុប្បន្នក្នុងការឆ្លើយតបនឹងគម្រោង សាលារៀនជំនាន់ថ្មី នៅកម្ពុជា។ លោក ហ្វ្រង់ ក៏បានប្ដេជ្ញាចិត្តដើម្បីផ្សារភ្ជាប់អង្គការ ខេប និង ក្រសួងអប់រំ យុវជន និងកីឡា ផងដែរជាមួយម្ចាស់ជំនួយធំៗនៅចក្រភពអង់គ្លេស និងអឺរ៉ុប ដើម្បីផ្ដល់ហិរញ្ញប្បទានពេញលេញសម្រាប់គម្រោងទៅថ្ងៃអនាគត៕

## ខេបបានធ្វើបទបង្ហាញអំពីសុសវែរថ្មីរៀនភាសាខ្មែរ នៅសន្និសិទអង្គការ យូណេស្កូ ទីក្រុងប៉ារីស

លោក អ៊ុល រុន ទីប្រឹក្សាជាតិជាន់ខ្ពស់អង្គការ ខេប បានចូលរួមធ្វើបទបង្ហាញស្ដីពីគម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ នៅក្នុងកម្មវិធី **Mobile Learning Week** របស់អង្គការសហប្រជាជាតិ។ នេះគឺជាសន្និសិទប្រចាំឆ្នាំដ៏ធំមួយដែលមានអ្នកចូលរួមក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ និងម្ចាស់ជំនួយមកពីទូទាំងពិភពលោក។ លោក អ៊ុល រុន បានបង្ហាញអំពីការប្រឹងប្រែងរបស់អង្គការ ខេប ដើម្បីអភិវឌ្ឍសៀវភៅសិក្សាបែបអេឡិចត្រូនិចមានលក្ខណៈទាក់ទាញច្រើនដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា។ នេះគឺជាគ្រាដំបូងហើយដែលសៀវភៅសិក្សានៅកម្ពុជាត្រូវបានធ្វើទៅជាទម្រង់អេឡិចត្រូនិច និងក៏ជាការបោះជំហានធំមួយសម្រាប់កម្មវិធីសិក្សាថ្នាក់ជាតិ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងធ្វើការសាកល្បងក្នុងសាលារដ្ឋចំនួន១០ក្នុងប្រទេសកម្ពុជា។ ការធ្វើបទបង្ហាញនៅអង្គការយូណេស្កូ-ទីក្រុងប៉ារីស គឺដាក់ពាក្យជាប់ក្នុងចំណោមអ្នកដាក់ពាក្យមកពី ៣០០ស្ថាប័ន ដើម្បីឱ្យអង្គការ យូណេស្កូពិចារណាជ្រើសរើស។ អង្គការ ខេប មានកិត្តិយខ្ពង់ខ្ពស់ត្រូវបានធ្វើជាវាគ្មិនក្នុងចំណោមវាគ្មិនមកពី៤០ស្ថាប័នធ្វើបទបង្ហាញនៅក្នុងទីក្រុងប៉ារីស៕




*លោក អ៊ុល រុន ជាទីប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកអប់រំ បានធ្វើបទបង្ហាញអំពីកម្មវិធីសៀវភៅឆ្លាត នៅអង្គការយូណេស្កូ-ទីក្រុងប៉ារីស ប្រទេសបារាំង។*

## អង្គការ SEAMEO បានរៀបចំបណ្ដុះបណ្ដាលដល់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីក្នុងក្រុងកំពង់ចាម



*គ្រូបង្រៀនក្រុងកំពង់ចាមបានចូលរួមសិក្ខាសាលាស្ដីពីវិទ្យាសាស្ត្រនៅសាលារៀនជំនាន់ថ្មី (NGS)។*

នៅខែមីនា ឆ្នាំ២០១៦ មានគ្រូវិទ្យាសាស្ត្រ និងគណិតវិទ្យាចំនួន៣០នាក់បានចូលរួមសិក្ខាសាលាស្ដីពីការប្រើប្រាស់សុសវែរ **Edmodo** ដែលឧបត្ថម្ភដោយអង្គការអន្តរក្រសួងសម្រាប់ការអប់រំនៅអាស៊ីអាគ្នេយ៍ **(SEAMEO)**។ **Edmodo** ត្រូវបានបង្កើតឡើងដើម្បីជួយគ្រូបង្រៀនក្នុងតំបន់ដោយធ្វើការចែករំលែកបទពិសោធន៍ និងធនធានក្នុងការបង្រៀនវិទ្យាសាស្ត្រ និងគណិតវិទ្យា។ ដោយសារមានជំនាញផ្នែកបច្ចេកវិទ្យា សិក្ខាសាលានេះត្រូវបានរៀបចំដោយវិទ្យាល័យ ហ៊ុន សែន កំពង់ចាម (ដែលគេស្គាល់ទូទៅថា ជាសាលាអនុវត្តគឺជាសាលារៀនជំនាន់ថ្មីមួយរបស់អង្គការ ខេប)។ គ្រូទាំង៤សាលាក្នុងក្រុងកំពង់ចាមបានចូលរួមសិក្ខាសាលារៀនអំពីសុសវែរ និងការប្រើប្រាស់ **Edmodo**។ ក្នុងសិក្ខាសាលានេះគេរកឃើញថា ៧៥% នៃគ្រូក្នុងក្រុងកំពង់ចាមលើកលែងតែគ្រូសាលាអនុវត្ត គ្មានបទពិសោធន៍ប្រើប្រាស់អ៊ីមែល ដែលជាក្ដីបារម្ភក្នុងការលើកកម្ពស់កម្មវិធីអង្គការ **SEAMEO**។ ផ្ទុយទៅវិញ រាល់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីមានកុំព្យូទ័រយួរដៃម្នាក់១គ្រឿងពេលមកសាលា។ ដូច្នេះ ពួកគេមានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័តិមានវិទ្យាខ្ពស់បើធៀបនឹងសាលាដទៃទៀតក្នុងក្រុង។




*លោក ឃីត វ៉ែប៊ែរមិនប៊ែក ជាទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់អង្គការ ខេប បានធ្វើបទបង្ហាញអំពីផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ អំឡុងពេលប្រជុំប្រចាំឆ្នាំ*

## ខេបបានរៀបចំប្រជុំបុគ្គលិកប្រចាំឆ្នាំ

អង្គការ ខេប បានបន្តរៀបចំព្រឹត្តិការណ៍មួយដើម្បីប្រជុំបុគ្គលិករបស់ខ្លួនប្រចាំឆ្នាំនៅខែមេសា ឆ្នាំ២០១៦។ ការប្រជុំនេះផ្តោតទៅលើការពិនិត្យតាមដានគម្រោងចំនួន ១៥ ដែលខេបកំពុងអនុវត្តនៅឆ្នាំនេះ និងធ្វើឱ្យបុគ្គលិកមានភាពស្និទ្ធស្នាលនឹងគ្នា ហើយស្វែងយល់អំពីទំហំកម្មវិធីអង្គការ និងមេរៀនពិសោធន៍មួយចំនួន។ ការប្រជុំនេះក៏ផ្តោតលើការខិតខំប្រឹងប្រែងតម្រង់ទិសបុគ្គលិកឱ្យយល់ប្រសើរឡើងអំពីផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ដែលមានសកម្មភាពរៀបចំពីគ្រប់គម្រោងទាំងអស់។ ដើម្បីអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល អង្គការ ខេប បានផ្តល់ឱកាសដល់បុគ្គលិកពាក់ព័ន្ធចូលរួមលើកកម្ពស់ប្រតិបត្តិការអង្គការទាក់ទងនឹងការផ្តល់សេវា ប្រព័ន្ធរដ្ឋបាល និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ការប្រជុំនេះបានផ្តល់ជាវេទិកាមួយល្អសម្រាប់បុគ្គលិកទូទាំងប្រទេសជួបជុំពិភាក្សា និងចែករំលែកពីកម្មវិធីរបស់ពួកគេក្នុងបរិយាកាសសប្បាយ និងលំហែពីការងារ៕

## ខេបបានធ្វើបទបង្ហាញនៅក្នុងសន្និសិទស្តីពីការបណ្តុះបណ្តាលអប់រំ និងបច្ចេកវិទ្យានៅសិង្ហបុរី

អង្គការ ខេប ត្រូវបានអញ្ជើញចូលរួមធ្វើបទបង្ហាញនៅក្នុងសន្និសិទស្តីពីការបណ្តុះបណ្តាលអប់រំ និងបច្ចេកវិទ្យាក្នុងប្រទេស សិង្ហបុរី ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥។ លោក អ៊ុល រុន ជាទីប្រឹក្សាជាតិជាន់ខ្ពស់បានធ្វើបទបង្ហាញអំពីអង្គការ ខេប ដោយផ្តោតលើការខិតខំប្រឹងប្រែងក្នុងប្រទេសកម្ពុជាដើម្បីផ្សារភ្ជាប់គម្លាតរវាងសមធម៌ និងឧត្តមភាពអប់រំ ទោះបីមានការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗក៏ដោយ។ អង្គការ ខេប បានចូលរួមធ្វើជាវាគ្មិនពិភាក្សាជាច្រើននៅសន្និសិទនេះ និងបានធ្វើការទាក់ទងជាមួយក្រុមហ៊ុនពីរដើម្បីធ្វើសមាហរណកម្មសុសវែរថ្នាក់ពិភពលោកបញ្ចូលទៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី។ កម្មវិធីសុសវែរទាំងនេះគឺមាន **3DClassroom** និង **Literatu** និងជាកម្មវិធីសុសវែរទំនើប ដែលជួយនាំសាលារដ្ឋទៅក្នុងសតវត្សរ៍ទី២១បាន៕







## ប្រធានគម្រោងអង្គការ ខេប ទទួលបានអាហារូបករណ៍ក្នុងកម្មវិធីអ្នកដឹកនាំវ័យក្មេងនៅអាស៊ីអាគ្នេយ៍

ដោយការបង្ហាញពីសមត្ថភាពខ្ពស់របស់បុគ្គលិក ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិកបានផ្តល់អាហារូបករណ៍ដល់ប្រធានគម្រោងរបស់អង្គការ ខេប ម្នាក់ក្រោមកម្មវិធីអ្នកដឹកនាំវ័យក្មេងនៅអាស៊ីអាគ្នេយ៍ ដែលជាកម្មវិធីពិសេសមួយផ្តួចផ្តើមដោយលោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា ដើម្បីលើកកម្ពស់ និងលើកទឹកចិត្តអ្នកដឹកនាំវ័យក្មេងនៅក្នុងប្រទេសអាស៊ាន។ លោក ផាន់ ប៊ុនណាត ប្រធានគម្រោងការផ្តល់សិទ្ធិអំណាចយុវជនតាមរយៈការអប់រំ និងការតស៊ូមតិ **(EYEA)** គឺជាអ្នកទទួលអាហារូបករណ៍ម្នាក់មកពីប្រទេសកម្ពុជាក្នុងឆ្នាំ២០១៥ ក្នុងចំណោមយុវជនដាក់ពាក្យរាប់រយនាក់។ លោក ផាន់ ប៊ុនណាត បានចំណាយពេល ៥ សប្តាហ៍សិក្សាអំពីភាពជាអ្នកដឹកនាំ និងការអប់រំនៅមូលនិធិ **The Maureen and Mike Mansfield Center** នៃសាកលវិទ្យាល័យ **Montana** និងមួយសប្តាហ៍ជួបជាមួយមេដឹកនាំនយោបាយសំខាន់ៗនៅក្នុងរដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី ក្នុងខែតុលា-វិច្ឆិកា ឆ្នាំ២០១៥។ នៅពេលត្រឡប់មកវិញ លោក ប៊ុនណាត បានចូលរួមក្នុងគម្រោង សាលារៀនជំនាន់ថ្មី ដើម្បីអនុវត្តបទពិសោធន៍ល្អៗមួយចំនួនពីសហរដ្ឋអាមេរិកមកជួយបង្កើតគម្រោងថ្មី ដែលទទួលមូលនិធិពីក្រសួងអប់រំ យុវជន និងកីឡា៕

# បច្ចុប្បន្នភាព ធនធានសិក្សា-ខេប

"សម្ភារៈជំនួយការសិក្សាដែលមានប្រសិទ្ធភាព និងតម្លៃសមរម្យ"

## សេចក្តីសង្ខេប

### អំពីធនធានសិក្សា

ធនធានសិក្សាខេបគឺជាសហគ្រាសសង្គមមួយដែលបានបង្កើតឡើងដោយអង្គការ ខេប និង ដំណើរការដោយឯករាជ្យ មានគោលបំណងលើកកម្ពស់ការផលិតសម្ភារៈបង្រៀន និងរៀនទាំងនៅក្នុង និងក្រៅថ្នាក់រៀន។



### ផលិតផល

**សម្ភារៈបង្រៀន:**

| | |
|---|---|
| គណិតវិទ្យា | ១១មុខ |
| ភាសាខ្មែរ | ២៩មុខ |
| វិទ្យាសាស្ត្រ | ២មុខ |
| តេស្តវាយតម្លៃថ្នាក់ទី ១-៣ | |

### ការតម្រង់ទិស

ធនធានសិក្សាផ្តល់វគ្គតម្រង់ទិសដោយឥតគិតថ្លៃអំពីការប្រើប្រាស់សម្ភារៈបង្រៀនដល់គ្រូ និងអ្នកស្ម័គ្រចិត្តបង្គោល ដែលមានអ្នកចូលរួមចំនួន ១.២២០នាក់។

ផ្គត់ផ្គង់គ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជា

\+ ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ ១០% ត្រូវបានបរិច្ចាគទៅក្នុងការងារមនុស្សធម៌។



### ចំណូលពីការលក់សរុប ៣៥.៧០០៨ដុល្លារអាមេរិក






### ប្រាក់ចំណេញសុទ្ធ និងការវិនិយោគ: ១១៤.៧៤១ ដុល្លាអាមេរិក

ធនធានសិក្សាដំណើរបានយ៉ាងជោគជ័យក្នុងឆ្នាំ២០១៦ និងសូមថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍន៍ និងអតិថិជននៅទូទាំងប្រទេសកម្ពុជា។ ធនធានសិក្សាទទួលបានទឹកប្រាក់ចំណេញសុទ្ធជាង ១១៤.000 ដុល្លាអាមេរិក ដោយបានវិនិយោគច្រើនបំផុតក្នុងការបោះពុម្ពសម្ភារៈបង្រៀន និងរៀន ព្រមទាំងការអភិវឌ្ឍផលិតផលថ្មីៗ។ ថវិកានេះក៏បានចូលរួមបន្តនិរន្តរភាពសមិទ្ធផលគម្រោងតូចៗដែលបានបញ្ចប់៕

សូមមើលព័ត៌មានលម្អិតបន្ថែមនៅលើគេហទំព័រធនធានសិក្សា: ***www.tts-kape.org***
និងចុច *"LIKE"* និងចុច *"Share"* បណ្តាញសង្គម *Facebook* របស់យើង: ***www.facebook.com/ttskape***។

# គម្រោង សាលារៀនដៃគូ (BSI)

## "សាលារៀនរដ្ឋដែលមានស្តង់ដារឯកជន"

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការអ្នកទ្រី, មូលនិធិ Breteau, ក្រុមហ៊ុន Apple Corporation |
| អ្នកទទួលផលផ្ទាល់ | សិស្សបឋម និងមធ្យមសិក្សាចំនួន ១.៨៦៥ (ស្រី ៩៥៦នាក់) |
| ថវិកាទទួលបានក្នុងឆ្នាំ ២០១៦ | ៧៤.៧៦៩ ដុល្លាសហរដ្ឋអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ៤០,០៩ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ២ ខេត្ត (កំពង់ចាម និងត្បូងឃ្មុំ) |
| ចំនួនស្រុកគ្របដណ្តប់ | ៣ ស្រុក (កំពង់ចាម ជើងព្រៃ និងត្បូងឃ្មុំ) |
| មធ្យមសិក្សាគោលដៅ | ៣ (វិ. ហ៊ុន សែន កំពង់ចាម វិ.ហ៊ុន សែន ស្គន់ និងវិ. សម្តេចម៉ែ) |
| បឋមសិក្សាគោលដៅ | សាលាបឋមសិក្សាអនុវត្ត ហ៊ុន សែន |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មករា ២០១១ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ កញ្ញា ២០១៦ |

## គោលបំណង

គម្រោងសាលារៀនដៃគូព្យាយាមបង្កើតឱ្យបានគំរូអភិវឌ្ឍន៍ពហុជម្រើសក្នុងសាលារៀនរដ្ឋ ដោយផ្អែកលើលក្ខណៈអំណោយផលរបស់សាលាក្នុងការប្រើប្រាស់ជំនួយបច្ចេកទេស។ គម្រោងមិនមែនត្រឹមតែផ្តល់ជំនួយបច្ចេកទេសដ៏ល្អពេញលេញដល់សាលាដែលត្រូវបានជ្រើសរើសផ្អែកលើសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែក៏បានផ្តោតលើរចនាសម្ព័ន្ធអភិបាលកិច្ច ជំនាញ ដែលធានាឱ្យការប្រើប្រាស់ធនធាន ថវិកាឧបត្ថម្ភគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព និងមានគណនេយ្យភាពអាស្រ័យភារកិច្ចបន្ថែមដែលគ្រូបង្រៀនបានបំពេញ (ឧ.ការរៀបចំការងារគម្រោង ជាពិសេស ពាក់ព័ន្ធនឹងការសិក្សាបែបស្ថាបនា ការផ្តល់ប្រឹក្សាអាជីព និងក្លឹបសិក្សា។ល។ វិធីអភិវឌ្ឍន៍ទាំងពីរគន្លងនេះបង្ហាញពីគំរូនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងការគ្រប់គ្រងសាលារៀនរដ្ឋទាំងបី ដែលគម្រោងបាន និងកំពុងអនុវត្តសាកល្បងនូវគំរូថ្មីនេះ។

## បច្ចុប្បន្នភាពគម្រោង

ការអនុវត្តគម្រោងសាលារៀនដៃគូដំណាក់កាលទី២ រយៈពេល២ឆ្នាំ បានឈានដល់ទីបញ្ចប់ក្នុងខែកញ្ញា ឆ្នាំ២០១៦។ ជាមួយនឹងគោលដៅពង្រីកគំរូសាលារៀនជំនាន់ថ្មី ព្រមទាំងបង្ហាញលទ្ធភាពនៃការចម្លងតាមគំរូនេះយកទៅអនុវត្តបន្ត គម្រោងសាលារៀនដៃគូបានដើរតួនាទីជាស្ពានយ៉ាងសំខាន់សម្រាប់ដំណាក់កាលថ្មីមួយនៃការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី។ ការផ្តល់ថវិកាដំណាក់កាលទី២ បានធ្វើឱ្យខ្លឹមនៃគម្រោងសាលារៀនដៃគូមានស្ថេរភាពក្នុងកាលៈទេសៈមួយ ដែលគម្រោងឈានដល់វិសាលភាពដ៏ធំធេង។ ដោយសារតែដំណាក់កាលទី២ចាប់ផ្តើមក្នុងឆ្នាំ២០១៤ ដែលបរិបទអប់រំមានការផ្លាស់ប្តូរយ៉ាងខ្លាំង ដោយមានការដាក់បញ្ចូលគំរូសាលារៀនជំនាន់ថ្មីទៅក្នុងកម្មវិធីកំណែទម្រង់ផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា (ចំណុចទី១៤)។ តាំងពីពេលនោះមក គំរូនេះបានទទួលការគាំទ្រហិរញ្ញវត្ថុយ៉ាងសំខាន់ពីក្រសួងអប់រំ យុវជន និងកីឡាផ្ទាល់ (ប្រមាណ ១,៩ លានដុល្លាអាមេរិករហូតមកទល់ពេលនេះ) ព្រមជាមួយនឹងដៃគូអភិវឌ្ឍន៍ដទៃទៀត រួមទាំងអង្គការឆាលហ្វាន ប្រទេសអូស្ត្រាលី (៣០០,០០០ដុល្លា) និងមូលនិធិ **Frank Family Foundation** (៣០០,០០០ដុល្លា)។ ដូចនេះ ការវិនិយោគរបស់អ្នកទ្រីមិនត្រឹមតែនាំទៅដល់ការបង្កើតបាននូវគំរូអភិវឌ្ឍន៍ថ្មីមួយសម្រាប់ប្រទេសកម្ពុជាប៉ុណ្ណោះទេ តែវាបានប្រែក្លាយពន្លកនៃការគាំទ្រហិរញ្ញវត្ថុដំបូងឱ្យក្លាយជាការគាំទ្របន្ថែមទំហំរាប់លានដុល្លាអាមេរិក។ ខណៈដែលគម្រោងសាលារៀនដៃគូឈានដល់ទីបញ្ចប់ ក្រសួងបានអនុម័តជាផ្លូវការនូវគោលនយោបាយសាលារៀនជំនាន់ថ្មីកាលពីខែកញ្ញា ឆ្នាំ២០១៦ ដែលបានធ្វើឱ្យវិធីសាស្ត្រសាកល្បងដោយអ្នកទ្រីក្លាយជាផ្នែកមួយនៃក្របខណ្ឌកម្មវិធីអប់រំផ្លូវការរបស់កម្ពុជា។ នេះជាសមិទ្ធផលវិនិយោគដ៏ធំធេងរបស់អ្នកទ្រី ដែលហួសពីក្តីរំពឹងទុករបស់កម្មវិធី បើក្រឡេកទៅមើលដំណាក់កាលចាប់ផ្តើមក្នុងឆ្នាំ២០១១។

## សកម្មភាពសំខាន់ៗ

- ពង្រឹងសេវាពិសេសសម្រាប់សិស្ស រួមមាន៖ កម្មវិធីអប់រំបំណិនជីវិត ការប្រឹក្សាយោបល់ និងបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការអប់រំ។
- ពង្រីកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការអប់រំ រួមមាន៖ ការបង្ហាញកម្មវិធីសុសវែរអប់រំកម្រិតពិភពលោក និងការរៀបចំសុសវែរអប់រំថ្មីៗជាភាសាខ្មែរ។
- ពង្រឹងការបង្កើតចំណូលក្នុងមូលដ្ឋានសាលារៀន ដើម្បីធ្វើឱ្យកម្មវិធីកាន់តែមាននិរន្តរភាព។
- បង្កើនសមត្ថភាពគ្រូបង្រៀនដើម្បីកែសម្រួលការបង្រៀនសម្រាប់លើកកម្ពស់ជំនាញទន់ដែលត្រូវការចាំបាច់នៅក្នុងសតវត្សរ៍ទី២១នេះ ដូចជាការគិតពិចារណាស៊ីជម្រៅ ការងារក្រុម និងការច្នៃប្រឌិត។

## រូបភាពសកម្មភាព



បរិស្ថានសិក្សាក្នុងសតវត្សរ៍ទី២១ដែលបានកែសម្រួលៈ កុមារនៅសាលាមានបន្ទប់រៀនទំនើបទាន់សម័យ ហើយបណ្ណាល័យបំពាក់ទៅដោយឧបករណ៍សិក្សាចល័តបានយ៉ាងស្រួល។



គ្រូបង្រៀនពិសោធន៍វិធីសាស្ត្របង្រៀនថ្មីៗៈ គ្រូនៅសាលារៀនជំនាន់ថ្មីត្រូវបានលើកទឹកចិត្តឱ្យសាកល្បងនូវវិធីសាស្ត្របង្រៀនថ្មីៗ រួមមានការនាំកុមារទៅកន្លែងមានបរិស្ថានធម្មជាតិ ដើម្បីលើកកម្ពស់គំនិតនិងការច្នៃប្រឌិតថ្មី។



សិស្សអនុវត្តការពិសោធផ្ទាល់ដៃៈ មុខវិជ្ជាស្តែមមានសារៈសំខាន់ណាស់នៅក្នុងសាលារៀនដៃគូដែលឈានទៅបង្កើនការប្រើប្រាស់បន្ទប់ពិសោធន៍ និងវិធីសាស្ត្របង្រៀនថ្មីបែបសកម្ម។

# ១២ គម្រោង សាលារៀនជំនាន់ថ្មី (NGS)

*" ជាសាលាធម្មនុញ្ញទី១នៅក្នុងប្រទេសកម្ពុជា "*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | ក្រសួងអប់រំ យុវជន និងកីឡា |
| អ្នកទទួលផលផ្ទាល់ | ៩៣៥ នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ ២០១៦ | ៩៤៨.៧៦៩ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ១.០៣១,៦៥ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | រាជធានីភ្នំពេញ |
| ចំនួនស្រុកគ្របដណ្តប់ | ១ (ខណ្ឌដូនពេញ) |
| មធ្យមសិក្សាគោលដៅ | ១ (វិទ្យាល័យ ព្រះស៊ីសុវត្ថិ) |
| បឋមសិក្សាគោលដៅ | គ្មាន |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ តុលា ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | បើកចំហរ (មិនកំណត់) |

## បច្ចុប្បន្នភាពគម្រោង

ដោយមានការរៀបចំបង្កើតគោលនយោបាយសាលារៀនជំនាន់ថ្មីជាគោលនយោបាយផ្លូវការ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ ខេប បានធ្វើកិច្ចព្រមព្រៀងជាប្រវត្តិសាស្រ្តមួយដើម្បីផ្តល់មូលនិធិផ្ទាល់ដល់អង្គការ ខេប ដើម្បីអនុវត្តគំរូសាលារៀនជំនាន់ថ្មីនៅក្នុងទីតាំងថ្មីៗទៀត។ ការអភិវឌ្ឍនេះគឺជាលើកដំបូងហើយដែលក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់មូលនិធិដល់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដើម្បីអនុវត្តកម្មវិធីកំណែទម្រង់ដ៏សំខាន់។

ក្នុងឆ្នាំនេះដោយមានការបង្រួមបញ្ចូលកម្មវិធីជាច្រើនរបស់សាលារៀនជំនាន់ថ្មីទៅជាកម្មវិធីតែមួយដោយមានសហដៃគូជំនួយពីប្រភពមួយចំនួនព្រមទាំងក្រសួង។ ក្នុងន័យនេះ គម្រោងសាលារៀនដៃគូ (គាំទ្រដោយអង្គការមូលនិធិអូកទ្រី) និងគម្រោងក្រសួងបានរួមបញ្ចូលទៅជាគម្រោងតែមួយមានឈ្មោះថា គម្រោងសាលារៀនជំនាន់ថ្មី។ ទោះបីជាការផ្តល់មូលនិធិអង្គការមូលនិធិអូកទ្រីបានបញ្ចប់ក្នុងឆ្នាំ២០១៦ក៏ដោយ យើងក៏មានម្ចាស់ជំនួយមួយទៀតឈ្មោះថា មូលនិធិ ប្រេហ្ស៊ី ហ្វេមីលី (FFF) ដែលនឹងផ្តល់ហិរញ្ញប្បទានគាំទ្រជាសហដៃគូជំនួយជាមួយការខិតខំរបស់ក្រសួងសម្រាប់ឆ្លើយតបបន្ថែមទូលំទូលាយទៀតក្នុងគំរូនេះ។

ការវិវត្តដ៏សំខាន់ក្នុងឆ្នាំនេះគឺការសម្រេចបាននូវគោលនយោបាយថ្នាក់ជាតិស្តីពីការអនុវត្តសាលារៀនជំនាន់ថ្មី ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងខែកញ្ញា ឆ្នាំ២០១៦។ អង្គការ ខេប ក៏បានជួយរៀបចំបង្កើតគោលការណ៍ណែនាំប្រតិបត្តិការសាលារៀនជំនាន់ថ្មីដល់ក្រសួងផងដែរ ដែលកំណត់និយមន័យយ៉ាងច្បាស់របស់ NGS និងអាចឱ្យម្ចាស់ជំនួយដទៃទៀតយកទៅអនុវត្តដោយមិនឱ្យខុសទៅនឹងន័យរបស់សាលារៀនជំនាន់ថ្មី។ មានគោលការណ៍ណែនាំ និងឧបករណ៍សមស្របជាង៩០មុខត្រូវបានរៀបចំឡើងនៅក្នុងគម្រោងនេះ។

គម្រោងសាលារៀនជំនាន់ថ្មីសម្រេចបានការអភិវឌ្ឍគំរូសាលាក្នុងសាលានៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ ដែលជាសាលាមានបញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ចរបស់ខ្លួន។ បច្ចុប្បន្ននេះ វាជាសាលារៀនមួយមានអភិបាលកិច្ចល្អ និងស្តង់ដាអប់រំខ្ពស់ ដែលបានលុបបំបាត់រាល់ទម្រង់បង្រៀនឯកជនក្រៅផ្លូវការ (បង្រៀនគួ) និងសេវាកម្មក្រៅផ្លូវការផ្សេងៗទៀត។ កម្មវិធីបានជ្រើសរើសគ្រូបង្រៀនថ្មីៗដោយមានការប្រកួតប្រជែង និងមានសមត្ថភាពល្អតាមវិជ្ជាជីវៈ និងបានបំពេញការងារល្អប្រសើរឆ្លើយតបនឹងស្តង់ដាអប់រំសតវត្សរ៍ទី២១ ក្នុងសាលារដ្ឋ៕

## សន្និដានភាពនៃកម្មវិធី

សាលារៀនជំនាន់ថ្មីគឺជាកំណែទម្រង់ថ្មីមួយ ដែលត្រូវបានសម្ភោធន៍ឱ្យដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡានៅក្នុងឆ្នាំ ២០១៤ ដើម្បីបង្កើតសាលារៀនរដ្ឋស្វ័យតដោយមានកព្វកិច្ចក្នុងការច្នៃប្រឌិតថ្មី និងលើកកម្ពស់គុណភាពអប់រំ។ ការវិនិយោគថវិកាកម្រិតខ្ពស់នេះគឺពឹងផ្អែកលើស្តង់ដាអភិបាលកិច្ច និងវិជ្ជាជីវៈខ្ពស់។ ដំណើរការអភិវឌ្ឍកម្មវិធីនេះគឺព្យាយាមធ្វើឱ្យសាលារៀនរដ្ឋទៅកម្រិតមួយទៀត ដែលអាចទទួលបានស្តង់ដាអប់រំអតិបរិមា ជាពិសេស មុខវិជ្ជាស្ទែម (STEM)។ ក្រោមគោលនយោបាយថ្មី កម្មវិធីសាលារៀនជំនាន់ថ្មី រដ្ឋាភិបាលអាចវិនិយោគទៅលើសាលារៀនជាច្រើនក្រោមលក្ខខណ្ឌធ្វើឱ្យមានស្តង់ដាខ្ពស់អភិបាលកិច្ចល្អ។ ប្រព័ន្ធនេះតម្រូវឱ្យមានការទទួលស្គាល់គុណភាពតឹងរឹងបំផុតដែលផ្សារភ្ជាប់នឹងការវិនិយោគបន្ត គោលនយោបាយថ្មីនេះជំរុញឱ្យសាលារៀនប្រកាន់ខ្ជាប់នូវស្តង់ដាអប់រំខ្ពស់។ សាលារៀនជំនាន់ថ្មីយកលំនាំតាមបទពិសោធន៍ពីប្រទេសដទៃៗទៀត ដែលមានសាលារៀនរដ្ឋទទួលបានស្វ័យភាពល្អពីរដ្ឋដើម្បីជំរុញការអប់រំប្រកបដោយភាពច្នៃប្រឌិតខ្ពស់។ នេះចង់សំដៅទៅលើការវិវត្តសាលារៀនធម្មនុញ្ញ៕

## សកម្មភាពសំខាន់ៗ

- ការរៀបចំគោលនយោបាយសម្រាប់សាលារៀនធម្មនុញ្ញនៅកម្ពុជាដោយជោគជ័យ
- ការសាកល្បងនូវមូលនិធិសមធម៌សង្គមនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដែលបង្កលក្ខណៈឱ្យសិស្សក្រីក្រអាចចូលរៀនបាន
- ការសាកល្បងគំរូសាលាក្នុងសាលានៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ ដោយជោគជ័យ
- ការលុបបំបាត់សេវាគ្រូបង្រៀនឯកជនក្រៅផ្លូវការបានចំនួន ២សាលា
- ការពង្រីកសេវាកម្មសាលារៀនជំនាន់ថ្មីនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម
- ការរៀបចំ និងការអនុវត្តនូវសម្ភារៈបរិក្ខាអប់រំបែបសតវត្សរ៍ទី២១ រួមមាន៖ បន្ទប់វិទ្យាសាស្រ្ត ចំនួន ៦ បណ្ណាល័យសតវត្សរ៍ទី២១ និងបន្ទប់កុំព្យូទ័រចំនួន ២
- ការសម្រេចបានការស្ទង់មតិថ្នាក់ជាតិដើម្បីកំណត់យកទីតាំងថ្មីចំនួន ១០សាលា ដែលមានសក្តានុពលឆ្លើយតបរហ័សសម្រាប់ការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី។



សិស្សវិទ្យាល័យ ព្រះស៊ីសុវត្ថិ ធ្វើពិសោធវិភាគត្រីដើម្បីសិក្សាអំពីគ្រឿងក្នុងរបស់ត្រីនៅក្នុងថ្នាក់មុខវិជ្ជាជីវៈវិទ្យារបស់ពួកគេ។

## រូបភាពសកម្មភាព



← រដ្ឋមន្ត្រីក្រសួងអប់រំ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងឯកឧត្តម ហ៊ុន ម៉ាណែត កាត់ខ្សែបូ សម្ពោធគម្រោង សាលារៀនជំនាន់ថ្មីនៅវិ.ព្រះស៊ីសុវត្ថិ ជាសាលារៀនទី១ ក្នុងចំណោមសាលារៀនជំនាន់ថ្មីក្នុងផែនការ សម្រាប់រាជធានីភ្នំពេញ។

ការរៀបចំគោលការណ៍ណែនាំគោលនយោបាយសាលារៀនជំនាន់ថ្មីត្រូវបានរៀបចំឡើងដោយអង្គការ ខេប ជាមួយក្រសួងអប់រំ ដើម្បីឆ្លើយតបយ៉ាងរហ័សក្នុងការអនុវត្តគម្រោងសាលារៀនជំនាន់ថ្មី។ ការឯកភាពគ្នាលើក្របខណ្ឌគោលនយោបាយនេះបង្ហាញពីការប្តេជ្ញាចិត្តពេញលេញរបស់ក្រសួងចំពោះកំណែទម្រង់ ហើយនឹងជួយម្ចាស់ជំនួយដទៃទៀតឱ្យធ្វើការងារក្នុងប៉ារ៉ាម៉ែត្រត្រឹមត្រូវ ដែលនឹងមិនធ្វើឱ្យគុណភាពកម្មវិធីសាលារៀនជំនាន់ថ្មីថមថយនៅថ្ងៃអនាគត។ →


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងអប់រំ យុវជន និងកីឡា
គោលនយោបាយ
ស្តីពី
សាលារៀនជំនាន់ថ្មី
ខែកញ្ញា ឆ្នាំ២០១៦



### បរិក្ខាទំនើបៗមានបន្ទាញនៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ

វិ. ព្រះស៊ីសុវត្ថិ គឺជាសាលាដែលមានវ័យចំណាស់ជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ បរិក្ខាសល់ពីសតវត្សរ៍ទី១៩ គាំទ្រតិចតួចចំពោះការសិក្សានៅក្នុងសតវត្សរ៍ទី២១នេះ។ អង្គការ ខេប បានសម្រេចជួសជុលកន្លែងសិក្សាឡើងវិញនៅក្នុងសាលាប ហើយង្កើតបានជាបណ្ណាល័យរដ្ឋបែបអេឡិចត្រូនិច (រូបខាងឆ្វេង) ដែលមានការរៀបចំពណ៌បន្ទប់ទាក់ទាញ និងបន្ទប់វិទ្យាសាស្ត្រទំនើប (រូបខាងក្រោម)។ គ្រូបង្រៀនម្នាក់ៗទទួលបានកុំព្យូទ័រយួរដៃមួយគ្រឿង និងសុសវែរកម្រិតថ្នាក់ពិភពលោកសម្រាប់បង្រៀនសិស្សនៅទីនេះ៕





សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់ចាម បានដាក់តាំងស្នាដៃគម្រោងដែលពួកគេធ្វើឡើងរួចរាល់នៅក្នុងការពិពណ៌ ក្នុងកម្មវិធីដែលរៀបចំឡើងដោយសិស្សសាលា។

សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់ចាម បានចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់ក្រុមពួកគេនៅក្នុងបណ្ណាល័យសតវត្សរ៍ទី២១។ →

## លក្ខណៈកម្មវិធី




### សាលាសម្រាប់អ្នកជំនាន់ថ្មី....

### សេវាផ្តល់សិទ្ធិអំណាចយុវជន

គោលការណ៍ផ្តល់សិទ្ធិអំណាចយុវជន គឺមានកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍យុវជនជាតិកម្ពុជារបស់ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីយ៉ាងសំខាន់ជាគំរូសាលារៀនជំនាន់ថ្មី។ គោលការណ៍ផ្តល់សិទ្ធិអំណាចយុវជនបង្ហាញពីការជ្រើសរើសរបស់សិស្សចំពោះមុខវិជ្ជាដែលពួកគេចង់រៀន សមាជិកក្លឹបសិក្សាស្ម័គ្រចិត្ត និងការផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាកុមារ/យុវជនដែលជួយគ្រប់គ្រងកម្មវិធី។ សេវាប្រឹក្សាអាជីពផ្តល់ឱ្យយុវជនដើម្បីធានាថាការសម្រេចចិត្តរបស់គេ និងមានព័ត៌មានត្រឹមត្រូវគ្រប់គ្រាន់។

### សេវាពិសេសសម្រាប់សិស្ស

សាលារៀនជំនាន់ថ្មីផ្តល់សេវាថ្មីៗដល់សិស្សដែលមិនធ្លាប់មាននៅក្នុងសាលារដ្ឋដូចជាៈ

បណ្ណាល័យអេឡិចត្រូនិចសតវត្សរ៍ទី២១ - សេវាប្រឹក្សាយោបល់ - ក្លឹបមុខវិជ្ជា - ការអប់រំកម្មវិធីបំណិនជីវិត - ការវាយតម្លៃតាមប្រព័ន្ធអេឡិចត្រូនិច - សុសវែរសម្រាប់ការសិក្សា៕

# ១៤ គម្រោង លើកកម្ពស់សេវាកម្មសុខភាពសាលារៀន (ISHS)

“ ធ្វើឱ្យសាលាមានសេវាសុខភាព ”

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | មូលនិធិ Breteau |
| អ្នកទទួលផលផ្ទាល់ | សិស្ស ១.៧៦៥ នាក់ (ស្រី ៨៥៤ នាក់) |
| ថវិកាទទួលបានក្នុងឆ្នាំ ២០១៦ | ៧.៤១០ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ៤,២០ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ១ (កំពង់ចាម) |
| ចំនួនស្រុកគ្របដណ្តប់ | ១ (ជើងព្រៃ) |
| មធ្យមសិក្សាគោលដៅ | ១ (វិ. ហ៊ុន សែន សួន់) |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មករា ២០១៣ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ កញ្ញា ២០១៧ |

## បច្ចុប្បន្នភាពគម្រោង

បន្ទប់សង្គ្រោះបឋមថ្មីមួយបានចាប់ផ្តើមដំណើរការនៅខែកញ្ញា ឆ្នាំ ២០១៣ នៅក្នុងវិទ្យាល័យ ហ៊ុន សែន សួន់ ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ បន្ទប់សង្គ្រោះបឋមនេះបានផ្តល់សេវាសុខភាពដល់ទាំងសិស្ស គ្រូបង្រៀន និងបុគ្គលិកសិក្សាក្នុងរយៈពេល៣ឆ្នាំមកហើយ។ នៅក្នុងឆ្នាំសិក្សា ២០១៥-២០១៦ នេះ បន្ទប់សង្គ្រោះបឋមបានផ្តល់សេវាសុខភាពដល់សិស្ស គ្រូបង្រៀន និងបុគ្គលិកសរុបចំនួន ១.៧៦១នាក់។

## សកម្មភាពសំខាន់ៗ

១. បន្តផ្តល់សេវាសុខភាពដល់សិស្ស គ្រូបង្រៀន និងបុគ្គលិកសិក្សាក្នុងម៉ោងសិក្សា។ សេវាធម្មតាដែលផ្តល់ដំបូងបំផុត គឺការសង្គ្រោះបឋម និងការពិគ្រោះជំងឺ។

២. បំពាក់បរិក្ខាសង្គ្រោះបឋម ផ្គត់ផ្គង់ឱសថ ដើម្បីដោះស្រាយបញ្ហាសុខភាព។

៣. ផ្តល់ការអប់រំសុខភាពទាំងនៅក្នុង និងខាងក្រៅបន្ទប់សង្គ្រោះបឋមក្នុងសាលារៀនដោយផ្តោតទៅលើការថែទាំសុខភាព ការពារការឆ្លងមេរោគ និងអនាម័យ។

៤. លើកកម្ពស់ការថែទាំសុខភាពថ្នាក់ជាតិតាមរយៈការផ្សព្វផ្សាយសារសុខភាព និងការការពារពីការឆ្លងមេរោគកាចសាហាវ។

៥. សម្របសម្រួលបញ្ជូនសិស្សពិការទៅមន្ទីរពេទ្យដើម្បីព្យាបាល រួមមាន៖ ការថែទាំភ្នែក អវយវៈ...។ល។



## សនិទានភាពនៃកម្មវិធី

ដោយប្រកាន់ខ្ជាប់នូវវិធីសាស្ត្រអនុវត្តន៍ ដែលលើកកម្ពស់ការអភិវឌ្ឍអ្នកពាក់ព័ន្ធ ក្រុមប្រឹក្សាកុមារនៅវិទ្យាល័យ ហ៊ុន សែន សួន់ បានចាប់ផ្តើមសកម្មភាពមួយនៃការផ្តួចផ្តើមគំនិតរៀបចំទីកន្លែងមួយដែលគេអាចជួបប្រជុំគ្នា និងគាំពារសិស្សឈឺនៅក្នុងសាលារៀន។ មានសិស្សជាច្រើននាក់មកពីទីឆ្ងាយធ្វើដំណើរដោយជិះកង់ពីផ្ទះមកសាលារៀនរាល់ថ្ងៃ។ សិស្សជាច្រើនគឺជាកូនគ្រួសារក្រីក្រមានអាហារបរិភោគមិនគ្រប់គ្រាន់។ បន្ទាប់ពីខំប្រឹងដោយធ្វើដំណើរប្រើកម្លាំង សិស្សមួយចំនួនមានសុខភាពមិនល្អ ហើយអស់កម្លាំង និងត្រូវការឈប់សម្រាក។ ដោយសារគ្មានការផ្គត់ផ្គង់ពីសាលារៀនចំពោះតម្រូវការទាំងនេះ ធ្វើឱ្យជារឿយៗ សិស្សត្រូវដេកក្នុងថ្នាក់រៀន ឬអង្គុយនៅបរិវេណក្រៅថ្នាក់។ ក្រុមប្រឹក្សាកុមារបានជួបម្ចាស់ជំនួយម្នាក់ដែលបានសម្រេចចិត្តជួយគេដោះស្រាយតម្រូវការនេះ។ ទំនាក់ទំនងនេះហើយបានឈានដល់ការសាងសង់គ្លីនិកសុខភាព ដែលមានការផ្គត់ផ្គង់គ្រប់គ្រាន់នៅវិទ្យាល័យ ហ៊ុន សែន សួន់ ដោយមានគិលានុបដ្ឋាយិកាពេញម៉ោងមួយរូបផ្តល់ដោយការិយាល័យសុខាភិបាលស្រុក។ សកម្មភាពនេះគឺជាទាហរណ៍មួយនៃការផ្តល់អំណាចឱ្យអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍដោយមានសិស្សជាអ្នកផ្តួចផ្តើមគំនិតទាំងស្រុង។

## រូបភាពសកម្មភាព



## ផលជះគម្រោង

ដោយមានបន្ទប់សង្គ្រោះបឋម វិទ្យាល័យ ហ៊ុន សែន សួន់ គឺជាសាសារដ្ឋតែមួយគត់ដែលបានផ្តល់សេវាសុខភាពដល់សិស្ស គ្រូបង្រៀន និងបុគ្គលិកសិក្សាដែលមិនធ្លាប់មានពីមុនមក។ បន្ទប់សង្គ្រោះបឋមនេះកាន់តែមានការទាក់ទាញការសិក្សារបស់សិស្ស និងមានបរិយាកាសល្អសម្រាប់សិស្ស និងគ្រូបង្រៀន ហើយវាក៏បានចូលរួមកាត់បន្ថយអវត្តមាន និងអត្រាបោះបង់ការសិក្សារបស់សិស្ស ដែលបណ្តាលមកពីបញ្ហាសុខភាពផងដែរ។

# គម្រោង សៀវភៅសម្រាប់កម្ពុជា (BfC)

*" បង្កើនការលូតលាស់ជីវិតកុមារតាមរយៈសៀវភៅសិក្សា និងប្រព័ន្ធផ្សព្វផ្សាយ "*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការមូលនិធិអាស៊ី (TAF) |
| អ្នកទទួលផលផ្ទាល់ | សរុប: ៧៤.០២៦ នាក់<br>ស្រី: ៣៤.៩៥៨ នាក់ |
| ថវិកាបដិភាគទទួលបានក្នុងឆ្នាំ២០១៦ | ២៨០.០២០,២៧ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ៣,៧៨ ដុល្លារអាមេរិក |
| ខេត្តគ្របដណ្តប់ | ១៦ |
| ចំនួនស្រុកគ្របដណ្តប់ | ៣៦ |
| វិទ្យាស្ថានរដ្ឋាភិបាល និងសាកលវិទ្យាល័យគោលដៅ | ១០ |
| អង្គការមិនមែនរដ្ឋាភិបាលគោលដៅ | ៤ |
| អនុវិទ្យាល័យគោលដៅ | ២៩ |
| បឋមសិក្សាគោលដៅ | ៥៨ |
| សាលារដ្ឋ ឯកជន និងអង្គការមូលនិធិ | ៣ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មេសា ២០១៤ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ កញ្ញា ២០១៦ |

## គោលបំណង

គម្រោងសៀវភៅសម្រាប់កម្ពុជាជំរុញការលើកកម្ពស់នៃការអានភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យនៅក្នុងប្រព័ន្ធសាលារៀនរដ្ឋ។ គម្រោងក៏ខិតខំជួយដល់សាកលវិទ្យាល័យ ស្ថានប័នរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីបង្កើតវប្បធម៌នៃការអាននៅកម្ពុជា។



អានឱ្យសិស្សស្តាប់ អានជាមួយសិស្ស ប្រមូលសិស្សឱ្យរៀនអានខ្លួនឯង។

## បច្ចុប្បន្នភាពគម្រោង

គម្រោង**សៀវភៅសម្រាប់កម្ពុជា**ពង្រីកការចែកចាយសៀវភៅទៅដល់សាលារៀន និងអង្គការបានចំនួនពី ៦០ ដល់ ១០០ អង្គភាព។ ការចែកចាយបន្ទាប់ពីនេះទៀត រួមមាន៖ ស្ថាប័នរដ្ឋាភិបាល អង្គការមូលនិធិមនុស្សធម៌ អង្គការជាតិ និងអន្តរជាតិ និងតាមបណ្ណាល័យសាធារណៈ។

### ដ្យាក្រាមចែកចាយសៀវភៅក្នុងឆ្នាំ២០១៥/២០១៦




## សកម្មភាពសំខាន់ៗ

- គម្រោងសៀវភៅសម្រាប់កម្ពុជា បានចែកចាយសៀវភៅចំនួន ១៥,៧៧០ ក្បាល ក្នុងឆ្នាំសិក្សា ២០១៥-២០១៦នេះ។
- ដើម្បីបង្កើនការចែកចាយ និងការប្រើប្រាស់សៀវភៅទាំងនេះដល់អ្នកទទួល អង្គការ ខេប បានធ្វើការត្រួតពិនិត្យ និងវាយតម្លៃជាទៀងទាត់ពីការប្រើប្រាស់។
- យើងបានប្រមូល និងចងក្រងរបាយការណ៍ពីការផ្តល់ជាអនុសាសន៍ល្អៗ ដើម្បីប្រើប្រាស់សៀវភៅឱ្យបានចំនួនជាអតិបរិមា។
- ក្រុមការងារអង្គការ ខេប បានជំរុញលើកទឹកចិត្តដល់សាលាគោលដៅផងដែរដើម្បីលើកកម្ពស់សកម្មភាពអំណាន និងរៀបចំព្រឹត្តិការណ៍អំណាន។

## ផលជះរបស់គម្រោង

**វប្បធម៌នៃការសិក្សា**: បណ្ណារក្ស នាយកសាលា ព្រមទាំងគ្រូបង្រៀននៅតាមសាលាទាំងអស់បានរាយការណ៍មកថា សៀវភៅរឿងមានអត្ថប្រយោជន៍យ៉ាងពិសេសក្នុងការជំរុញសិស្សឱ្យចូលចិត្តអាន។ នៅពេលគ្រូបង្រៀន និងមាតាបិតាសិស្សជាច្រើនមិននិយាយភាសាអង់គ្លេស សៀវភៅទាំងនេះអាចឱ្យពួកគេធ្វើការណែនាំ និងចូលរួមក្នុងកម្មវិធីអំណានកុមារបាន។

**ការពង្រឹងបណ្ណាល័យ**: គម្រោងបានដាក់ចេញនូវអទិភាពដល់សាលារៀនណាដែលមានការគ្រប់គ្រងរឹងមាំល្អ រួមមាន៖ សាលារៀនគោលដៅរបស់គម្រោងងាយស្រួលរៀន (E2L) និងបណ្ណាល័យគម្រោង សាលារៀនជំនាន់ថ្មី និងមណ្ឌលយុវជន។ ការធ្វើអំណោយសៀវភៅដល់សាលាអនុវត្តក្រុងកំពង់ចាម និងវិទ្យាល័យ ព្រះស៊ីសុវត្ថិ ក្នុងរាជធានីភ្នំពេញបានធ្វើនូវសារពើភ័ណ្ឌសៀវភៅសិក្សាជាភាសាអង់គ្លេសផង និងបានរួមចំណែកយ៉ាងខ្លាំងដល់កម្មវិធីសិក្សាភាសាអង់គ្លេសរបស់សាលាផង។

**ការសម្លឹងមើលទៅថ្ងៃអនាគត**: អង្គការ ខេប សង្ឃឹមថាមូលនិធិនឹងមានតាមរយៈរាជរដ្ឋាភិបាល និងប្រភពក្រៅរដ្ឋាភិបាលដើម្បីជួយលើកកម្ពស់ប្រសិទ្ធភាពគ្រូបង្រៀនភាសាអង់គ្លេស ដែលអាចធ្វើឱ្យពួកគេមានសកម្មភាពគាំទ្រ និងជំរុញការអានបន្ថែមទៀតទាំងភាសាខ្មែរ និងភាសាអង់គ្លេស។

# ១៦

# គម្រោង អប់រំកុមារ (EAC)

*“ សាលារៀនបានបង្កភាពរីករាយដល់កុមារជនជាតិភាគតិច ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | EDUCATE A CHILD (EAC) មូលនិធិ អប់រំកុមារ ពីប្រទេស Qatar តាមរយៈ អង្គការ Aide et Action (AeA) ដែលមានបណ្ដាញសម្ព័ន្ធអង្គការចំនួន២១អង្គការ ។ |
| អ្នកទទួលផលផ្ទាល់ | សិស្សចំនួន ១៣.០០៣ នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ ២០១៦ | ៩៥.៩២៩.៧៥ ដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ៧.៤០ ដុល្លារអាមេរិក |
| ខេត្តគ្របដណ្ដប់ | ២ខេត្ត (ត្បូងឃ្មុំ និងក្រចេះ) |
| ស្រុកគ្របដណ្ដប់ | ៦ស្រុក |
| បឋមសិក្សាគោលដៅ | ៤៣សាលា |
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | ០១ មិថុនា ២០១៤ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ កក្កដា ២០១៧ |

## គោលបំណង

គោលបំណងសំខាន់របស់គម្រោងអប់រំកុមារគឺដើម្បីផ្ដល់នូវបរិយាប័ន្ននៃប្រព័ន្ធអប់រំកម្ពុជាដែលបំពេញបំណងដល់កុមារគ្រប់រូប រួមមាន៖ កុមារក្រៅសាលា កុមារពិការ កុមារជនជតិភាគតិច កុមាររស់នៅតំបន់ជនបទដាច់ស្រយាល និងកុមារអនាថារស់នៅតាមចិញ្ចើមថ្នល់ក្នុងទីប្រជុំជន និងក្មេងលើសអាយុជាដើម។ អង្គការ ខេប ធ្វើអន្តរាគមន៍ផ្ដោតទៅលើកុមារជនជាតិភាគតិច ជាពិសេស កុមារជនជាតិអ៊ីស្លាម និងក្រុមកុមារមកពីកុលសម្ព័ន្ធជនជាតិភាគតិច។

## រូបភាព



## បច្ចុប្បន្នភាពគម្រោង

គម្រោងបានបំពេញរួចរាល់នូវសកម្មភាពប្រតិបត្តិការក្នុងឆ្នាំទី២របស់ខ្លួន ដោយមន្ត្រីគម្រោងអប់រំកុមាររបស់អង្គការ ខេប បានធ្វើការលើកកម្ពស់ក្នុងការបង្កភាពងាយស្រួលចូលសាលារៀនសម្រាប់កុមារក្រៅសាលាមកពីក្រុមជនជាតិភាគតិចឱ្យចូលសាលារៀនប្រកបដោយសមធម៌ និងលើកម្ពស់គុណភាពអប់រំសម្រាប់កុមារទាំងនេះ។

គម្រោងបានប្រតិបត្តិការតាំងតែពីឆ្នាំទៅ ហើយនៅឆ្នាំទី២នេះបានបង្កើនអន្តរាគមន៍ដល់សាលាបឋមសិក្សាគោលចំនួន ៣ សាលាទៀត និងសាលាឆ្លងកាត់ចំនួន ៣ សាលាដែរក្នុងខេត្តត្បូងឃ្មុំ។ អគារឆ្លងកាត់ (ថ្នាក់រៀនបណ្ដោះអាសន្ន) គឺជាយុទ្ធសាស្ត្រសំខាន់របស់គម្រោងអប់រំកុមារដើម្បីផ្ដល់ភាពងាយស្រួលចូលរៀនដល់កុមារ ដែលមិនទទួលបានការអប់រំតាមបណ្ដាឃុំដាច់ស្រយាល ដោយសង់អគារឆ្លងកាត់ដែលប្រើប្រាស់សម្ភារៈនៅសហគមន៍មូលដ្ឋាន។ ឆ្លងតាមទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីមូលដ្ឋាន មានគ្រូកិច្ចសន្យាមួយចំនួនបានដាក់ឱ្យកាន់ថ្នាក់។ លើសពីនេះទៅទៀត គឺដើម្បីដោះស្រាយភាពកង្វះគ្រូដែលផ្ដល់ដោយក្រសួងអប់រំ អង្គការ ខេប មានថវិកាមួយចំនួនឧបត្ថម្ភដល់គ្រូសហគមន៍ផងដែរ ហើយនិងកម្មវិធីផ្សេងៗទៀត ដូចជាកម្មវិធីបំណិនជីវិត និងបំប៉នគ្រូ។ ការគាំទ្រពីសហគមន៍ គម្រោងមានលទ្ធភាពសាងសង់ ១០ អគារឆ្លងកាត់ដើម្បីផ្ដល់ជូនកុមារក្រៅសាលាចូលរៀន។ ជាលទ្ធផលរហូតដល់ឆ្នាំនេះ គម្រោងបានប្រមូលសិស្សក្រៅសាលាចំនួន ១.២២៨ នាក់ ចុះឈ្មោះចូលរៀន។

## សកម្មភាពសំខាន់ៗ

- → កសាងសាលាឆ្លងកាត់បានចំនួន ១០ សាលា ប្រមូលកុមារក្រៅសាលាបានជាង ២០០នាក់
- → ក្រសួងបានជួលគ្រូកិច្ចសន្យា ៥នាក់ ដើម្បីដោះស្រាយបញ្ហាកង្វះគ្រូបង្រៀន
- → យុទ្ធនាការប្រមូលកុមារចូលរៀនធ្វើឡើងដើម្បីប្រមូលកុមារក្រៅសាលា
- → បានធ្វើផែនទីសាលាចប់សព្វគ្រប់ចំនួន ២៨
- → ឧបត្ថម្ភអាហារូបករណ៍ដល់កុមារក្រៅសាលាចំនួន ៤១៤ នាក់ (មានស្រី ៥០%)
- → កម្មវិធីកុមារជួយកុមារផ្ដោតទៅលើកុមារធំជួយកុមារតូច
- → ជ្រើសរើស និងបណ្ដុះបណ្ដាលគ្រូជំនួយការថ្នាក់រៀនពីរភាសាចេញពីសហគមន៍ជនជាតិភាគតិច
- → ផ្ដល់វគ្គបណ្ដុះបណ្ដាលគ្រូមូលដ្ឋានដល់គ្រូបង្រៀនដើម្បីលើកកម្ពស់ការអនុវត្តក្នុងថ្នាក់រៀន
- → បង្កើតថ្នាក់បង្រៀនសិស្សរៀនយឺតនៅតាមភូមិ
- → ផ្ដល់ការសិក្សាកម្មវិធីបំណិនជីវិតទាក់ទងនឹងការអប់រំនៅក្នុងមូលដ្ឋាន/តំបន់
- → បណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំសម្រាប់នាយកសាលា និងសហគមន៍ដើម្បីឱ្យពួកគេមានជំនាញគ្រប់គ្រងមូលនិធិប្រកបដោយប្រសិទ្ធភាព
- → ក្រុមបច្ចេកទេសត្រួតពិនិត្យតាមដានទទួលបានការគាំទ្រពីការតាមដាន និងការធ្វើរបាយការណ៍ដំណើរការសាលារៀនជាប្រចាំ
- → ផ្ដល់បំណិនអាជីពដល់គ្រួសារកុមារក្រីក្រ
- → កុមារដែលមានបញ្ហាសុខភាពទទួលជំនួយជួយឱ្យពួកគេបន្តទៅរៀនបាន។

## ផលជះរបស់គម្រោង

### ១. អត្រាចុះឈ្មោះចូលរៀនកើនឡើង

» កុមារក្រៅសាលាចំនួន ២.៥០០ នាក់ ត្រូវបានចុះឈ្មោះចូលរៀនតាមរយៈគម្រោងចាប់តាំងពីឆ្នាំ២០១៤មក។

» កុមារក្រៅសាលាថ្មីចំនួន ១.២២៨ នាក់ (ស្រី ៥០%) បានចុះឈ្មោះចូលរៀនក្នុងឆ្នាំទី២នេះ។

### ២. ការប្រមូលសិស្សចូលសាលារៀនបានកើនឡើង

» សាលាឆ្លងកាត់ចំនួន ១០ ខ្នង ត្រូវបានកសាងឡើងនៅក្នុងឆ្នាំទី២ ដែលសរុបតាំងពីឆ្នាំ២០១៤មកមានចំនួន ២៤ ខ្នង។

### ៣. បញ្ហាខ្វះខាតគ្រូបង្រៀនត្រូវបានដោះស្រាយ

» នៅក្នុងឆ្នាំទី១ អង្គការ ខេប បានជួលគ្រូសហគមន៍ចំនួន ២០ នាក់ ដោយប្រើប្រាស់ថវិកាគម្រោង។

» ក្នុងឆ្នាំ២០១៥ មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុកបានឯកភាពគាំទ្រជួលគ្រូកិច្ចសន្យាឧបត្ថម្ភថវិកាដោយក្រសួងអប់រំ យុវជន និងកីឡាបានចំនួន ៥ នាក់។

### ៤. គុណភាពអប់រំត្រូវបានលើកកម្ពស់

គម្រោង អប់រំកុមារ បានផ្ដល់ការលើកកម្ពស់ស្ដង់ដាបង្រៀន និងបរិស្ថានថ្នាក់កុមារមេត្រី ដោយ៖

» បណ្ដុះបណ្ដាលវិធីសាស្ត្របង្រៀនសាលាកុមារមេត្រីដល់គ្រូបង្រៀនចំនួន ១០៨នាក់។

» ជួសជុល និង/ឬកែលម្អបន្ទប់រៀនឡើងវិញបានចំនួន ៣២ បន្ទប់។

# កម្មវិធីអប់រំបញ្ចូលគ្នា (IEP)

*“កម្មវិធីអប់រំបញ្ចូលគ្នាៈ លើកកម្ពស់សិទ្ធិអប់រំរវាង់ក្រុមជនជាតិ ”*

អង្គការ ខេប បានបញ្ចូលគម្រោងតូច និងមធ្យមដែលអនុវត្តសកម្មភាពស្រដៀងគ្នាស្ថិតក្រោមឆត្រតែមួយមានឈ្មោះថា**កម្មវិធីអប់រំបញ្ចូលគ្នា** ឬហៅកាត់ថា **IEP** ដើម្បីកាត់បន្ថយចំណាយផ្សេងៗ និងចំណេញពេលវេលា ដោយមានអ្នកសម្របសម្រួលតែម្នាក់គ្រប់គ្រងគម្រោងទាំងនោះ ។

គោលបំណងដ៏សំខាន់គឺបង្កើនភាពងាយស្រួលចូលសាលារៀនរបស់កុមារី កុមារជនជាតិ ឬយុវជនងាយរងគ្រោះដទៃទៀតកម្រិតអនុវិទ្យាល័យដល់សាកលវិទ្យាល័យ កម្រិតវិជ្ជាជីវៈ និងបណ្តុះបណ្តាលគ្រូជាដើម។

កម្មវិធី IEP មានគម្រោងចំនួនពីរ រួមមានៈ ១). គម្រោងអប់រំកុមារី (GEI) និង ២). គម្រោងស្ទែមសម្រាប់ស្ត្រី (STEM4WOMEN) និងគម្រោងទី៣ គឺគម្រោងអាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ (CTSP) នឹងដំណើរការដើមឆ្នាំ២០១៧ ។

| | គម្រោងអប់រំកុមារី(GEI) | គម្រោង STEM4Women |
|---|---|---|
| ម្ចាស់ជំនួយ | អង្គការមូលនិធិអូកទ្រី | អង្គការមូលនិធិអូកទ្រី អង្គការស្ត្រី ១០០ និងអង្គការ Classroom of Hope |
| អ្នកទទួលផលផ្ទាល់ | សិស្សចំនួន ៩២០នាក់ | សិស្សចំនួន ១០នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៦ | ១១៨.១៣៩ ដុល្លាអាមេរិក | ៣៩.៦០៥ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ១៧០ ដុល្លាអាមេរិក | ៩៥០ដុល្លាអាមេរិក (រៀននៅកម្ពុជា)<br>១២០០ដុល្លាអាមេរិក (រៀននៅថៃ) |
| ខេត្តគ្របដណ្តប់ | ២ខេត្ត (ត្បូងឃ្មុំ និងក្រចេះ) | ៦ខេត្ត (ត្បូងឃ្មុំ កំពង់ចាម កំពង់ធំ ព្រៃវែង រតនគិរី និងតាកែវ) |
| ស្រុកគ្របដណ្តប់ | ៦ស្រុក | ៩ស្រុក |
| មធ្យមសិក្សាគោលដៅ | ១០សាលា | គ្មាន |
| សាលាបណ្តុះបណ្តាលវិជ្ជាជីវៈគោលដៅ | • វិទ្យាស្ថានកំពង់ឈើទាល<br>• មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម | • វិទ្យាស្ថាន PNC<br>• វិទ្យាស្ថាន កសិកម្ម បុរីរ៉ាម<br>• វិទ្យាស្ថាន បច្ចេកទេស |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ សីហា ២០០០ | ០១ មីនា ២០១៦ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ ធ្នូ ២០១៨ | ២៨ កុម្ភៈ ២០១៨ |






*អ្នកទទួលផល និងសហគមន៍ត្រៀមខ្លួនជាស្រេច សម្រាប់ឱកាសការងារក្នុងសតវត្សទី២១*






១៨

# គម្រោង អប់រំកុមារី (GEI)

*“ ការអប់រំជួយឱ្យឆ្លងផុតពីគ្រោះអវិជ្ជា ”*

## បច្ចុប្បន្នភាពគម្រោង

គម្រោង**អប់រំកុមារី** (GEI) ដំណើរការសារជាថ្មីក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ ក្រោមជំនួយអង្គការមូលនិធិអូកទ្រី ប្រទេសអូស្ត្រាលីពីខែមករា ឆ្នាំ២០១២ និងអនុវត្តដោយអង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា (ខេប)។ គម្រោងនេះបានបង្កើតឡើងតាំងពីឆ្នាំ២000 និងមានអាយុកាល១៦ឆ្នាំហើយ។ អង្គការ ខេប បង្កើតគម្រោងអប់រំកុមារីក្នុងគោលបំណងផ្តល់ឱ្យយុវជននូវជំនាញ ព័ត៌មាន និងជំនួយចាំបាច់ដើម្បីជំរុញពួកគេឱ្យមានជម្រើសទាំងផ្នែកសេដ្ឋកិច្ច និងកិច្ចការងារសង្គម។ គម្រោងនេះបន្តដំណើរការដើម្បីផ្តល់តាមតម្រូវការយុវជន និងសង្គមនៅកម្ពុជា ជាពិសេសបោះជំហានក្នុងសតវត្សរ៍ទី២១។ សកម្មភាពសំខាន់ៗរបស់គម្រោង រួមមានៈ

- បណ្តុះភាពជាអ្នកដឹកនាំដល់ក្រុមប្រឹក្សាយុវជន
- ប្រឹក្សាយោបល់ដល់យុវជន
- ផ្តល់អាហារូបករណ៍ដល់យុវជនងាយរងគ្រោះក្នុងសាលា
  - ☞ (មធ្យមសិក្សា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសាកលវិទ្យាល័យ)
- ផ្តល់អាហារូបករណ៍ដល់យុវជនក្រៅសាលា និងផ្តល់សេវាកម្មវិជ្ជាជីវៈ។
- ផ្តល់បំណិនជីវិតដល់គ្រួសារឪពុកម្តាយយុវជនងាយរងគ្រោះ។
- ផ្តល់ការគាំទ្របណ្តាញការងារសង្គម។

## ករណីសិក្សា

អ្នកនាង ស្លេះ ហាទីនី (ទីនី) គឺជាគរុសិស្សឆ្នាំទី២ មកពីគ្រួសារប្រកបរបរកសិកម្ម និងជាជនជាតិចាមរស់នៅក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ នៅក្នុងសហគមន៍របស់នាងមិនមានក្មេងស្រីច្រើននាក់រៀនបានកម្រិតខ្ពស់ទេ ព្រោះឪពុកម្តាយពួកគេចង់ឱ្យនៅផ្ទះ និងឱ្យសិក្សាតែសាសនាឥស្លាមតែប៉ុណ្ណោះ។ មិត្តភក្តិស្រីៗរបស់នាងនៅក្នុងភូមិបានបោះបង់ការសិក្សា ហើយអ្នកភូមិសើចចំអកឱ្យនាងដែលទៅរៀនតែម្នាក់ឯង។ ទីនីស្រលាញ់ការសិក្សាណាស់ ហើយបានបញ្ចប់ការសិក្សានៅវិទ្យាល័យក្នុងឆ្នាំ២០១០។

ទីនីចង់បានអាជីពជាគ្រូបង្រៀនម្នាក់ ហើយបានដាក់ពាក្យប្រឡងធ្វើជាគ្រូបឋមសិក្សាចំនួន ៤លើក។ ជាការត្រេកអរ នាងក៏បានប្រឡងជាប់សិក្សានៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ចាមក្នុងឆ្នាំ២០១៤។

កាលពីមុន នាងធ្វើជាគ្រូកិច្ចសន្យានៅក្នុងភូមិរយៈពេល២ឆ្នាំ និងរៀបការបានកូនស្រីម្នាក់។ ឥឡូវនេះ នាងត្រូវរស់នៅឆ្ងាយពីប្តី និងកូនស្រីអាយុ២ឆ្នាំ ដើម្បីទៅសិក្សានៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ចាមរយៈពេល២ឆ្នាំ ដែលមានចម្ងាយ ៨0គីឡូម៉ែត្រពីផ្ទះរបស់នាង។ នាងនឹកដល់កូនស្រីខ្លាំងណាស់ ប៉ុន្តែនាងប្រាប់ខ្លួនឯងថា ត្រូវបញ្ចប់ការសិក្សាឱ្យបាន។ ចុងក្រោយ នាងនឹងបញ្ចប់ការសិក្សាឆ្នាំនេះ។ សមិទ្ធផលនេះ បានធ្វើឱ្យនាងអាចផ្លាស់ប្តូរផ្នត់គំនិតសហគមន៍ពីការបង្ខាំងកូនទៅរៀន ជាពិសេសក្មេងស្រី។ ទីនីបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែចំនួន៣0ដុល្លាអាមេរិកពីគម្រោង អប់រំកុមារី ដើម្បីសិក្សានៅសាលាគរុកោសល្យ និងវិក្រឹតការរយៈពេល២ឆ្នាំ។ នាងត្រូវបានជ្រើសរើសធ្វើជាប្រធានក្រុមក្នុងការរៀបចំប្រជុំសិស្សអាហារូបករណ៍ប្រចាំខែជាមួយអង្គការ ខេប ដែលធ្វើជាគំរូក្នុងថ្នាក់រៀន។ នាងបានគៀងគរថវិកាក្នុងសាលាជួយដល់ស្ត្រីចាស់ជរាក្នុងភូមិ។

នាង ទីនី ចង់ក្លាយទៅជាគ្រូបង្រៀនម្នាក់ប្រកបដោយចំណេះដឹង និងវិជ្ជាជីវៈខ្ពស់ ដើម្បីបង្រៀនសិស្សទទួលការអប់រំល្អ។ ទីនីចង់បន្តការសិក្សាថ្នាក់បរិញ្ញាបត្រអប់រំនៅសាកលវិទ្យាល័យ វ៉ៃស្មើន នាពេលអនាគត។

## ផលជះរបស់គម្រោង

- ☞ មានកិច្ចសហការល្អជាមួយក្រសួងអប់រំផ្នែកវិជ្ជាជីវៈប្រទេសថៃ និងវិទ្យាស្ថាន Passerelles Numériques កម្ពុជានៅភ្នំពេញផ្តល់ការសិក្សាបរិញ្ញាបត្ររង ឬបរិញ្ញាបត្រ និងការស្នាក់នៅដោយឥតគិតថ្លៃសម្រាប់និស្សិតអង្គការ ខេប ។
- ☞ គរុសិស្សអន្តរាគមន៍ដោយអង្គការ ខេប បានបញ្ចប់ការសិក្សា និងមានការងារធ្វើគ្រប់ៗគ្នា។ ពួកគាត់ដើរតួនាទីយ៉ាងសំខាន់ ធ្វើជាយុវជនគំរូនៅក្នុងសហគន៍។
- ☞ ផ្តោតលើការយកចិត្តទុកដាក់ដ៏សំខាន់ ផ្នែកប្រឹក្សាយោបល់នៅសាលាមធ្យមសិក្សា និងមានផែនការបង្កើតប្រឹក្សាយោបល់តាមប្រព័ន្ធអេឡិចត្រូនិច។
- ☞ កិច្ចសហការល្អពីសមាជិកគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ (CEFAC) ដើម្បីផ្តល់ការគាំទ្រ បំណិនជីវិតដល់ឪពុកម្តាយសិស្សអាហារូបករណ៍របស់គម្រោង អប់រំកុមារី។



# គម្រោង STEM4WOMEN

*" ការអប់រំផ្លាស់ប្តូរជីវិតស្ត្រីកម្ពុជា "*

## បច្ចុប្បន្នភាពគម្រោង

អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា (ខេប) គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយបានចាប់ដៃគូជាមួយអង្គការ Classroom of Hope (CoH) ដើម្បីជំរុញយុវតីចំនួន១០នាក់ដែលបាត់បង់ឱកាសសិក្សាទទួលបានការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)តាមគម្រូវការពិភពលោករយៈពេល២ឆ្នាំ ឧបត្ថម្ភគាំទ្រមូលនិធិពីអង្គការ ស្ត្រី១០០ ប្រទេសអូស្ត្រាលី។

យុវជនកម្ពុជាចំនួន ៤.៣៨៩.០០០នាក់អាយុពី ១៥ ទៅ ២៩ឆ្នាំ និងបច្ចុប្បន្ននេះយុវជនប្រហែលជា ៥% ចូលរៀនតាមវិទ្យាស្ថាន ឬសាកលវិទ្យាល័យ។ ក្នុងចំណោមយុវជនទាំងនោះ មានស្ត្រីប្រហែលជា ៣៩% ។ នៅប្រទេសកម្ពុជា សិក្សាផ្នែកស្តែមគឺនៅមានគម្លាតធ្លារវាងបុរស និងស្ត្រី ក្នុងនោះ ១៤% ជានារី និង ៨៦% ជាបុរស។ សម្រាប់ប្រទេសជិតខាង ដូចជាថៃគឺមានស្ត្រី ៥២% និងម៉ាឡេស៊ី ស្ត្រី ៤៨% សិក្សាជំនាញស្តែម។

## ករណីសិក្សា



កញ្ញា ចាន់ ស្រីតក់ អាយុ ២០ឆ្នាំ គឺជានិស្សិតកំពុងសិក្សាជំនាញគ្រប់គ្រងបណ្តាញកុំព្យូទ័រនៅសាលា Passerelles numériques កម្ពុជាក្នុងរាជធានីភ្នំពេញ។ នាងមានម្តាយម្នាក់ បងប្អូនស្រី ៣នាក់។ ឪពុកស្រីតក់បានចាកចោលកូនៗ និងប្រពន្ធអស់រយៈពេលច្រើនឆ្នាំ។ បងស្រីពីរនាក់របស់នាងបានបោះបង់ការសិក្សានៅអនុវិទ្យាល័យ ព្រោះម្តាយរបស់នាងមិនអាចរ៉ាប់រងការផ្គត់ផ្គង់កូនទាំង ៣នាក់សិក្សាក្នុងពេលតែមួយបាន។ ស្រីតក់បានធំពេញវ័យនៅក្នុងគ្រួសារដែលមិនមានសេចក្តីសុខ ហើយប្រឈមបញ្ហាជាច្រើន។ ម្តាយនាងបានលក់ផ្ទះតូចដើម្បីសងបំណុលគេ និងលក់នំ និងគ្រឿងទេសនៅមុខផ្ទះជួល។ ជួនកាល ស្រីតក់បានរកការងារក្រៅម៉ោងធ្វើក្នុងពេលវិស្សមកាលដើម្បីផ្គត់ផ្គង់ការសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ស្រីតក់នៅតែខិតខំប្រឹងប្រែងរៀនសូត្រទទួលបានលទ្ធផលសិក្សាល្អ។ នាងបានទទួលអាហារូបករណ៍ពីអង្គការ ខេប តាំងពីថ្នាក់ទី ១០ មក និងបច្ចុប្បន្នកំពុងសិក្សាឆ្នាំទី១នៅសាលា PNC គាំទ្រមូលនិធិដោយអង្គការស្ត្រី ១០០ និងសម្របសម្រួលដោយអង្គការ ខេប។ នាងនិយាយថា "*នៅថ្ងៃអនាគត ខ្ញុំចង់ក្លាយទៅជាស្ត្រីផ្នែកជំនួញម្នាក់។ នាងសង្ឃឹមថា នាងនឹងមានសមត្ថភាពគ្រប់គ្រាន់ទាំងជំនាញទន់ និងជំនាញបច្ចេកទេសធ្វើឱ្យនាងអាចបើកក្រុមហ៊ុនរកស៊ីដោយខ្លួនឯងបាន។ ខ្ញុំមិនចង់ធ្វើការងារឱ្យអ្នកដទៃឡើយនៅក្នុងមួយជីវិតខ្ញុំ។*

## គោលបំណង

គម្រោងមានបំណងផ្តល់សិទ្ធិអំណាចដល់យុវតីបាត់បង់ឱកាសសិក្សា ទទួលបានការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។

## សេចក្តីសង្ខេប

គម្រោង STEM4Women បានប្រើប្រាស់បណ្តាញទូលំទូលាយដែលអភិវឌ្ឍឡើងដោយអង្គការ ខេប ប្រើប្រាស់ធនធានមានកំណត់នៅក្នុងការគាំទ្រគោលបំណងទាំងនេះ រួមមាន៖ ការប្រឹក្សាយោបល់អាជីព និងទំនុកចិត្តទទួលបានការងារ។ ខេបមានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលថៃក្នុងការផ្តល់ការសិក្សា និងស្នាក់នៅដោយឥតគិតថ្លៃ នៅប្រទេសថៃ និងការបង់ថ្លៃសិក្សាកម្រិតទាបនៅប្រទេសកម្ពុជា សម្រាប់បេក្ខនារីជ្រើសរើសដោយគម្រោង។ យុវតីក្រីក្រចំនួន ៥នាក់ ត្រូវបានជ្រើសរើសឱ្យសិក្សាមុខជំនាញស្ថាបត្យកម្ម កែច្នៃអាហារ និងវិទ្យាសាស្ត្រដាំដុះនៅវិទ្យាស្ថាន បូរីរាំក្នុងប្រទេសថៃរយៈពេល២ឆ្នាំ (បរិញ្ញាបត្ររង)។ យុវតី ៥នាក់ទៀតសិក្សាបច្ចេកវិទ្យាព័ត៌មានវិទ្យា (IT) ផ្នែកសរសេរកម្មវិធីគេហទំព័រ និងការគ្រប់គ្រងប្រព័ន្ធណេតវើកនៅសាលា Passerelles Numériques នៅរាជធានីភ្នំពេញ។ ជាសរុប យុវតីចំនួន ១០នាក់ បានទទួលអាហារូបករណ៍ពីគម្រោងនៅក្នុងឆ្នាំនេះ។ ពួកគាត់កំពុងសិក្សាឆ្នាំទី១។

## ព្រឹត្តិការណ៍ និងសកម្មភាពសំខាន់ៗ

**សកម្មភាពទី ១**: ការជ្រើសរើស និងការបញ្ចប់វគ្គសិក្សាពីសាលាបច្ចេកទេស (ប្រទេសថៃ)

- ការជ្រើសរើសសិស្ស និងការប្រឹក្សាយោបល់អាជីព
- វគ្គសិក្សាខ្លីភាសាថៃ និងវប្បធម៌
- ការតម្រង់ទិសមុនពេលចេញដំណើរទៅប្រទេសថៃ។

**សកម្មភាពទី ២**: ការជ្រើសរើស និងការបញ្ចប់វគ្គសិក្សាពីវិទ្យាស្ថានបច្ចេកវិទ្យាព័ត៌មាន (ប្រទេសកម្ពុជា)

- ការជ្រើសរើសសិស្ស
- ការសិក្សាកម្មវិធីបំណិនជីវិត និងជំនាញទន់
- ការសិក្សាភាសាអង់គ្លេស។

**សកម្មភាពទី ៣**: ការរៀបចំពិធីផ្សព្វផ្សាយពីជំនាញនិស្សិតដល់ស្ថាប័នការងារ

- ការងារស្ម័គ្រចិត្ត

**សកម្មភាពទី ៤**: ការបង្កើតបណ្តាញអតីតនិស្សិត។

# គម្រោង ខ្ញុំកំពុងរៀន (IML)!

*“ធ្វើឱ្យមានសុពលភាពវិធីសាស្ត្រថ្មីចំពោះការអប់រំតាមរយៈការស្រាវជ្រាវ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការ Save the Children និងទីភ្នាក់ងារណ័រវេដើម្បីសហប្រតិបត្តិការអភិវឌ្ឍ(NORAD) |
| អ្នកទទួលផលផ្ទាល់ | សិស្ស ៤.៤៣៣ នាក់ (ស្រី ២.២៣៨ នាក់) |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៦ | ១៣២.២០០ ដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | គ្មាន |
| ខេត្តគ្របដណ្តប់ | ៥ខេត្ត (កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង និង កំពង់ឆ្នាំង) |
| ស្រុកគ្របដណ្តប់ | ១៦ |
| អនុវិទ្យាល័យគោលដៅ | ១៥ សាលាអនុវត្ត និង ១៥ សាលាប្រៀបធៀប |
| បឋមសិក្សាគោលដៅ | គ្មាន |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មីនា ២០១៣ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ ធ្នូ ២០១៧ |

## គោលបំណង

គម្រោងខ្ញុំកំពុងរៀនគឺជាឧទាហរណ៍នៃនិន្នាការថ្មីក្នុងការអភិវឌ្ឍ ដែលផ្តោតលើកម្មវិធីផ្អែកលើភស្តុតាង។ គម្រោងមានគោលបំណង៖

១. ស្រាវជ្រាវ តាមដាន និងប្រមូលឯកសារការពាក់ព័ន្ធរវាងការលើកកម្ពស់បរិស្ថានសិក្សា និងពង្រឹងលទ្ធផលសិក្សា/លទ្ធផលអភិវឌ្ឍន៍ការសិក្សា របស់កុមារ។

២. ធ្វើតេស្ត និងដំណើរការប្រមូលឯកសារ និងលទ្ធផលអនុវត្តវិធីសាស្ត្រគម្រោង “ខ្ញុំកំពុងរៀន!” សម្រាប់លើកកម្ពស់ការសិក្សា និងការអភិវឌ្ឍកុមារនៅក្នុងសាលារៀន។ ។

## សកម្មភាពសំខាន់ៗ

១. ប្រមូលទិន្នន័យសម្រាប់វាយតម្លៃគម្រោង

២. ប្រមូលទិន្នន័យសម្រាប់ការស្រាជ្រាវ

៣. ចូលរួមក្នុងសន្និបាទជាតិ និងអន្តរជាតិជាមួយប្រទេសពីរផ្សេងទៀតដែលកំពុងធ្វើការស្រាវជ្រាវដូចគ្នា។

## បច្ចុប្បន្នភាពគម្រោង

គម្រោងខ្ញុំកំពុងរៀនគឺផ្តោតទៅលើការធ្វើតេស្តពិសោធន៍ប្រសិទ្ធភាពក្របខណ្ឌការអភិវឌ្ឍថ្មីដែលបង្កើតឡើងដោយអង្គការ Save the Children។ ក្របខណ្ឌថ្មីនេះមានឈ្មោះថា ***បរិស្ថានសិក្សាប្រកបដោយគុណភាព (QLE)*** និងគោលវិធីសំខាន់ៗទាំង៤ដែលពាក់ព័ន្ធនឹងលទ្ធផលសិក្សាប្រកបដោយបញ្ញារបស់កុមារ សុខមាលភាពផ្លូវអារម្មណ៍ផ្អែកសង្គម ការចូលរួមរបស់សហគមន៍ និងថ្នាក់រៀន/បង្រៀន។ សម្រាប់ឆ្នាំ២០១៦នេះ គម្រោងខ្ញុំកំពុងរៀនបានធ្វើសកម្មភាពសំខាន់ៗជាច្រើន ទាំងការតាមដាន និងការវាយតម្លៃ និងការស្រាវជ្រាវ។ សម្រាប់ការតាមដាន និងវាយតម្លៃ អង្គការ ខេប បានបន្តប្រមូលទិន្នន័យតេស្តភាសាខ្មែរ និងគណិតវិទ្យា ក៏ដូចជាអត្រាចុះឈ្មោះចូលរៀននៅសាលាអនុវត្ត និងសាលាប្រៀបធៀបនៅក្នុងខែធ្នូ ឆ្នាំ២០១៥។ ការវាយតម្លៃការតាមដានបរិស្ថានសិក្សាប្រកបដោយគុណភាពត្រូវបានធ្វើនៅក្នុងខែមីនា ឆ្នាំ២០១៦ ដើម្បីតាមដានស្ថានភាពបរិស្ថានសិក្សាប្រកបដោយគុណភាពនៅក្នុងសាលាអនុវត្តទាំង១៥ និងដើម្បីផ្តល់អនុសាសន៍សម្រាប់អនុវត្តអំឡុងឆ្នាំនេះ។ នៅចុងឆ្នាំសិក្សាទី៣ អង្គការ ខេប បានធ្វើការវាយតម្លៃគម្រោងប្រចាំឆ្នាំ និងផ្តល់អនុសាសន៍សម្រាប់អនុវត្តគម្រោងឆ្នាំ២០១៧ ជាឆ្នាំបញ្ចប់។

នៅអំឡុងពេលស្រាវជ្រាវផ្លូវការ អង្គការ ខេប បានអភិវឌ្ឍក្របខណ្ឌស្រាវជ្រាវដែលបន្តប្រមូលទិន្នន័យ និងវិភាគលើការប្រែប្រួលបរិស្ថានសិក្សានិងលទ្ធផលជាក់ស្តែងរបស់កម្មវិធី និងលទ្ធផលវិជ្ជមានលើការសិក្សាការអនុវត្ត និងផលជះរបស់កុមារ។ អង្គការ ខេប បានប្រមូលទិន្នន័យតេស្តដើមឆ្នាំ និងទិន្នន័យតេស្តចុងឆ្នាំក្នុងឆ្នាំទី២ (ភាសាខ្មែរ គណិតវិទ្យា និងបំណិនជីវិត) ក៏ដូចជាទិន្នន័យគុណភាព និងការអភិវឌ្ឍតេស្តបំណិនជីវិតសម្រាប់ឆ្នាំទី៣ខាងមុខនេះ។ របាយការណ៍ស្រាវជ្រាវសង្ខេបប្រចាំឆ្នាំទី២ក៏បានធ្វើឡើងរួចរាល់ផងដែរ និងបានផ្ញើទៅសាកលវិទ្យាល័យ អូស្លូ ដើម្បីត្រួតពិនិត្យឡើងវិញ និងសម្រេចចុងក្រោយ៕




*ក្រុមស្រាវជ្រាវគម្រោង ខ្ញុំកំពុងរៀន អង្គការ ខេប បានធ្វើបទបង្ហាញអំពីការរកឃើញពីការស្រាវជ្រាវនៅក្នុងកិច្ចប្រជុំគម្រោង ខ្ញុំកំពុងរៀន ពិភពលោកក្នុងក្រុងប៊ូឡាវ៉ាយ៉ូ ប្រទេសស៊ីមបាវ៉េ (ខែមិថុនា ឆ្នាំ២០១៦)។*

# គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀន តាមរយៈការគាំទ្រពីសហគមន៍ (REACH/រីក II )

*" សហគមន៍រឹងមាំកសាងបាននូវសាលារៀនដ៏រឹងមាំ! "*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការ WeWorld |
| អ្នកទទួលផលផ្ទាល់ | • នាយកបឋម ៣៦នាក់ និងនាយករង ៣៦នាក់<br>• គ្រូបឋម ៣៦៣នាក់<br>• សិស្ស ១៥.៣២៤នាក់<br>• គ្រូមត្តេយ្យ ៤៧នាក់<br>• សិស្សមត្តេយ្យ ១.៦៦០នាក់<br>• សិស្សអាហារូបករណ៍ ៣៦០នាក់<br>• ក្រុមប្រឹក្សាកុមារ ៣៦នាក់<br>• គណៈកម្មការទ្រទ្រង់សាលា ៣៦នាក់<br>• អាជ្ញាធរ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ប្រធានការិយាល័យអប់រំ យុវជន និងកីឡា និងតំណាងសហគមន៍ ប្រហែល ៩៦នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៦ | ២៩៥.៨៩៤,៨០ ដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ១៧,០៦ ដុល្លារអាមេរិក |
| ខេត្តគ្របដណ្ដប់ | ៤ខេត្ត (ស្វាយរៀង ព្រៃវែង កំពង់ឆ្នាំង និងពោធិសាត់) |
| ស្រុកគ្របដណ្ដប់ | ៨ស្រុក (៣ ស្វាយរៀង ១ ព្រៃវែង ២កំ.ឆ្នាំង ២ពោធិសាត់) |
| បឋមសិក្សាគោលដៅ | ៣៦សាលា |
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | ០១ កក្កដា ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ មិថុនា ២០១៨ |

## បច្ចុប្បន្នភាពគម្រោង

- គាំទ្រផែនការអភិវឌ្ឍន៍សាលាបឋមសិក្សា ៣៦សាលាដើម្បីលើកកម្ពស់ការអនុវត្តផែនការ រួមមាន៖ ការធ្វើបច្ចុប្បន្នភាពផែនទីសាលា យុទ្ធនាការប្រមូលសិស្សចូលរៀន ប្រជុំមាតាបិតាសិស្ស។ល។
- គាំទ្រសកម្មភាពក្រុមប្រឹក្សាកុមារ និងកម្មវិធីបំណិនជីវិតដើម្បីធ្វើឱ្យមានការអប់រំផ្សារភ្ជាប់នឹងតម្រូវការនៅមូលដ្ឋាន។
- ការសាងសមត្ថភាពអ្នកដឹកនាំសាលា និងសមាជិកសហគមន៍ ដើម្បីធានាថា អ្នកពាក់ព័ន្ធមានជំនាញគ្រប់គ្រងចាំបាច់ក្នុងការគ្រប់គ្រងមូលនិធិឱ្យមានប្រសិទ្ធភាព។
- ឧបត្ថម្ភគាំទ្រអាហារូបករណ៍ដល់សិស្សបឋមសិក្សាចំនួន ៣៦០នាក់។
- ធ្វើទស្សនកិច្ចសិក្សានៅសាលាបឋមសិក្សា និងមត្តេយ្យសិក្សា និងគណៈកម្មការទ្រទ្រង់សាលា។
- ពង្រឹងសមាសភាគបណ្ណាល័យដើម្បីបង្កើនការអាន និងការសរសេររបស់សិស្ស។
- កសាងសមត្ថភាព និងគាំទ្រថ្នាក់មត្តេយ្យសិក្សាចំនួន ៤៧ថ្នាក់។
- កសាងសមត្ថភាពដល់គ្រូបង្រៀន ក្រុមប្រឹក្សាឃុំ គណៈកម្មការទ្រទ្រង់សាលា និងមាតាបិតាសិស្សក្នុងការប្រើប្រាស់ល្បែងសិក្សាសម្រាប់លើកកម្ពស់អំណានកូនៗពួកគេ។
- លើកកម្ពស់ការចូលរួមមាតាបិតាសិស្សក្នុងការអប់រំកូនចៅរបស់ពួកគេ។
- លើកកម្ពស់មាតាបិតាដើម្បីប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការសិក្សាអប់រំកូនចៅ។
- កសាងសមត្ថភាពគ្រូដើម្បីប្រើប្រាស់ និងផលិតសម្ភារៈបង្រៀនសិស្ស។

## គោលបំណង

គម្រោងរីក II មានគោលដៅពង្រឹងអក្ខរកម្ម លេខនព្វន្ត និងចំណេះដឹងកម្មវិធីបំណិនជីវិតតាមរយៈយុទ្ធសាស្ត្រចម្រុះ ដែលលើកកម្ពស់បរិស្ថានសិក្សា ទាំងនៅក្នុងសាលារៀន និងនៅតាមផ្ទះក្នុងខេត្តគោលដៅទាំង៤។

## រូបភាពសកម្មភាព



*ក្រុមប្រឹក្សាកុមារធ្វើផែនការអភិវឌ្ឍន៍សាលារៀនតាមរយៈការប្រឹក្សាយោបល់ក្រុម និងឆ្លុះបញ្ចាំងនូវអ្វីដែលពួកគេបានជោគជ័យ អ្វីដែលជាបញ្ហាប្រឈមហើយត្រូវដោះស្រាយយ៉ាងដូចម្ដេចនៅថ្ងៃអនាគត ដូចជាការកសាងជំនាញទន់ សម្រាប់ការងារក្រុមនិងស្វ័យឆ្លុះបញ្ចាំង។*

## ផលជះរបស់គម្រោង

ដើម្បីតាមដានផលជះរបស់គម្រោង ក្រុមការងារបានរៀបចំធ្វើតេស្តស្ទង់ដាអំណានសិស្សនៅដើមឆ្នាំ និងចុងឆ្នាំ។ ជាលទ្ធផលបញ្ជាក់ថា សាលាអន្តរាគមន៍មានភាពប្រសើរ បើប្រៀបធៀបជាមួយសាលាប្រៀបធៀប។ នៅពេលយើងមើលលទ្ធផលសិស្សនៅសាលាអន្តរាគមន៍ជាមធ្យមអាចអានបាន ៧,១១តួអក្សរ ខណៈដែលសិស្សនៅសាលាប្រៀបធៀបអាចអានបានតែ ៦,៥៨តួអក្សរ។ តាមលទ្ធផលនេះបញ្ជាក់ថា អន្តរាគមន៍កម្មវិធីអំណានមានផលល្អចំពោះសិស្សនៅសាលាគោលដៅ។




ក្រៅពីភាពរីកចម្រើនខាងលើគម្រោងមានរបាយការណ៍វិជ្ជមានផ្សេងទៀត ដូចជា មាតាបិតាសិស្ស ៧៥% ថា សាលាមានភាពប្រសើរចំពោះសកម្មភាពអន្តរាគមន៍អំណាន ក្រុមប្រឹក្សាកុមារសកម្មក្នុងតួនាទីរបស់គេ លើសពីនេះទៀត សាលាមានសម្ភារៈបច្ចេកវិទ្យានៅបណ្ណាល័យដែលជួយដល់ការសិក្សារបស់សិស្សជាពិសេសអំណាន។

## សកម្មភាពសំខាន់ៗ

គម្រោងរីក II បានចាប់ផ្ដើមនៅឆ្នាំ២០១២ ដោយគាំទ្រសាលាក្នុងខេត្តស្វាយរៀង និងព្រៃវែង។ បន្ទាប់ពីគម្រោងដំណើរការដោយជោគជ័យរយៈពេល៣ឆ្នាំ ដែលមានការពេញចិត្តនិងទទួលការស្នើសុំឱ្យបន្តនិងពង្រីកបន្ថែមពីសំណាក់មន្ត្រីរាជការក្នុងមូលដ្ឋាន អង្គការ វីវើល និងអង្គការ ខេប បានធ្វើការពិភាក្សាក្នុងការបន្តអនុវត្តគម្រោងនៅក្នុងខេត្តស្វាយរៀង និងព្រៃវែង៣ឆ្នាំទៀត និងពង្រីកគម្រោងទៅខេត្តថ្មីចំនួន២ទៀត គឺខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់។ គម្រោងបន្តប្រើយុទ្ធវិធីចម្រុះដើម្បីអភិវឌ្ឍសាលាឱ្យសមស្របទៅតាមគោលនយោបាយកម្មវិធីសាលាកុមារមេត្រីថ្នាក់ជាតិ។

គម្រោងបានឈានចូលដល់ឆ្នាំទី២នៃការអនុវត្តរបស់ខ្លួន នៅតែមានការពេញចិត្តពីអ្នកពាក់ព័ន្ធមូលដ្ឋានចំពោះវឌ្ឍនភាព។ គម្រោងរីក II បានរៀបចំឡើងដោយផ្ដោតខ្លាំងលើអំណានថ្នាក់ដំបូង។ ក្រោមការគាំទ្ររបស់អង្គការ វីវើល គម្រោងអាចបង្កើតឧបករណ៍វាយតម្លៃកម្មវិធីអំណានថ្នាក់ដំបូងតាមរយៈការអភិវឌ្ឍពីទម្រង់ឯកសាររឹងទៅជាឯកសារទន់ (កម្មវិធីអេឡិចត្រូនិច) ដែលគេហៅថា Tangerine ទៅជាភាសាខ្មែរជាលើកដំបូង៕

# ២២

# គម្រោង ងាយស្រួលរៀន (E2L)

*“ការរៀបចំគម្រោងដោយប្រើសកម្មភាពចម្រុះដើម្បីធានានូវផលជះរយៈពេលយូរក្នុងការអប់រំ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការឆាលហ្វានកម្ពុជា |
| អ្នកទទួលផលផ្ទាល់ | សិស្សចំនួន ៨.១៥៥ នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៦ | ៣៣៧.៥៥៧ ដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ៤១ ដុល្លារអាមេរិក |
| ខេត្តគ្របដណ្តប់ | ស្វាយរៀង |
| ស្រុកគ្របដណ្តប់ | ២ស្រុក (ស្វាយជ្រំ និងរមាសហែក) |
| បឋមសិក្សាគោលដៅ | ២១សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ កក្កដា ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ មិថុនា ២០១៦ (ដោយមានភាពជោគជ័យ និងទទួលបានការពង្រីកបន្ថែម) |

## គោលបំណង

គម្រោងមានគោលបំណងដើម្បីអភិវឌ្ឍគំរូដោយប្រើសកម្មភាពចម្រុះសាលាកុមារមេត្រី ដែលមានលក្ខណៈល្អនៅក្នុងផ្នែកជាច្រើន រួមមានៈ គុណភាពអប់រំ កម្មវិធីបញ្ចូលគ្នា និងជំរុញការចូលរួមពីភាគីពាក់ព័ន្ធនៅក្នុងស្រុក (ឧ. មាតាបិតា សហគមន៍ គណៈកម្មការទ្រទ្រង់សាលា និងរដ្ឋាភិបាលក្នុងស្រុក)។ សកម្មភាព និងលទ្ធផលគម្រោង ងាយស្រួលរៀន ត្រូវបានចាត់ជា៤ក្រុម រួមមានៈ (១). លើកកម្ពស់ភាពងាយស្រួលនៃការអប់រំ (២). លើកកម្ពស់គុណភាពអប់រំ និងបញ្ហាពាក់ព័ន្ធ (៣).កម្មវិធីអំណានថ្នាក់ដំបូងពាក់ព័ន្ធខ្លាំងគឺការរៀនតាមស្វាតហ្វូន និង (៤). ការលើកកម្ពស់ការគ្រប់គ្រងសាលារៀន និងសកម្មភាពអ្នកពាក់ព័ន្ធផ្សេងៗ។

## បច្ចុប្បន្នភាពគម្រោង

**គោលបំណងគម្រោង:** ដើម្បីអភិវឌ្ឍគំរូសាលាកុមារមេត្រីដែលពិតជាមានលក្ខណៈល្អនៅក្នុងផ្នែកជាច្រើន រួមមានៈ គុណភាពអប់រំ កម្មវិធីបញ្ចូលគ្នា និងការចូលរួមពីភាគីពាក់ព័ន្ធក្នុងស្រុក (ឧ.មាតាបិតា សហគមន៍ និងរដ្ឋាភិបាលក្នុងស្រុក)។

**គោលបំណងទី១:** បង្កភាពងាយស្រួលក្នុងការអប់រំ (ជាពិសេសក្មេងស្រី និងកុមារងាយរងគ្រោះ) ក្នុងតំបន់គោលដៅ។

- សិស្សបឋមសិក្សាចំនួន ១.៥៧៥នាក់ ទទួលបានអាហារូបករណ៍។
- កុមារចំនួន ៥៦នាក់ (ស្រី ១៧នាក់) ដែលពិការភាពទទួលបានសេវាត្រួតពិនិត្យសុខភាព។

**គោលបំណងទី២:** ប្រសិទ្ធភាពនៃការអប់រំ(ឧ.គុណភាពអប់រំ) លើកកម្ពស់តាមរយៈការអភិវឌ្ឍ និងអនុវត្តវិធីសាស្ត្រសាលាកុមារមេត្រី ដើម្បីឆ្លើយតបនឹងតម្រូវការកុមារងាយរងគ្រោះ ជាពិសេស កុមារី។

- បណ្ណាល័យចំនួន ៤ ត្រូវបានជួសជុលទៅជាបរិស្ថានសិក្សាក្នុងសតវត្សទី២១។
- កុមារចំនួន ១.៨៧០នាក់ (ស្រី ៩៣៤នាក់) ទទួលបានការអប់រំកម្មវិធីបំណិនជីវិតផ្ទាល់។
- ថ្នាក់រៀនចំនួន ១១៥បន្ទប់ (១៣សាលា) បានពង្រឹងកម្មវិធីកុមារមេត្រីបំពាក់ដោយសម្ភារៈបង្រៀន និងរៀន ផ្ទាំងផ្សព្វផ្សាយការអប់រំ បរិស្ថានសិក្សាល្អ។
- គ្រូសហគមន៍ចំនួន ៣១នាក់ (ស្រី ១៩នាក់) ត្រូវបានជ្រើសរើសមកបំពេញកង្វះគ្រូនៅក្នុងសាលាគោលដៅ។
- គរុសិស្សចំនួន ១៣នាក់ (ស្រី ៧នាក់) ទទួលបានអាហារូបករណ៍សិក្សានៅសាលា គរុកោសល្យ និងវិក្រឹតការខេត្ត។
- គ្រូបឋមចំនួន ១៧២នាក់ ដែលបង្រៀនពីថ្នាក់ទី១ ដល់ទី៦ ទទួលបានវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀនកម្មវិធីសាលាកុមារមេត្រី។

**គោលបំណងទី៣:** សមត្ថភាពអំណានរបស់កុមារកាន់តែប្រសើរឡើងផ្អែកលើទិន្នន័យមូលដ្ឋាន (ថ្នាក់ទី១-៣)។

- គ្រូថ្នាក់ទី១-៣ ចំនួន ១៩២នាក់ (ស្រី ៨១នាក់) ទទួលបានវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាអំណាន។
- សម្ភារៈ IEC ចំនួន 1000 ត្រូវបានបោះពុម្ព និងចែកចាយដល់សាលាគោលដៅ រួមមានៈ ស្តង់ដាអំណានថ្នាក់ទី៣ និងតេស្តដំណាក់កាល។
- សម្ភារៈអំណានចំនួន ១២៨មុខត្រូវបានចែកជូនដល់ថ្នាក់ទី១-៣ នៅក្នុងសាលាគោលដៅ។
- ថេប្លេតចំនួន ១៥០គ្រឿង (ម៉ាក Samsung Galaxy Tab 3 V) ត្រូវបានចែកជូនដល់សិស្សដើម្បីពង្រឹងបំណិនអំណានរបស់កុមារក្នុងសាលាគោលដៅ។
- គ្រូបង្វឹកអំណានចំនួន ២១នាក់ត្រូវបានបណ្តុះបណ្តាលពីរបៀបប្រើប្រាស់ប្រព័ន្ធឆ្លើយតបរហ័សដើម្បីលើកកម្ពស់សមត្ថភាពអំណានកុមារក្នុងសាលាគោលដៅ។

**គោលបំណងទី៤:** បង្កើនសមត្ថភាពគ្រប់គ្រងសាលារៀន ដើម្បីគ្រប់គ្រងជំនួយអភិវឌ្ឍន៍ការទទួលការអប់រំ និងគុណភាព ក៏ដូចជាការចូលរួមរបស់សហគមន៍។

- ភាគីពាក់ព័ន្ធសាលាចំនួន ៣២៨នាក់ (ស្ត្រី ៩២នាក់) ត្រូវបានបណ្តុះបណ្តាលពីរបៀបធ្វើផែនការអភិវឌ្ឍន៍សាលារៀន។
- សាលាគោលដៅចំនួន ២១ ទទួលបានថវិកាអភិវឌ្ឍន៍សាលា (ឧ. ប្រហែល ១.000 ដុល្លារអាមេរិកក្នុងមួយសាលា)។
- ថ្នាក់គ្រប់គ្រងសាលាចំនួន៤៦នាក់ ត្រូវបានបណ្តុះ បណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលា។
- សមាជិកគណៈកម្មការទ្រទ្រង់សាលា និងគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំចំនួន ១៦០នាក់ (ស្រី ២៣នាក់) ត្រូវបានបណ្តុះបណ្តាលស្តីពីតួនាទី និងការទទួលខុសត្រូវ ដូច្នេះពួកគេអាចគាំទ្រសាលាបាន។
- ក្រុមប្រឹក្សាកុមារចំនួន ៥១០នាក់ (ស្រី ២៦១នាក់) ទទួលវគ្គបណ្តុះបណ្តាលពីតួនាទី និងការទទួលខុសត្រូវដើម្បីធានាថា ពួកគេអាចជួយគ្រប់គ្រងសាលា លើកកម្ពស់ភាពជាអ្នកដឹកនាំ ការអប់រំកម្មវិធីបំណិនជីវិត...។ល។

## សកម្មភាពសំខាន់ៗ

- លើកកម្ពស់ភាពងាយស្រួលទទួលការអប់រំតាមរយៈអាហារូបករណ៍សម្រាប់កុមារក្រីក្រ និងសេវាសុខភាពសម្រាប់កុមារដែលកំពុងប្រឈមនឹងបញ្ហារាងកាយ។
- លើកកម្ពស់គុណភាពអប់រំតាមរយៈការអភិវឌ្ឍកម្មវិធីសាលាកុមារមេត្រី។
- ដោះស្រាយកង្វះខាតគ្រូតាមរយៈការឧបត្ថម្ភគាំទ្រដល់គរុសិស្ស និងជ្រើសរើសគ្រូសហគមន៍ដែលស្ថិតនៅក្នុងមូលដ្ឋាន។
- លើកកម្ពស់អំណានថ្នាក់ដំបូងតាមរយៈការប្រើប្រាស់ស្តង់ដាអំណាន សម្ភារៈអំណាន បណ្ណាល័យសតវត្សរ៍ទី២១ និងបច្ចេកវិទ្យា។
- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដល់ថ្នាក់ដឹកនាំសាលា។
- ការផ្តល់កញ្ចប់ថវិការដើម្បីអភិវឌ្ឍសាលារៀនក្នុងតំបន់គោលដៅ។
- លើកកម្ពស់ការចចូលរួមពីមាតាបិតា និងសហគមន៍តាមរយៈគណៈកម្មការទ្រទ្រង់សាលា និងការគាំទ្រការកសាងសមត្ថភាពសមាជិកគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ (CEFAC)។

## រូបភាពសកម្មភាព



*សិស្សប្រើប្រាស់ថេប្លេតអានភាសាខ្មែរនៅក្នុបណ្ណាល័យសតវត្សរ៍ទី២១។*



*សិស្សបានប្រមូលផលបន្លែនៅក្នុងសាលាពួកគេ។*

# គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ (E4K)

*"ផ្លាស់ប្តូរការបង្រៀនអំណានភាសាខ្មែរតាមរយៈការរៀនចល័ត"*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការ All Children Reading (ACR) ដែលជាមូលនិធិរួមពី៖<br>• World Vision<br>• USAID<br>• DFAT |
| អ្នកទទួលផលផ្ទាល់ | សិស្សថ្នាក់ទី២ និងថ្នាក់ទី៣ |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៦ | ១៩១.២៧៤,០០ ដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ៧៤ ដុល្លារអាមេរិក |
| ខេត្តគ្របដណ្តប់ | កំពង់ចាម និងត្បូងឃ្មុំ |
| ស្រុកគ្របដណ្តប់ | ១១ ស្រុក |
| អនុវិទ្យាល័យគោលដៅ | គ្មាន |
| បឋមសិក្សាគោលដៅ | ១៥សាលា (សាលាអនុវត្តមានចំនួន ១០ និងសាលាប្រៀបធៀបមានចំនួន ៥) |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ១៥ មករា ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ កក្កដា ២០១៧ |

## បច្ចុប្បន្នភាពគម្រោង

គម្រោងបាននឹងកំពុងអនុវត្តសកម្មភាពនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំចាប់តាំងពីខែមករា ឆ្នាំ២០១៥ មកម្លេះ។ គម្រោងនេះមានគោលការណ៍សំខាន់ៗចំនួន ៤ ក្នុងការអភិវឌ្ឍសៀវភៅអេឡិចត្រូនិច រួមមាន៖

១. ការអភិវឌ្ឍសៀវភៅអានដោយផ្អែកទៅតាមសមត្ថភាពខុសៗគ្នានៃសិស្ស (ដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិច)
២. ការអភិវឌ្ឍតេស្តខ្លីៗដោយបញ្ចូលទៅក្នុងសៀវភៅអានអេឡិចត្រូនិច
៣. ការបង្កើតវិធីណែនាំអំពីការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្សសម្រាប់អំណានថ្នាក់ដំបូង (DCLS) (ឧ. ក្រុមអំណានតាមកម្រិតសមត្ថភាព) ដែលកុមារអាចទទួលបានភាពជឿជាក់ពីការអានក្នុងកម្រិតមួយត្រឹមត្រូវ (ដែលផ្ទុយគ្នា នឹងការប្រើប្រាស់វិធីសាស្ត្រ ឬសម្ភារៈអំណានតែមួយប្រភេទសម្រាប់សិស្សគ្រប់រូប)
៤. ការចែកចាយសៀវភៅអេឡិចត្រូនិចតាមរយៈការចូលរួមពីដៃគូសហគ្រាសសង្គមធនធានសិក្សា (TTS)។ ការប្រើប្រាស់សៀវភៅអេឡិចត្រូនិចគឺជាមូលដ្ឋានដ៏សំខាន់មួយក្នុងការលើកកម្ពស់វិធីសាស្ត្របង្រៀនឆ្លើយតបនឹងតម្រូវការសិស្សសម្រាប់អំណានថ្នាក់ដំបូង (DCLS) ។

បច្ចុប្បន្នគម្រោងបាននឹងកំពុងដំណើរបានចំនួនប្រាំពីរត្រីមាស ហើយបានសម្រេចផលិតកម្មវិធី**សៀវភៅឆ្លាត** ដែលជាកម្មវិធីគន្លឹះដែលប្រើប្រាស់ក្នុងគម្រោង ក៏ដូចជាបង្កើតសេចក្តីណែនាំពីវិធីសាស្ត្របង្រៀនឆ្លើយតបតាមតម្រូវការសិស្សក្នុងសាលាគោលដៅ។

## សកម្មភាពសំខាន់ៗ

នៅក្នុងអំឡុងពេលអនុវត្តសកម្មភាពនៅក្នុងឆ្នាំទី២នេះ គម្រោង **E4K** បានសម្រេចសកម្មភាពសំខាន់ៗមួយចំនួនដូចជា៖

- បង្កើតសៀវភៅអេឡិចត្រូនិចតាមកម្រិតសមត្ថភាពសិស្សដែលមានឈ្មោះថា **សៀវភៅឆ្លាត**
- បង្កើតការណែនាំស្តីពីការប្រើប្រាស់ឧបករណ៍ថេប្លេត និងកម្មវិធីសៀវភៅឆ្លាត
- បង្កើតការណែនាំស្តីពីវិធីសាស្ត្របង្រៀនឆ្លើយតបតាមតម្រូវការសិស្ស
- បំលែងការធ្វើតេស្តរករបៀបនៃការរៀនឱ្យទៅជាអេឡិចត្រូនិច: http://kapekh.org/en/what-we-do/16/?pro_id=32
- បញ្ចូលកម្មវិធីសៀវភៅឆ្លាតទៅកាន់ PlayStore: https://play.google.com/store/apps/details?id=org.kape.smartbooks

## គោលបំណង

គម្រោងសៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរបង្កើតឡើងក្នុងគោលបំណងប្រើប្រាស់បច្ចេកវិទ្យាជាមូលដ្ឋានសម្រាប់ជំនួយការបង្រៀន ក៏ដូចជាសម្ភារៈឧបទេសដើម្បីលើកកម្ពស់សមត្ថភាពអានរបស់កុមារកម្ពុជា។

## រូបភាពសកម្មភាព




*សិស្សប្រើប្រាស់ថេប្លេតដើម្បីអានភាសាខ្មែរនៅក្នុងបណ្ណាល័យ ដែលគម្រោងដំឡើងឧបករណ៍នេះក្នុងការអន្តរាគមន៍ជំនួយដល់ការសិក្សាសិស្ស។*



*សិស្សប្រើប្រាស់ថេប្លេតដើម្បីអានភាសាខ្មែរនៅក្នុងបណ្ណាល័យ និងក្នុងបរិវេណសាលាដែលផ្តល់ទីកន្លែងទូលាយសម្រាប់សិក្សា។*

*កម្មវិធីសៀវភៅឆ្លាត និងកម្មវិធី**អានខ្មែរ**! ត្រូវបានដំឡើងឱ្យសិស្សរៀន។ កម្មវិធីទាំងនេះ អាចរកបានតាមទូរសព្ទស្មាតហ្វូន Android ដោយចូលទៅកាន់ PlayStore ដូចបានរៀបរាប់នៅក្នុងសកម្មភាពសំខាន់ៗ។*







Available for Android

## ផលជះរបស់គម្រោង

ដោយមានការផ្តួចផ្តើមបង្កើតនូវការណែនាំស្តីពីវិធីសាស្ត្របង្រៀនឆ្លើយតបតាមតម្រូវការសិស្ស គម្រោង E4K បានជំរុញឱ្យគម្រោងដទៃទៀតដូចជា គម្រោងងាយស្រួលរៀន និងគម្រោងសាលាជំនាន់ថ្មីបានចូលរួមអនុវត្តនូវវិធីសាស្ត្របង្រៀនថ្មីបែបសត្សវត្សរ៍ទី២១។

២៤

# គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណាន សម្រាប់កុមារ( ត្រាក់/TRAC II)

*“ការបង្កើតវិធីសាស្ត្រថ្មីៗសម្រាប់ពង្រឹងអំណានសម្រាប់កុមារ ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការមូលនិធិ Atlassian |
| អ្នកទទួលផលផ្ទាល់ | សិស្សថ្នាក់ទី ១, ២ និងទី ៣ |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៦ | ៣៤.៦១២,៧៨ ដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ៣៥.៤១ ដុល្លារអាមេរិក |
| ខេត្តគ្របដណ្តប់ | កំពង់ចាម និងត្បូងឃ្មុំ |
| ចំនួនស្រុកគ្របដណ្តប់ | ២ ស្រុក (ស្រុកព្រៃឈរ និងត្បូងឃ្មុំ) |
| មធ្យមសិក្សាគោលដៅ | គ្មាន |
| បឋមសិក្សាគោលដៅ | ៣ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ១៥ ធ្នូ ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ មិថុនា ២០១៦ |

## បច្ចុប្បន្នភាពគម្រោង

គម្រោងត្រាក់ II ធ្វើការលើកកម្ពស់អំណានថ្នាក់ដំបូងតាមរយៈប្រព័ន្ធអន្តរាគមន៍ជាច្រើនដែលផ្តល់នូវវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណាន ទាំងក្នុងថ្នាក់រៀន រួមមាន៖ បរិស្ថានសិក្សារបស់កុមារព្រមទាំងការពង្រឹងសេវាកម្មបណ្ណាល័យ គាំទ្រកម្មវិធីសិស្សជួយសិស្ស ប្រសិទ្ធភាពពីបច្ចេកវិទ្យា ការរៀបចំកុមារឱ្យលេងល្បែងសិក្សាដោយខ្លួនឯង (ឧ.សម្ភារៈអំណាន) បង្កើនការចូលរួមពីមាតាបិតាក្នុងសកម្មភាពគាំទ្រអំណាននៅតាមផ្ទះ។ មូលដ្ឋានគ្រឹះប្រព័ន្ធចាប់ផ្តើមដោយមានស្តង់ដាអំណាន ដែលត្រូវធ្វើការអភិវឌ្ឍដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ហើយបច្ចុប្បន្ននេះបានអនុម័តឱ្យផ្សព្វផ្សាយនៅថ្នាក់ជាតិ។ ស្តង់ដាអំណានដែលរួមមានការវាយតម្លៃច្បាស់លាស់ លើកកម្ពស់សមត្ថភាពសាលារៀនដើម្បីកំណត់ថា តើសាលារៀនបែបណាអាចជួយបានតាមរយៈប្រព័ន្ធឆ្លើយតបរហ័ស។ ការសម្របសម្រួលសកម្មភាពវាយតម្លៃជាដំណាក់ និងប្រព័ន្ធឆ្លើយតបរហ័សត្រូវសម្របសម្រួលដោយគ្រូបង្វឹកអំណាន ដែលអាចធ្វើឱ្យប្រព័ន្ធឆ្លើយតបរហ័សប្រសើរឡើង។ គោលដៅបង្កើតថ្មីក្រោមប្រព័ន្ធឆ្លើយតបរហ័ស រាប់បញ្ចូលទាំងការពង្រឹងសេវាបណ្ណាល័យសតវត្សរ៍ទី ២១ សិស្សជួយសិស្ស សម្ភារៈល្បែងសិក្សាអំណាន ការលេងល្បែងសិក្សាដោយខ្លួនឯង កម្មវិធីប្រជុំមាតាបិតា និងការរៀនចល័ត។ គម្រោងបានធ្វើការសាកល្បងរយៈពេល៦ខែនៅក្នុងសាលារៀនជនបទចំនួន ៣ មានលទ្ធផលលើកទឹកចិត្តល្អ។ ទោះបីស្ថិតក្នុងរយៈពេលអនុវត្តសកម្មភាពខ្លីៗក្តី ក៏គម្រោងត្រាក់ II អាចបង្ហាញអំពីការថយនៅក្នុងពិន្ទុ “0” ដែលលទ្ធផលល្អប្រសើរពីចាប់ផ្តើមដំបូង និងកាត់បន្ថយបញ្ហាប្រឈមនៃអំណានក្នុងអំឡុងពេលអនុវត្តគម្រោងជាក់ស្តែងរយៈពេល៤ខែ។

## គោលបំណង

អង្គការ ខេប បានលើកកម្ពស់អំណានថ្នាក់ដំបូងតាមរយៈប្រព័ន្ធនៃអន្តរាគមន៍ជាច្រើន ដែលផ្តល់ជាវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណាន ក្នុងថ្នាក់រៀន និងរួមបញ្ចូលទាំងធាតុផ្សេងៗទៀតក្នុងបរិស្ថានសិក្សារបស់កុមារ រួមមាន៖ ការពង្រឹងសេវាបណ្ណាល័យ សិស្សខុសកម្រិតគ្នា និងប្រសិទ្ធភាពដែលទទួលបានពីបច្ចេកវិទ្យា ការប្រមូលសិស្សឱ្យរៀនអនុវត្តល្បែងសិក្សាដោយខ្លួនឯង (ឧ. សម្ភារៈរៀនអំណាន) និងការជួយពីមាតាបិតា។

## សកម្មភាពសំខាន់ៗ

**សកម្មភាពទី ១:** របៀបចំប្រព័ន្ធវាយតម្លៃជាដំណាក់នៅសាលារៀនចំនួន៣ ដោយផ្អែកទៅលើស្តង់ដាអំណាន ដែលឯកភាពដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ថ្នាក់ទី ១-៣។

**សកម្មភាពទី ២:** បង្កើតប្រព័ន្ធឆ្លើយតបរហ័សដោយមានសកម្មភាពដែលរៀបចំដើម្បីឆ្លើយតបនឹងសិស្សមានតម្រូវការបន្ថែម ដែលបានកំណត់តាមរយៈការវាយតម្លៃជាដំណាក់របស់ស្តង់ដាអំណាន។ ប្រព័ន្ធឆ្លើយតបរហ័សរួមមាន៖ សិស្សជួយសិស្ស ការពង្រឹងការអានក្នុងបណ្ណាល័យ សម្ភារៈសិក្សា ការរៀនចល័ត **(M-learning)** ។ល។

**សកម្មភាពទី ៣:** កំណត់ និងបណ្តុះបណ្តាលគ្រូបង្វឹកអំណាននៅសាលាទាំង ៣ ដែលជាអ្នកសម្របសម្រួលការអនុវត្តស្តង់ដាអំណានជាមួយគ្រូ ក៏ដូចជាការប្រជុំជាមួយមាតាបិតាសិស្ស ការធ្វើឱ្យអន្តរាគមន៍ប្រព័ន្ធឆ្លើយតបរហ័សមានដំណើរការ និងការធ្វើការងារជាមួយបណ្ណារក្សក្នុងបណ្ណាល័យសតវត្សរ៍ទី២១។ ការតាមដានធ្វើឡើងដោយប្រើប្រាស់ឧបករណ៍ស្តង់ដា។

**សកម្មភាពទី ៤:** បង្កើតបណ្ណាល័យសតវត្សរ៍ទី២១ នៅក្នុងសាលាទាំង ៥ រួមមាន៖ ការរៀបចំជួសជុលបណ្ណាល័យចាស់ឡើងវិញ ហើយប្រើប្រាស់បានច្រើនមុខងារ សេវាបណ្ណាល័យអេឡិចត្រូនិច និងកម្មវិធីអំណាន ដែលប្រើទម្រង់លំហាត់រៀនចល័ត និងសៀវភៅសិក្សាអេឡិចត្រូនិចសម្រាប់ថ្នាក់ទី២ និងទី៣។

**សកម្មភាពទី ៥:** រៀបចំកម្មវិធីប្រជុំជាមួយមាតាបិតា និងសហគមន៍ដើម្បីធានាថា ការគាំទ្រអំណានត្រូវបានពង្រីកទាំងក្នុងថ្នាក់រៀន និងរួមមានការប្រជុំមាតាបិតា មាតាបិតាខ្ចីសម្ភារៈល្បែងសិក្សាពីបណ្ណាល័យ និងការគាំទ្រគ្រូបង្វឹកអំណានពីសហគមន៍។



***បណ្ណាល័យសតវត្សរ៍ទី២១**: សិស្សកាន់តែមានសកម្មភាពច្រើនជាងមុនមកអានសៀវភៅ និងរៀនប្រើប្រាស់ថេប្លេតនៅក្នុងបណ្ណាល័យ។ បណ្ណាល័យនេះទាក់ទាញបានទាំងសហគមន៍ និងមាតាបិតាសិស្សមកមើលកូនៗពួកគេរៀននៅទីនេះ។*

## ផលជះរបស់គម្រោង

អង្គការ ខេប បានរៀបចំបណ្ណាល័យឡើងវិញ ដើម្បីគាំទ្រដល់សាលាឱ្យមានភាពទំនើប និងទាក់ទាញកុមារកម្ពុជាក្នុងការសិក្សា។ សហគមន៍នៅសាលាបឋមសិក្សា ទួលទ្រា ពិតជាមានការភ្ញាក់ផ្អើលចំពោះគំនិតនេះ ហើយក៏រៃអង្គាសបានថវិកាច្រើនជាងសាលាមួយចំនួនដែរ។ ជាសរុប សហគមន៍រៃអង្គាសបាន ២000ដុល្លារអាមេរិកសម្រាប់ជួសជុលបណ្ណាល័យឡើងវិញចំណែកគ្រឿងសង្ហារឹមជាការបរិច្ចាគរបស់គម្រោងត្រាក់II។ ចាប់តាំងពីដំណើរការគម្រោងក្នុងខែឧសភា ឆ្នាំ២០១៦ មក បណ្ណាល័យមានសិស្សមកកកកុញច្រើន អង្គុយកន្លែងលេង ចូលលេងល្បែងសិក្សាទំនើបៗ និងពង្រឹងបំណិនអំណានរបស់ពួកគេដោយប្រើប្រាស់សុសវែរ អានខ្មែរថ្មីមានឈ្មោះថា អានខ្មែរ ដែលត្រូវបានអភិវឌ្ឍឡើង ជាពិសេសសម្រាប់សាលារដ្ឋ៕

# គម្រោង គ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ (SML)

*“ការលើកកម្ពស់អភិបាលកិច្ចល្អនៅសាលារៀនតាមមូលដ្ឋាន ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការឆាលហ្វានកម្ពុជា |
| អ្នកទទួលផលផ្ទាល់ | សិស្ស ៣.៨៥១ នាក់ (ស្រី ១.៩៣៣ នាក់) |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៦ | ៦៩.៧៥៧ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ១៦ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ក្រចេះ |
| ចំនួនស្រុកគ្របដណ្តប់ | ឆ្លូង |
| បឋមសិក្សាគោលដៅ | ១១ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ កក្កដា ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ មិថុនា ២០១៨ |

## បច្ចុប្បន្នភាពគម្រោង

គម្រោង SML បានបំពេញការងារឆ្នាំទី១នៃវដ្ត៣ឆ្នាំរបស់គម្រោង និងបានផ្តល់ការគាំទ្រដល់សាលាគោលដៅដូចខាងក្រោម៖

- គម្រោងបានផ្តល់វគ្គសិក្ខាសាលាចំនួនពីរវគ្គស្តីពី ការដឹកនាំនិងគ្រប់គ្រងសាលារៀនដល់សមាជិកក្រុមបំប៉ន និងត្រួតពិនិត្យតាមដានថ្នាក់ស្រុក (DTMT) និងនាយកសាលាគោលដៅទាំង១១សាលា។
- បានផ្តល់ការគាំទ្រ និងរៀបចំដើម្បីពង្រឹងការប្រជុំបច្ចេកទេសថ្នាក់កម្រងទាំង ៧ នៅក្នុងស្រុកឆ្លូង។
- បានផ្តល់កញ្ចប់ថវិកាអភិវឌ្ឍន៍ដល់សាលាបឋមសិក្សាគោលដៅទាំង ១១ ដើម្បីធ្វើការអភិវឌ្ឍបរិស្ថានសិក្សាកម្មវិធីសាលាកុមារមេត្រី។
- បានផ្តល់ការគាំទ្រផ្នែកអាហារូបករណ៍ដល់សិស្សក្រីក្រចំនួន ១៥៤ នាក់ នៅក្នុងសាលាគោលដៅទាំង ១១។
- បានរៀបចំ និងទទួលដំណើរទស្សនកិច្ចសិក្សាដើម្បីផ្លាស់ប្តូរបទពិសោធន៍មួយដែលដឹកនាំដោយអង្គការ **Samaritan Purse** មកពីខេត្តបន្ទាយមានជ័យ។

## សកម្មភាពសំខាន់ៗ

- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេស ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដល់សមាជិកក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុកក្នុងស្រុកឆ្លូង។
- ធ្វើទស្សនកិច្ចគាំទ្របច្ចេកទេសដល់ថ្នាក់គ្រប់គ្រងសាលារៀនដោយសមាជិកក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដោយបុគ្គលិកគម្រោង និងសមាជិកបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុកសម្រាប់ថ្នាក់ដឹកនាំសាលារៀន។
- រៀបចំទសន្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំសាលារៀន និងសមាជិកបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក ដើម្បីសិក្សាអំពីកម្មវិធីសាលាកុមារមេត្រីនៅក្នុងតំបន់ដទៃៗទៀត។
- រៀបចំកិច្ចប្រជុំកម្រងបច្ចេកទេសជាមួយគ្រូដោយថ្នាក់ដឹកនាំសាលារៀន និងសមាជិកក្រុមត្រួតពិនិត្យបច្ចេកទេសផ្តោតលើជំនាញបង្រៀន និងការផលិតសម្ភារៈរៀន។
- អភិវឌ្ឍផែនការលើកកម្ពស់សាលារៀនជាលក្ខណៈចូលរួមស្របតាមថវិកាជំនួយដើម្បីគាំទ្រការវិវត្តឆ្ពោះទៅរកបរិស្ថានសិក្សាសាលាកុមារមេត្រីជាច្រើនទៀត។
- ផ្តល់វគ្គបំប៉នដល់គណៈកម្មការទ្រទ្រង់សាលារៀនស្តីពីតួនាទី និងភារកិច្ច គោលនយោបាយអប់រំសំខាន់ៗ (ឧ.ការអប់រំសម្រាប់ទាំងអស់គ្នា) ការតស៊ូមតិ និងការចូលរួមពីសហគមន៍។
- ធ្វើការវាយតម្លៃគណៈកម្មការទ្រទ្រង់សាលារៀននូវចំណុចនានា (ឧ.មុនចាប់ផ្តើម ក្នុងពេល និងចុងបញ្ចប់) អំឡុងពេលអនុវត្តគម្រោង។

## គោលបំណង

គម្រោងមានគោលបំណងដូខាងក្រោមៈ “សាលាកុមារមេត្រីគោលដៅលើកកម្ពស់លទ្ធផលការពង្រឹងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងល្អនៅបឋមសិក្សាគោលដៅចំនួន ១១ សាលា” ។ គម្រោងនេះមានទិសដៅ៖

១. បង្កើនជំនាញបច្ចេកទេសដល់សមាជិកក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក (DTMT) ក្នុងការផ្តល់ការគាំទ្រដល់នាយកបឋមសិក្សាគោលដៅទាំង១១សាលា។
២. លើកកម្ពស់ការកសាងសមត្ថភាពដល់នាយកសាលាតាមរយៈការបណ្តុះបណ្តាល។
៣. លើកកម្ពស់បរិស្ថានសាលាកុមារមេត្រីតាមរយៈការពង្រឹងសមត្ថភាពថ្នាក់គ្រប់គ្រងសាលា និងកញ្ចប់ថវិកាជំនួយសម្រាប់អ្នកពាក់ព័ន្ធ។
៤. គណៈកម្មការទ្រទ្រង់សាលារៀនបង្ហាញពីការពង្រីកសមត្ថភាពដោយផ្អែកលើលក្ខខណ្ឌស្តង់ដា រួមមាន៖ ការចូលរួមពាក់ព័ន្ធ ការត្រួតពិនិត្យ និងការគ្រប់គ្រងធនធាន។

## រូបភាពសកម្មភាព



*ក្រុមត្រួតពិនិត្យបច្ចេកទេស និងនាយកសាលាបានចូលរួមសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលា ដែលធ្វើការបង្ហាញដោយលោក អ៊ុល រុន ទីប្រឹក្សាជាតិជាន់ខ្ពស់។*

## ផលជះរបស់គម្រោង

ចាប់តាំងពីគម្រោង SML បានចាប់ផ្តើមមក មានការរៀបចំប្រជុំថ្នាក់បច្ចេកទេសជាទៀងទាត់ប្រចាំខែនៅកម្រិតសាលាកម្រងទាំងអស់។ ដោយមានការចូលរួមគាំទ្របច្ចេកទេសពីបុគ្គលិកគម្រោងពាក់ព័ន្ធនឹងវិធីសាស្ត្ររៀន និងបង្រៀនថ្មីៗ។ ការប្រជុំនេះក៏បានបង្ហាញអំពីកំណើនខ្លឹមសារល្អៗសម្រាប់គ្រូបង្រៀនធ្វើការឆ្លុះបញ្ចាំង និងអនុវត្តផងដែរ។ ការផ្លាស់ប្តូរនេះគឺជាផ្នែកមួយដ៏ធំនៃការផ្លាស់ប្តូរឥរិយាបទ និងអាកប្បកិរិយាថ្នាក់ដឹកនាំសាលារៀន។ ការផ្លាស់ប្តូរផ្សេងៗទៀតនាបច្ចុប្បន្នេះ ដូចជាការប្រសើរឡើងគួរឱ្យកត់សម្គាល់នូវទិដ្ឋភាពសាលា ដែលមានការរឹតត្បឹតបទបញ្ជាផ្ទៃក្នុងចំពោះការចោលសំរាមនៅកន្លែងត្រឹមត្រូវ។ ក្នុងបច្ចុប្បន្ននេះ ថ្នាក់រៀនមានសម្ភារៈ និងដឹកនាំរៀបចំល្អធ្វើឱ្យមានការទាក់ទាញសិស្សមករៀននៅក្នុងថ្នាក់ច្រើនឡើងៗ។

ស្ថិតក្រោមការដឹកនាំរបស់សមាជិកក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុកថ្នាក់ដឹកនាំបានបង្កើតឱ្យមានចក្ខុវិស័យនៅក្នុងសាលាពួកគេ ដែលធ្វើឱ្យមានការយល់ដឹងយ៉ាងទូលំទូលាយរួមទាំងគ្រូបង្រៀន និងសហគមន៍។ ចក្ខុវិស័យនេះផ្តោតទៅលើការលើកកម្ពស់គុណភាពអប់រំដែលជាវិធីសាស្ត្រផ្សារភ្ជាប់ផ្ទាល់នឹងភាពជាអ្នកដឹកនាំល្អក្នុងចំណោមថ្នាក់ដឹកនាំសាលា។ ការរួមបានថវិកាជំនួយផ្តល់ដោយគម្រោង សាលារៀនក៏បានបង្ហាញអំពីគំនិតផ្តួចផ្តើមល្អៗដើម្បីធ្វើឱ្យបរិវេណសាលាស្រស់ស្អាត លើកកម្ពស់បរិស្ថានតាមថ្នាក់រៀន ការធ្វើអនាម័យ និងការពង្រឹងសកម្មភាពសិក្សា។ ថវិកាជំនួយទាំងនេះត្រូវបានធ្វើកម្មវិធីអំឡុងពេលប្រជុំធ្វើផែនការអភិវឌ្ឍន៍សាលារៀនដែលទាំងថ្នាក់ដឹកនាំសាលា និងគ្រូបង្រៀនបានចូលរួមនៅក្នុងឆ្នាំនេះផងដែរ៕

២៦

# គម្រោង បណ្ណាល័យអេឡិចត្រូនិចសម្រាប់កុមារ (CDL)

*"ការលើកកម្ពស់វប្បធម៌អំណានសម្រាប់កុមារ"*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការមូលនិធិអាស៊ី (TAF) |
| អ្នកទទួលផលផ្ទាល់ | សិស្សចំនួន ៩៩១នាក់ (ស្រី ៥០៣នាក់) |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៦ | ៥.៧២៣,៨៨ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ៩,៦៨ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ខេត្តកំពង់ចាម និងខេត្តស្វាយរៀង |
| ចំនួនស្រុកគ្របដណ្តប់ | ក្រុងកំពង់ចាម និងស្រុកស្វាយជ្រំ |
| បឋមសិក្សាគោលដៅ | សាលាអនុវត្ត តាន្ទ និងចារ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ តុលា ឆ្នាំ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ កញ្ញា ២០១៦ |

## បច្ចុប្បន្នភាពគម្រោង

គម្រោង CDL បានប្រើប្រាស់ថេបប្លេត និងកម្មវិធី**តស់អាន**សម្រាប់សិស្សអានសៀវភៅ ហើយគម្រោង CDL បានធ្វើបច្ចុប្បន្នភាពរាល់៣ខែម្តង ជាដំបូងបញ្ចូលសៀវភៅភាសាខ្មែរ និងភាសាអង់គ្លេស ដែលមានជាង១០០ក្បាលដាក់ក្នុងថេបប្លេត។ គម្រោង CDL បានចាប់ដំណើរការនៅក្នុងខែតុលា ឆ្នាំ២០១៥ បន្ទាប់មក គម្រោងបានផ្តល់ថេបប្លេតចំនួន ១០គ្រឿងដល់សាលាអនុវត្ត និង ៧គ្រឿងទៀតដល់សាលាបឋមសិក្សា តាន្ទ និង ៣គ្រឿងទៀតដល់សាលាបឋមសិក្សា ចារ។ គម្រោងបានផ្តល់ raspberry-pi និងសម្ភារៈមួយចំនួនបន្ថែមទៀតសម្រាប់ដំណើរការកម្មវិធី**តស់អាន**!។ ជាដំបូងគម្រោងទទួលការបំប៉នពីរបៀបប្រើប្រាស់កម្មវិធី**តស់អាន**ពីអង្គការមូលនិធិអាស៊ីហើយគម្រោង បណ្តុះបណ្តាលបន្តដល់សាលាទាំងបីនៅចុងខែតុលា។ គម្រោងបានដំឡើងកម្មវិធី**តស់អាន**! ដាក់ចូលក្នុងថេបប្លេតទាំងអស់ដែលទទួលបានពីមូលនិធិអាស៊ី និងថេប្លេតដែលទទួលបានពីអង្គការដៃគូ ដូចជាគម្រោង REACH, BSI និងគម្រោងងាយស្រួលរៀន។ សិស្សគោលដៅពីថ្នាក់ទី៤ ដល់ថ្នាក់ទី៦។ សាលារៀននីមួយៗបង្កើតផែនការជ្រើសរើសសកម្មភាពមួយចំនួនសម្រាប់លើកកម្ពស់អំណាន និងបង្កើតទម្លាប់ការអានរបស់សិស្ស។ សកម្មភាពទាំងអស់នៅក្នុងផែនការសាលា រួមមាន៖ ក្លឹបអំណាន ការរៀបចំអំណានឱ្យមានជាប្រព័ន្ធ ការបង្កើតការប្រកួតប្រជែងអំណានរាល់២ខែម្តងដឹកនាំដោយសាលា និងសិស្ស។ លើកកម្ពស់ទិវាអំណានជាតិដោយរៀបចំសកម្មភាពខុសប្លែកគ្នានៅក្នុងសាលានីមួយៗ ដែលមានការចូលរួមពីមាតាបិតា។ ផ្តល់ពានរង្វាន់លើកទឹកចិត្តដល់សិស្សដែលមានទម្លាប់អានបានច្រើន និងប្រកាសជ័យលាភីនៅចុងឆ្នាំសិក្សា។ សាលាទាំងអស់បានអនុវត្តគ្រប់សកម្មភាពទាំងអស់តាមផែនការរបស់ពួកគេ។

## សកម្មភាពសំខាន់ៗ

1. ផ្តល់ថេបប្លេតដល់សាលាគោលដៅ។
2. បញ្ចូលកម្មវិធី**តស់អាន**! (ថេប្លេត) ដល់សាលាគោលដៅ។
3. ផ្តល់វគ្គបណ្តុះបណ្តាលដល់បណ្ណារក្ស គ្រូបង្រៀនអំណាន ថ្នាក់ដឹកនាំសាលា និងលោកគ្រូអ្នកគ្រូស្តីពីការប្រើប្រាស់សេវាបណ្ណាល័យអេឡិចត្រូនិច។
4. លើកកម្ពស់វប្បធម៌នៃការអាន (សកម្មភាពអំណានតាមរចនាសម្ព័ន្ធកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ការប្រកួត២ខែម្តង ទិវាអំណានជាតិ ក្លឹបអំណាន ពានរង្វាន់សម្រាប់សិស្សដែលមានទម្លាប់ល្អក្នុងការអាន)។
5. បង្កើតសៀវភៅ "**ឯកសារពង្រឹងសកម្មភាពអំណានដើម្បីលើកកម្ពស់វប្បធម៌អំណាន**"។

## គោលបំណង

គម្រោងបណ្ណាល័យអេឡិចត្រូនិចសម្រាប់កុមារមានគោលបំណងបង្កើនដំណើរការនៃការអាន ប្រកបដោយគុណភាពតាមរយៈការប្រើប្រាស់សម្ភារៈថេបប្លេត និងកម្មវិធីសៀវភៅអេឡិចត្រូវនិច។

## រូបភាពសកម្មភាព



*សកម្មភាពអំណានៈ សិស្សអាន និងសង្ខេបរឿងតាមកម្មវិធីតស់អាន!*

## ផលជះរបស់គម្រោង

ដោយសារមានពានរង្វាន់លើកចិត្តចំពោះសិស្សដែលមានទម្លាប់ល្អក្នុងការអាន សិស្សមួយចំនួនបានអាន និងសង្ខេបរឿងទាំងអស់ជាភាសាខ្មែរតាមរយៈកម្មវិធី**តស់អាន**! និងសៀវភៅជាច្រើនទៀតនៅក្នុងបណ្ណាល័យ។ ពួកគេព្យាយាមអាន និងសង្ខេបសាច់រឿងនៅក្រៅម៉ោងសិក្សាជារៀងរាល់ថ្ងៃ និងនៅពេលម៉ោងចេញលេង។ សិស្សម្នាក់នៅសាលាបឋមសិក្សា តាន្ទ បានអាន និងសង្ខេបសាច់រឿងបានចំនួន ១៥៧ក្បាល និងម្នាក់ទៀតបាន ១៥១ក្បាល។ ពួកគេអាចផ្លាស់ប្តូរទៅរកសៀវភៅដែលពួកគេចូលចិត្តជាងការលេងល្បែងសិក្សា។ សិស្សជាច្រើនបានផ្លាស់ប្តូរឥរិយាបទពីទម្លាប់នៃការលេងល្បែងផ្សេងៗក្នុងម៉ោងចេញលេង ហើយប្តូរទៅបណ្ណាល័យអានសៀវភៅជំនួសវិញ។ សិស្សមួយចំនួនបានខិតខំរៀនសូត្រយ៉ាងខ្លាំងមុនពេលចូលរួមប្រកួតអំណាន។ ពួកគេចូលចិត្តអានយ៉ាងខ្លាំង ជាពិសេស អានតាមរយៈថេប្លេត ព្រោះពួកគេមានអារម្មណ៍ថាមានផាសុខភាព និងងាយស្រួលប្តូរសៀវភៅអានពីមួយទៅមួយទៀតនៅកន្លែងតែមួយបានច្រើនក្បាល។ ពួកគេនិយាយថា សៀវភៅទាំងអស់នៅក្នុងកម្មវិធី**តស់អាន**! មានការទាក់ទាញ និងអប់រំពួកគេឱ្យធ្វើកិច្ចការល្អៗ។ យ៉ាងហោចណាស់ ពួកគេអាចអានបានរយៈ១ម៉ោងក្នុងមួយសប្តាហ៍នៅក្នុងបណ្ណាល័យ។ សិស្សភាគច្រើនបំផុតចូលចិត្តអានសៀវភៅក្នុងម៉ោងចេញលេង និងនាំមិត្តភក្តិចូលបណ្ណាល័យ។ ចំពោះក្លឹបអំណានវិញ ពួកគេអាចបង្រៀនមិត្តភក្តិឱ្យចេះអាន និងជួយមិត្តដែលមិនចេះអាន។ កម្មវិធីសិស្សជួយសិស្សធ្វើឡើងដោយសារពួកគេមិនចេះអានសៀវភៅ។

ការប្រឈមគឺសៀវភៅមួយចំនួនដែលចេញដំបូង និងថេប្លេតខ្លះទៀតនៅក្នុងសាលាមួយចំនួនពិបាកប្រើប្រាស់កម្មវិធី**តស់អាន**! និងសិស្សខ្លះពិបាកក្នុងការអាន។

២៧

# គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព (QLE Expansion)

*"ការលើកកម្ពស់បរិស្ថានសិក្សាដើម្បីការលូតលាស់កុមារ"*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការ Save the Children និងទីភ្នាក់ងារណ័រវេដើម្បីសហប្រតិបត្តិការអភិវឌ្ឍន៍ (NORAD) |
| អ្នកទទួលផលផ្ទាល់ | សិស្ស ២២.៣៩៨នាក់ (ស្រី ៨.៦៦៦ នាក់) |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៦ | ១៣៥.៥៦៥ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ៦ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ៣ខេត្ត (កំពង់ចាម ត្បូងឃ្មុំ និងព្រះវិហារ) |
| ចំនួនស្រុកគ្របដណ្តប់ | ១៦ស្រុក |
| បឋមសិក្សាគោលដៅ | ៩៤ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មករា ២០១៦ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ ធ្នូ ២០១៨ |

## បច្ចុប្បន្នភាពគម្រោង

គម្រោង QLE Expansion បានចាប់ផ្តើមអនុវត្តនៅខេត្តកំពង់ចាម ត្បូងឃ្មុំ និងខេត្តព្រះវិហារ នៅក្នុងឆ្នាំសិក្សា២០១៥ និងបញ្ចប់នៅក្នុងឆ្នាំ២០១៨។ គម្រោងនេះផ្តោតលើ QLE ដែលបានរៀបចំដោយអង្គការ Save the Children មានន័យថា "បរិស្ថានសិក្សាប្រកបដោយគុណភាព" ដែលមាន ៤គោលការណ៍សំខាន់ៗគឺៈ ១).កម្មវិធីអប់រំសមស្របតាមតម្រូវការផ្លូវអារម្មណ៍ និងផ្លូវចិត្តរបស់កុមារ ២).កម្មវិធីអប់រំត្រូវបានការពារសុខមាលភាពរាងកាយរបស់កុមារ ៣).កម្មវិធីអប់រំលើកទឹកចិត្ត និងគាំទ្រការចូលរួមយ៉ាងសកម្មពីសិស្សតាមរយៈការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលធ្វើឱ្យប្រសើរឡើងដល់ការសិក្សារបស់សិស្សទាំងអស់ និង (៤).កម្មវិធីអប់រំអាណាព្យាបាល សហគមន៍ ជាពិសេស បណ្តាញគណៈកម្មការអប់រំទាំងអស់គ្នាចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការការសម្រេច និងសកម្មភាពដើម្បីធ្វើឱ្យការអប់រំកាន់តែប្រសើរឡើង។ ក្របខណ្ឌគម្រោង QLE ព្យាយាមលើកកម្ពស់វិធីសាស្ត្រសរុបចំពោះការអភិវឌ្ឍការអប់រំ និងចែករំលែកវិធីដូចគ្នាទៅក្នុងទស្សនៈល្អៗ និងគោលនយោបាយរបស់សាលាកុមារមេត្រី។

ការប្រើប្រាស់ក្របខណ្ឌខាងលើ គម្រោង QLE បានគាំទ្រសកម្មភាពនានានៅក្នុងផ្នែកជាច្រើនដើម្បីលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយគុណភាពដល់កុមារទាំងនៅផ្ទះ និងនៅសាលារៀន។ គម្រោងក៏បានផ្តោតសំខាន់លើការលើកកម្ពស់អំណានថ្នាក់ដំបូង និងបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយសាលាដើម្បីបង្កើត "កន្លែងអាន" សម្រាប់ជំរុញការអាន ក៏ដូចជាការផ្តល់សម្ភារៈអំណានដើម្បីបង្កើតឱ្យមានបរិយាកាសអំណានសម្រាប់កុមារ។

## សកម្មភាពសំខាន់ៗ

- រៀបចំជារចនាសម្ព័ន្ធការងារ (យន្តការការងារ) សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត/ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ដើម្បីដឹកនាំការអនុវត្តគម្រោង។
- បង្កើតឱ្យមាន និងបណ្តុះបណ្តាលគ្រូបង្គោលដើម្បីជួយបំប៉នដល់គ្រូតាមសាលាគោលដៅ និងចុះជួយដល់សាលាជាប្រចាំដែលជាផ្នែកមួយនៃក្របខណ្ឌអនុវត្តគម្រោង QLE។
- ការបំប៉នសមត្ថភាពគ្រូ (បណ្តុះបណ្តាលគ្រូ) ដោយផ្តោតលើការបង្រៀនមុខវិជ្ជាគណិតវិទ្យា ភាសាខ្មែរ បំណិនជីវិត និងគោលការណ៍ទាំង ៤ របស់គម្រោង QLE។

## គោលបំណង

គម្រោងមានគោលបំណងពង្រីក (១). ការទទួលបានការអប់រំ/ការចូលរៀនសម្រាប់កុមារដែលពុំបានទទួលសេវាអប់រំ (២). បង្កើនគុណភាពសិក្សារបស់កុមារ ជាពិសេស កុមារជួបការលំបាក និង (៣). គាំទ្រដល់ក្រសួងអប់រំ/មន្ទីរអប់រំ/ការិយាល័យអប់រំស្រុក (រួមទាំងសាលារៀន) ដើម្បីកំណត់បញ្ហា និងដំណោះស្រាយសម្រាប់ពង្រីកការទទួលបានការអប់រំ/ការចូលរៀននៅតាមតំបន់ជនបទ និងដាច់ស្រយាល និងសម្រាប់ការកែលម្អគុណភាពសិក្សារបស់កុមារ។

## រូបភាពសកម្មភាព



សិស្សចូលរួមក្នុងការប្រកួតអំណានក្នុងពិធីប្រកួតអំណាន ដែលលើកកម្ពស់ការបង្កើនគុណភាពអប់រំនៅក្រៅថ្នាក់រៀន។



សកម្មភាពចុះអង្កេត និងវាយតម្លៃសកម្មភាពអំណាននៅតាមផ្ទះ។

## ផលជះរបស់គម្រោង

គម្រោងបានចាប់ដៃគូជាមួយសាលារៀន ១៩ ដើម្បីបង្កើតឱ្យមានកន្លែងអាននៅតាមសហគមន៍ រួមបញ្ចូលទាំងការអប់រំតាមខ្នងផ្ទះស្មើ ២៧ កន្លែង ដើម្បីសម្រួល និងបង្កើនទម្លាប់ការអាន និងសរសេររបស់កុមារនៅពេលទំនេរ ជាពិសស ក្រៅម៉ោងសិក្សា។ បន្ទាប់ពីការអនុវត្ត១ឆ្នាំកន្លងមក សង្កេតឃើញថាកន្លែងអានតាមសហគមន៍ភាគច្រើនមានដំណើរការ និងទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក សាលារៀន និងអាណាព្យាបាលសិស្ស ជាក់ស្តែងសហគមន៍ និងគណៈកម្មការសាលារៀនក៏បានផ្តល់ទីកន្លែងសម្រាប់ដំណើរការ និងបានចំណាយពេលវេលាច្រើនក្នុងការគ្រប់គ្រង និងថែរក្សាយ៉ាងយកចិត្តទុកដាក់ខ្ពស់បំផុត។ ថ្មីៗនេះមានសាលារៀនមួយចំនួនក្នុងគម្រោងបានទៅទស្សនកិច្ចនៅកន្លែងអាននៅតាមសហគមន៍នៅភូមិស្វាយព័ន្ធទី១ និងថ្លុកជ្រៅ នៅក្នុងចំណុះសាលាបឋមសិក្សា ថ្លុកជ្រៅ ហើយបានយកទៅរៀបចំតាមគំរូតាមសាលារៀងៗខ្លួន។

ក្នុងពេលបច្ចុប្បន្ន សាលារៀនក្នុងគម្រោងចំនួន ៩ សាលាបានរៀបចំបន្ទប់សុខភាពសិក្សាដើម្បីជួយសម្រួលការថែទាំសុខភាពកុមារ។ ម៉្យាងទៀត សាលាក៏បានធ្វើផែនការសុខភាពរួមជាមួយមណ្ឌលសុខភាពឃុំ។ ជាលទ្ធផល មណ្ឌលសុខភាពមានផែនការរួមជាមួយសាលារៀន និងបានចុះផ្សព្វផ្សាយ និងផ្តល់សេវាសុខភាពដល់សិស្សជាប្រចាំ៕

# ការបង្ហាញផ្នែកហិរញ្ញវត្ថុ

## សាច់ប្រាក់ និងការចំណាយ

| សេចក្តីពណ៌នា | ចំនួនសាច់ប្រាក់ជាដុល្លារអាមេរិក (USD) |
|---|---|
| ចំណូលថវិកាសរុបក្នុងគម្រោងប្រចាំឆ្នាំ២០១៦ | ២.១០១.៩០៩,១៥ |
| សមតុល្យចុងគ្រាពីឆ្នាំ២០១៥ | ១៧២.៤៥០,៣៤ |
| ចំណូលការប្រាក់ | ៤៨៩,៧០ |
| ទ្រព្យដែលអាចប្រើប្រាស់ក្នុងឆ្នាំ២០១៦ | ២.២៧៤.៨៤៩,១៩ |
| សរុបថវិកាចំណាយប្រចាំឆ្នាំ២០១៦ | ២.០៦១.១៦៩,៤៤ |
| អត្រាប្រើប្រាស់ថវិកា | ៩១% |

## និន្នាការទទួលថវិកា




## តើថវិកាជំនួយត្រូវយកទៅប្រើប្រាស់ដូចម្តេច ?




## លំហូរចំណូលឆ្នាំ ២០១៦

| ម្ចាស់ជំនួយ | ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក |
|---|---|
| ChildFund Cambodia (CFC) | ៥៣៩.២៣៧,០០ |
| Ministry of Education, Youth and Sport (MoEYS) | ៣៧៥.៦៧៦,៩៣ |
| Save the Children (SC)/NORAD | ២៣៩.១៦២,៧១ |
| The Oaktree Foundation (TOF) | ២១៣.៩១០,០៧ |
| WeWorld | ២០៨.៣៨០,២៧ |
| Autonimus | ១៩១.៥៥៧,០០ |
| World Vision | ១៩១.២៧៤,០០ |
| Aide et Action (AeA) | ៩៧.៨១០,១៣ |
| KAPE/Overhead | ៥០.៧៤៥,៧៦ |
| The Atlassian Foundation | ៣៤.៦១២,៧៨ |
| 100Women/Classroom of Hope (CoH) | ២៧.៨៦៩,៧៨ |
| USAID | ១៩.០៤៥,៧២ |
| The Breteau Foundation (TBF) | ៧.៤២៨,០០ |
| The Asia Foundation (TAF) | ៥.២០០,០០ |
| ការទទួលប្រាក់ចំណូលថ្មីឆ្នាំ២០១៦ | ២.២៧៤.៨៤៩,១៩ |

## សេចក្តីថ្លែងអំណរគុណ!

ជូនសមុខឱ្យកុមារ គ្រូបង្រៀន ឪពុកម្តាយ និងក្រុមអ្នកទទួលផលទាំងនោះមកពីកម្មវិធីរបស់យើង អង្គការ ខេប សូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់សម្រាប់ការផ្តត់ផ្គង់របស់ពួកគេក្នុងឆ្នាំនេះ និងឆ្នាំមុនៗកន្លងមក។ ហិការផ្តត់ផ្គង់ហិរញ្ញវត្ថុ បានធ្វើឱ្យអង្គការ ខេប ផ្តល់នូវសេវាកម្មជូនអ្នកទទួលផលប្រកបដោយអត្ថន័យគ្រប់គ្រាន់។ សូមអរគុណ!

# ថ្នាក់គ្រប់គ្រងអង្គការ ខេប ឆ្នាំ ២០១៦

## ក្រុមប្រឹក្សាភិបាល


**លោក ហ៊ាង គុយ**
ប្រធាន


**លោក ប៊ុន រិទ្ធី**
អនុប្រធាន


**លោក ធុច ថាត**
សមាជិក


**លោកស្រី ហែម មណី**
សមាជិក


**លោក ឆាយ ទីប៉ា**
សមាជិក

## ក្រុមអ្នកគ្រប់គ្រងជាន់ខ្ពស់ (SMT)


**លោក សៅ វណ្ណា**
នាយកប្រតិបត្តិ


**លោក ហ៊ិន ស៊ីមហួន**
នាយករងប្រតិបត្តិ និងប្រធានច្ចេកទេស


**លោក យីត ប្រាឌិនបើក**
ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់


**លោក បូ សម្បត្តិ**
នាយកគ្រប់គ្រងហិរញ្ញវត្ថុ


**លោក ឈួន សារ៉ាន**
ប្រធានរដ្ឋបាល និងធនធានមនុស្ស


**កញ្ញា ហ៊ឹម ម៉ារី**
ប្រធានសម្របសម្រួលកម្មវិធីអប់រំបញ្ចូលគ្នា (IEP)


**លោក អ៊ុល រុន**
ទីប្រឹក្សាជាតិជាន់ខ្ពស់


**លោកស្រី ជូឌីដ បល្ឌវីន**
ទីប្រឹក្សាបច្ចេកទេស

## អ្នកដឹកនាំសំខាន់ៗរបស់អង្គការ ខេប *(ឈ្មោះតាមលំដាប់អក្សរ)*


**លោក អារៀល រូហ្សិនថ្លាំ**
ទីប្រឹក្សាបច្ចេកទេស (NGS-ភ្នំពេញ)


**លោក ឆន ផៃយុទ្ធ**
ប្រធានគម្រោងE4K/TRAC II


**លោក ហង្ស ពិសិដ្ឋ**
ប្រធានគម្រោងខ្ញុំកំពុងរៀន


**លោក គំ ម៉េងហួរ**
ប្រធានគម្រោង QLE Exp.


**លោក លាង សុវណ្ណនី**
ប្រធានគម្រោង NGS-ស្វាយរៀង


**លោក ម៉ៃ សារិទ្ធិ**
ប្រធានគម្រោងរីក (REACH II)


**លោក នូ ស៊ីណាត**
ប្រធានគម្រោង ងាយស្រួលរៀន (E2L)


**លោក អឿ សាវីន**
អ្នកសម្របសម្រួលទំនាក់ទំនង


**លោក ដាន់ ប៊ុនណាត**
ប្រធានក្រុម/ទីប្រឹក្សាកម្មវិធីយុវជន


**លោក ភួង សាម៉េត**
ប្រធានផ្នែករៀបចំប្រព័ន្ធព័ត៌មាន


**លោក ពេជ្រ សុភឿន**
ប្រធានគម្រោង BFC


**កញ្ញា សែត សុលក្ខិណា**
អ្នកសម្របសម្រួលកម្មវិធីអំណាន


**លោក ស្លេះ តាហៀត**
ប្រធានគម្រោង អប់រំកុមារ (EAC)


**លោក សឿង វ៉ាន់**
ប្រធានគម្រោង BSI និង ISHS


**លោកស្រី សុខ គឹមហៀង**
មន្ត្រីសម្របសម្រួលគម្រោង CDL


**លោក ស្ទីវិន ព្រីជីន**
ទីប្រឹក្សាស្រាវជ្រាវ (IML)


**លោក ស៊ុំ វណ្ណៈ**
ប្រធានផ្នែកគ្រប់គ្រងធនធានសិក្សា*


**លោក ទុំ ទីតូណា**
ប្រធានគម្រោង SML

* ***Note:*** *TTS គឺជាសហគ្រាសសង្គមស្វ័យតសម្ព័ន្ធជាមួយអង្គការ ខេប។*

# រចនាសម្ព័ន្ធអង្គការ ខេប ក្នុងឆ្នាំ២០១៦




| | |
|---|---|
| AGPO | មន្ត្រីកម្មវិធីប្រមូលសិស្សរៀន និងអភិបាលកិច្ច |
| App. Dp | អ្នកអភិវឌ្ឍកម្មវិធី App. |
| AS | អ្នកជំនួយការ |
| BfC | គម្រោង សៀវភៅសម្រាប់កម្ពុជា |
| BSI | គម្រោង សាលារៀនដៃគូ |
| CCO | មន្ត្រីប្រឹក្សាអាជីព |
| CDL | គម្រោង បណ្ណាល័យអេឡិចត្រូនិចសម្រាប់កុមារ |
| DPO | មន្ត្រីបច្ចេកទេសថ្នាក់ស្រុក |
| E2L | គម្រោង ងាយស្រួលរៀន |
| E4K | គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ |
| EAC | គម្រោង អប់រំកុមារ |
| EQPO | មន្ត្រីកម្មវិធីគុណភាពអប់រំ |
| FAO | មន្ត្រីហិរញ្ញវត្ថុ និងរដ្ឋបាល |
| FO | មន្ត្រីហិរញ្ញវត្ថុ |
| GES | មន្ត្រីគុណភាពអប់រំទូទៅ |
| ICT in ES | មន្ត្រីជំនាញព័ត៌មានវិទ្យាសម្រាប់ការអប់រំ |
| ICTPO | មន្ត្រីកម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអប់រំ |
| IEP | កម្មវិធីអប់រំបញ្ចូលគ្នា |
| IML | គម្រោង ខ្ញុំកំពុងរៀន! |
| ISHS | គម្រោង លើកកម្ពស់សេវាកម្មសុខភាពសាលារៀន |
| KLS | គ្រូបង្រៀនភាសាខ្មែរ |
| M&EO | មន្ត្រីកម្មវិធីផ្នែកតាមដាន និងវាយតម្លៃ (MIS) |
| M&ES/RT | មន្ត្រីជំនាញផ្នែកតាមដាន និងវាយតម្លៃ/គ្រូបណ្តុះបណ្តាលអំណាន |
| NAS | ទីប្រឹក្សាគម្រោង NGS (ទំនាក់ទំនងព័ត៌មានវិទ្យាសម្រាប់ការអប់រំ) |
| NGS | គម្រោង សាលារៀនជំនាន់ថ្មី |
| NIO | មន្ត្រីអប់រំ ICT |
| NOM | ប្រធានប្រតិបត្តិការគម្រោង សាលារៀនជំនាន់ថ្មី |
| PA | អ្នកជំនួយការកម្មវិធី |
| PC | មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត |
| PED/DCD | នាយកដ្ឋានបឋមសិក្សា/នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| PF&A | មន្ត្រីហិរញ្ញវត្ថុ និងរដ្ឋបាល |
| PO | មន្ត្រីកម្មវិធី |
| QLE Exp. | គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព (ពង្រីក) |
| REACH II | គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពិសេសគមន៍ |
| RTL | ប្រធានដឹកនាំក្រុម |
| SA | អ្នកសម្របសម្រួលសាលា |
| SEA | ជំនួយការអប់រំវិទ្យាសាស្ត្រ |
| SEO | មន្ត្រីអប់រំវិទ្យាសាស្ត្រ |
| SGM | អ្នកប្រឹក្សាអភិបាលកិច្ចសាលារៀន |
| SML | គម្រោង គ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ |
| TL | ប្រធានដឹកនាំក្រុម |
| TRAC II | គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ |

ផ្នែកដឹកនាំ

ព្រួញទ្វេទិស = ទំនាក់ទំនងជាមួយទីប្រឹក្សា

ប្រអប់ដាច់ៗ = ស្វ័យយ័តភាព។ គណៈកម្មការគ្រប់គ្រងមូលនិធិសុខភាពមានស្វ័យយ័តភាពពេញលេញ។

POs** កម្មវិធីអប់រំបញ្ចូលគ្នា/IEP មាន៖ គម្រោង អប់រំកុមារី (GEI) និងគម្រោង STEM4WOMEN (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) ។ "POs" បង្ហាញអំពីមន្ត្រីទាំងអស់នៅក្នុងកម្មវិធី IEP ។

*សូមបញ្ជាក់ថា លំដាប់ថ្នាក់ក្នុងរចនាសម្ព័ន្ធខាងក្រោមផ្នែកដឹកនាំ ប្រធានផ្នែកនីមួយៗមិនត្រូវបានបញ្ចូលទៅក្នុងផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស/រដ្ឋបាល ដែលបានកំណត់ហើយនៅក្នុងបញ្ជីឈ្មោះ។